ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- អាកាសយានដ្ឋានពោធិ៍ចិនតុង៖ បំពេញមុខងារជាប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ច អស់រយៈកាល៨៥ឆ្នាំកន្លងមក
- ទិវាឯករាជ្យភាពសហរដ្ឋអាមេរិក ខួប ២៥០ឆ្នាំ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៣១៩ ខែកក្កដា ឆ្នាំ២០២៦

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### ផ្នែកសំបុត្រ


◆ អាកាសយានដ្ឋានពោធិ៍ចិនតុង៖ ............... ១

◆ ទិវាឯករាជ្យភាពសហរដ្ឋអាមេរិកខួប ២៥០ឆ្នាំ .. ៣


### ផ្នែកឯកសារ


◆ ទូរលេខ លេខ៤៥ ចុះថ្ងៃទី៦-១០-៧៧.........៥

◆ គង់ ជាស៊ិន ហៅ ស៊ុន៖ លេខាតំបន់២០........ ៦

◆ គង់ គៀន៖ លេខាវរសេនាតូច៦៣១........... ៩

◆ គង់ ប៊ុនលិន៖ ប្រធានរោងពុម្ព ............... ១២

◆ មុត សុន ហៅ វណ្ណៈ ត្រូវចាប់ខ្លួនដោយសារ .. ១៥


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ វីរកងទ័ព គីយ គៀន .......................... ១៩

◆ វីរកងទ័ព គួ សែនសុភា ពលីនៅសមរភូមិ... ២១

◆ ហាច ហៀក៖ ប្រជាជនភៀសសឹកនៃ........ ២៤

◆ គ្រឹង នួន៖ ប្រធានកងកុមារក្នុងរបប..........២៨

◆ ដួង សាម៉ុន៖ គ្រូបង្រៀនកុមារ...............៣១

◆ ឈិត ឆេង៖ កុមារជនជាតិដើមភាគតិចព័រ .. ៣៤

◆ ស៊ុំ សឿម៖ ចូលបដិវត្តន៍ខ្មែរក្រហម.........៣៧

◆ គិន ហៀ៖ តស៊ូទៅសាលារៀន ទោះបី ...... ៣៩

◆ វដ្តជីវិត និងការបម្លាស់ទីតាមរដូវកាល ...... ៤២

◆ ស្ថានទូតហ្វីលីពីន សហការជាមួយមជ្ឈមណ្ឌល ឯកសារកម្ពុជា និងរដ្ឋបាលស្រុកបុរីអូរស្វាយ.. ៤៤

◆ រដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ សម្របសម្រួល ដំណើរបេសកកម្មរបស់គណៈប្រតិភូ..........៤៧

◆ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីមកពីក្រសួង សុខាភិបាល រៀបចំកម្មវិធី .................... ៤៩




មេដឹកនាំភូមា ណេ វិន នៅព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ផ្នែកវេទិកាពិភាក្សាសាធារណៈ


◆ សិស្សានុសិស្សមកពីសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម ទស្សនកិច្ច....... ៥២

◆ សិស្សវិទ្យាល័យអន្លង់វែងទស្សនា ខ្សែភាពយន្តឯកសារ និងសិក្សាពី ........... ៥៥

◆ សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ មកសិក្សាស្វែង យល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ............ ៥៧


### ផ្នែកស្រាវជ្រាវរកគ្រួសារ


◆ ខ្ញុំកូវ ផល្លា៖ អតីតយោធាកងពលលេខ៣១០ ដែលបាត់ខ្លួន.................................... ៦១

◆ ជាតិនេះ ខ្ញុំប៉ិះតែនឹងស្លាប់(ត) ............... ៦៣



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ៖** ឆាំង យុ, មេក វិន, នេន ស្រីមុំ, ជីម សុខកា, សា ហ៊ី, ធី គីមហុង, ចាន់ណារិទ្ធ, ភា រស្មី, ស្រេង លីដា, មឿន ស្រីណុច, ស៊ាង ចិន្តា, វន បុប្ផា, សួត វិចិត្រ, អេង សុខម៉េង និង សៀវ សុផុន

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ិកឹង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ផេង ពង្ស

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# អាកាសយានដ្ឋានពោធិ៍ចិនតុង៖
## បំពេញមុខងារជាប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ច អស់រយៈកាល៨៥ឆ្នាំកន្លងមក

**ឆាំង យុ**



*ព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង នៅទសវត្សរ៍ឆ្នាំ១៩៥០ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

អាកាសយានដ្ឋានពោធិ៍ចិនតុង គឺជានិមិត្តរូបនៃអត្តសញ្ញាណប្រទេសកម្ពុជា ដែលមានវត្តមានផ្សារភ្ជាប់រវាងសម័យមុននិងសម័យកាលទំនើប បរិស្ថាននិងប្រជាជនភូមិឋាននិងពិភពលោកៗ ក្នុងនាមជាព្រះរាជស្នាព្រះហស្តជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ អាកាសយានដ្ឋានពោធិ៍ចិនតុងគឺជាផ្នែកមួយនៃផែនការកែប្រែមុខមាត់ប្រទេសជាតិនាសម័យកាលសង្គមរាស្ត្រនិយម ស្ថិតក្រោមព្រះរាជបេសកកម្មដឹកនាំដ៏ឈ្លាសវៃនៃសម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរៗ អាកាសយានដ្ឋានពោធិ៍ចិនតុងគឺជាទីតាំងដ៏ពិសេសមួយ ចំពោះព្រះរាជដំណើរជីវិតនៃសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ និងចំពោះកេរដំណែលប្រទេសជាតិថែមទៀតផងៗ

នយោបាយ វប្បធម៌ សេដ្ឋកិច្ច និងប្រវត្តិសាស្ត្រ សុទ្ធសឹងតែបានក្រងត្របាញ់ភ្ជាប់ជាមួយគ្នានៅក្នុងបរិវេណនៃទីតាំងបេតិកភណ្ឌជាតិមួយនេះ ដែលឈរ

កៀកទៅនឹងរាជធានីរបស់ប្រទេសកម្ពុជា ទីតម្កល់ព្រះរាជបល្ល័ង្កជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់នៃរាជវង្សានុវង្ស ព្រះបរមរាជវាំង ព្រះរាជវត្តមាននៃព្រះករុណា ព្រះមហាក្សត្រ និងព្រះរាជសុបិនដ៏ថ្លៃថ្លានៃសម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ ដើម្បីប្រទេសកម្ពុជា។

ព្រះរាជសុបិនដ៏ថ្លៃថ្លានៃសម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរចំពោះប្រទេសកម្ពុជា គឺព្រះអង្គចង់ឱ្យប្រទេសនេះមានសន្តិភាព និងវិបុលភាព ដោយបម្រើមុខងារជាចំណុចប្រមូលផ្តុំនៃការដោះដូរពាណិជ្ជកម្មអន្តរជាតិ សម្រេចបានជាសមិទ្ធផលវប្បធម៌ និងលើកស្ទួយឧត្តមភាពនៃផ្នែកសិក្សាធិការ។ សង្គ្រាម អស្ថិរភាព ភាពក្រីក្រ និងជម្លោះផ្ទៃក្នុង ក៏ដូចជាអំពើប្រល័យពូជសាសន៍ស្ទើរតែបំផ្លិចបំផ្លាញព្រះរាជសុបិននេះ អស់ទាំងស្រុងទៅហើយ។ ទោះបីជាយ៉ាងណាក្តី បច្ចុប្បន្ន ខណៈពេលដែលកម្ពុជាបោះជំហានឆ្ពោះទៅកាន់អនាគតមួយដ៏ត្រចះត្រចង់ប្រកបទៅដោយក្តីសង្ឃឹម ព្រះរាជសុបិនរបស់សម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ បានចាំងរស្មីយ៉ាងត្រចះត្រចង់ផុសឡើងនៅក្នុងក្រឡបេះដូងរបស់យុវជនយុវនារីកម្ពុជា នៅក្នុងរាល់សកម្មភាព សេចក្តីសង្ឃឹម និងក្តីស្រមៃ។

អាកាសយានដ្ឋានពោធិ៍ចិនតុង គឺតែងតែស្ថិតនៅដក់ជាប់នៅក្នុងព្រះរាជហឫទ័យនៃសម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ ដោយសារតែអាកាសយានដ្ឋានពោធិ៍ចិនតុងគឺមិនមែនត្រឹមតែជាអាកាសយានដ្ឋានសាមញ្ញមួយតែប៉ុណ្ណោះទេ ប៉ុន្តែគឺជាព្រះរាជជំហានជានិមិត្តរូបមួយ នៅក្នុងព្រះរាជបេសកកម្មរបស់សម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ ក្នុងការប្រែផ្លាស់មុខមាត់ប្រទេសជាតិ។ អាកាសយានដ្ឋានពោធិ៍ចិនតុង ត្រូវបានអភិវឌ្ឍន៍ចេញពីទីវាលហោះហើរដ៏តូចមួយជាដំបូងនៅឆ្នាំ១៩៤១ ឱ្យទៅជាអាកាសយានដ្ឋានដែលតភ្ជាប់ប្រទេសកម្ពុជាទៅកាន់ពិភពលោក និងបម្រើមុខងារជាទីប្រជុំនៃមធ្យោបាយធ្វើដំណើរដ៏សំខាន់ប្រចាំរាជធានី។ អាកាសយានដ្ឋានពោធិ៍ចិនតុងបានផ្លាស់ប្តូរមុខមាត់ ដោយដើរតួនាទីជាជំហាននិមិត្តរូបមួយឆ្ពោះទៅកាន់ការធ្វើទំនើបកម្មរបស់ប្រទេសកម្ពុជា បន្ទាប់ពីទទួលបានឯករាជ្យភាពពេញលេញ។ សម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ ព្រះអង្គឈ្វេងយល់យ៉ាងច្បាស់អំពីសារសំខាន់នៃការដែលអាកាសយានដ្ឋាននេះ នឹងក្លាយទៅជាទីតាំងដែលទទួលស្វាគមន៍អ្នកដំណើររាប់លាននាក់មកកាន់ប្រទេសកម្ពុជា។ ដូច្នេះហើយ ព្រះអង្គបានរាជានុញ្ញាតចាត់តាំងឱ្យស្ថាបត្យករឯកប្រចាំប្រទេសចូលរួមដោយផ្ទាល់នៅក្នុងការរចនាសាងសង់អាកាសយានដ្ឋាននេះឡើង។ សព្វថ្ងៃថ្មីត្បិតតែអាកាសយានដ្ឋានពោធិ៍ចិនតុងត្រូវបានគេហៅថាជា «ព្រលានយន្តហោះចាស់» យ៉ាងណាក្តី អាកាសយានដ្ឋានពោធិ៍ចិនតុងនេះរក្សាបាននូវអត្តន័យដ៏វិសេសវិសាល ដែលមិនមែនត្រឹមតែជាសំណង់ដែលបន្សល់ពីសម័យមុនរបស់ប្រទេសកម្ពុជាឡើយ។ បច្ចុប្បន្ន អាកាសយានដ្ឋានពោធិ៍ចិនតុង គឺជាចំណុចប្រសព្វរវាងអតីតកាល និងអនាគតកាលរបស់កម្ពុជា ហើយអាកាសយានដ្ឋានពោធិ៍ចិនតុងនេះ ពោរពេញទៅដោយសក្តានុពលក្នុងការផ្លាស់ប្តូរតួនាទីទៅជាទីតាំងថ្មីមួយ សម្រាប់ការរំលេច និងការបំផុសអត្តសញ្ញាណជាតិរបស់ប្រទេសកម្ពុជាសាជាថ្មី និងជាព្រះរាជសុបិនដ៏ថ្លៃថ្លានៃព្រះរាជស្ថាបត្យករកំពូលរបស់កម្ពុជា គឺសម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ។

**ឯកឧត្តម ឆាំង យុ** គឺជាឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយនឹងក្រុមស្ថាបត្យករនៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែរួមមាន លោក ទិត្យ សត្យាវង្ស, កញ្ញា លឹម វណ្ណសូលីហ្សា និង កញ្ញា លាង ចន្ទី ដែលទទួលបានជ័យលាភីលេខ១ ក្នុងការប្រកួតប្រជែងរចនាប្លង់អាកាសយានដ្ឋានពោធិ៍ចិនតុង។

# ទិវាឯករាជ្យភាពសហរដ្ឋអាមេរិក ខួប ២៥០ឆ្នាំ

**ឆាំង យុ**



*លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ក្នុងឱកាសដ៏ថ្លៃថ្លានៃការប្រារព្ធខួបទិវាឯករាជ្យភាពសហរដ្ឋអាមេរិក ខ្ញុំកាន់តែមានជំនឿចិត្តយ៉ាងមុតមាំទៅលើឥទ្ធិពលដ៏ស្ថិតស្ថេរ និងចីរកាលនៃ **ផ្នត់គំនិតសហរដ្ឋអាមេរិក** ដែលផ្នត់គំនិតនេះគឺមិនមែនកើតចេញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រតែមួយ ចលនានយោបាយណាមួយ ឬមេដឹកនាំណាម្នាក់នោះឡើយ ប៉ុន្តែវាគឺជាកត្តារួមផ្សំ និងការវិវត្តនៃកម្លាំងចលករទាំងអស់នេះ ដែលបានបង្កើតឱ្យមានជាប្រជាជាតិសហរដ្ឋអាមេរិកនេះឡើង។ ផ្នត់គំនិតសហរដ្ឋអាមេរិកគឺផ្តើមផុសចេញពីគោលការណ៍គ្រឹះដែលថាសហរដ្ឋអាមេរិកបានចងភ្ជាប់គ្នា ហើយគឺមិនមែនដោយសារតែខ្សែស្រឡាយពីដូនតា ពូជសាសន៍ ឬជនជាតិនោះទេ ប៉ុន្តែគឺដោយសារតែភាពស្មោះត្រង់ចំពោះរាល់គោលការណ៍ជាសកលដែលមានចែងយ៉ាងច្បាស់នៅក្នុងសេចក្តីប្រកាសឯករាជ្យភាពរួមមាន៖ សមភាព សេរីភាព និងស្វ័យរដ្ឋាភិបាល។ ទោះជាយ៉ាងណានៅខណៈពេលដែលប្រជាជាតិសហរដ្ឋអាមេរិកបានចាប់ផ្តើមកកើតឡើងជាមួយនឹងគោលការណ៍ទាំងអស់នេះ ទស្សនវិជ្ជាសហរដ្ឋអាមេរិកស្តីពីរបបគ្រប់គ្រងរដ្ឋ ការដឹកនាំ និងមនុស្សធម៌ មានអត្ថន័យ

កាន់តែជ្រាលជ្រៅ និងជាប្រភពបំផុសគំនិតដ៏មានឥទ្ធិពលខ្លាំងក្លាលើសគេ សម្រាប់សហគមន៍អន្តរជាតិ និងប្រវត្តិសាស្ត្រពិភពលោក។

ក្នុងនាមជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាជនភៀសខ្លួនខ្មែរម្នាក់ សហរដ្ឋអាមេរិកគឺមិនមែនត្រឹមតែជាពន្លឺនៃក្តីសង្ឃឹម សម្រាប់ជោគវាសនាផ្ទាល់ខ្លួនរបស់ខ្ញុំតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាទីពំនាក់និងជាដែនទីបង្ហាញផ្លូវដ៏សំខាន់ក្នុងការប្តេជ្ញាចិត្តរបស់ខ្ញុំ ដើម្បីចូលរួមចំណែកគាំទ្រដល់ការកសាងប្រទេសកម្ពុជាឡើងវិញ ក្រោយការបំផ្លិចបំផ្លាញនៃសង្គ្រាមដែលមិនអាចនឹកស្មានដល់ ការអត់ឃ្លានខ្លោចផ្សា និងអំពើអមនុស្សធម៌ដ៏ឃោរឃៅបំផុត។ សហរដ្ឋអាមេរិកបានផ្តល់ឱកាសដល់ខ្ញុំ។ រីឯផ្នត់គំនិតសហរដ្ឋអាមេរិក គឺបានបន្ថែមទាំងកម្លាំងជំរុញលើកទឹកចិត្ត និងផ្តល់ក្តីសង្ឃឹមដ៏រុងរឿងដល់ជីវិតខ្ញុំ។ គំនិតចម្បងនៃការកំណត់ថា «តើអ្វីទៅគឺជាជនជាតិអាមេរិកពិតប្រាកដនោះ?» ទស្សនមួយនេះត្រូវបានគេយល់ច្រឡំដោយផ្អែកទៅលើរូបរាងចំណង់ចំណូលចិត្តបុគ្គលក្ខណៈសម្គាល់ដទៃទៀតលើផ្នែកសម្បកក្រៅនៃរូបរាងកាយ ដែលការគិតទាំងនេះទទួលឥទ្ធិពលយ៉ាងធ្ងន់ធ្ងរពីគំនិតដ៏ចាស់គំរិលមួយ ឬការវាយតម្លៃដោយខ្វះការយល់ដឹងច្បាស់លាស់ទៅលើប្រជាជនសហរដ្ឋអាមេរិក។ សម្រាប់ខ្ញុំ ខ្ញុំយល់ឃើញថា និយមន័យនៃជនជាតិអាមេរិកគឺត្រូវតែចាប់ផ្តើមចេញពីផ្នត់គំនិត និងស្មារតី ពីព្រោះកត្តាទាំងនេះហើយ ដែលជាឥទ្ធិពលនៃ «ផ្នត់គំនិតសហរដ្ឋអាមេរិក» ដែលចាក់ឫសយ៉ាងមាំ ស្ថិតស្ថេរ និងចីរកាលដ៏យូរអង្វែងបំផុត។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមសម្តែងនូវសេចក្តីដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរដ្ឋាភិបាល និងប្រជាជនសហរដ្ឋអាមេរិក ព្រមទាំងសូមប្រសិទ្ធពរជ័យ និងជូនពរដោយស្មោះអស់ពីចិត្តក្នុងទិវាឯករាជ្យភាពសហរដ្ឋអាមេរិកគម្រប់ខួប២៥០ឆ្នាំនេះ។



លោក ឆាំង យុ ថតក្នុងឆ្នាំ១៩៩៥ នៅសាកលវិទ្យាល័យ យ៉េល ក្នុងកម្មវិធីស្រាវជ្រាវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កងពល បស្ទិម

ផ្នែក ន.ប

# ទូរលេខ លេខ៨៥ ចុះថ្ងៃទី៦-១០-៧៧

ដកស្រង់ចេញពីឯកសារ D០១៨៦១

## សូមជូន សេចក្តីរាយការណ៍

១- នៅយប់ថ្ងៃ៥-១០ កងការពារយើងនៅដែនសមុទ្របានចេញល្បាតការពារដោយ ទូករបស់ខ្មាំង ចូលមកដល់ខាងលិចកោះកុងក្រៅ ជាច្រើនគ្រឿង។

២- មកដល់ម៉ោង៤ទៀបភ្លឺ ចាប់បានកាណូតខ្មាំងបាន១គ្រឿង នៅ ខាងលិចកោះក្ងួរស្រូវ។

៣- កាណូតនេះផុន ៥០០ សេស និងមនុស្សជាតិថៃម្នាក់។

៤- សម្ភារមានដូចតទៅ

-វិទ្យុកូ ខ្លាំង ១គ្រឿង។

-ប្រដាប់ស្ទង់ទឹក ១។

-កាំភ្លើងខ្លី ១ដើម និងសម្ភារមួយចំនួនទៀត។



កប៉ាល់របស់កងទ័ពបដិវត្តន៍ខ្មែរក្រហម (១៩៧៥-១៩៧៩) នៅកំពង់ផែកំពង់សោម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចម្លងជូនៈ

-ម.០៩ កោះកុង

-បង ៨៩ -មន្ទីរ -ឯកសារ

# គង់ ជាសុិន ហៅ ស៊ុន ៖ លេខាតំបន់២០ ភូមិភាគបូព៌ា

**ដារ៉ារដ្ឋ មេត្តា**



កម្មាភិបាលខ្មែរក្រហមចុះទៅតាមសហករណ៍ អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គង់ជា សុិនហៅ ស៊ុនមានស្រុកកំណើតនៅភូមិត្រពាំងកក់ ឃុំកូនសត្វ ស្រុកកំពត(បច្ចុប្បន្នស្រុកទឹកឈូ) ខេត្តកំពត តំបន់៣៥ ភូមិភាគនិរតី។ ខ្ញុំមានប្រពន្ធឈ្មោះ ហុង រឿនហៅ ស៊ានគឺជាសមាជិកគណៈមន្ទីរតំបន់២០ រួមមានស្រុកព្រៃវែង ស្រុកមេសាង ស្រុកកំចាយមារ ស្រុកកញ្ជៀច ស្រុកពញាក្រែក។ យើងមានកូនចំនួន២នាក់នៅតូចៗ។

ខ្ញុំមានឪពុកឈ្មោះ គង់ជាម អតីតអ្នកតស៊ូចាស់។ នៅឆ្នាំ១៩៥៨ ឪពុកខ្ញុំបាននាំខ្ញុំមកនៅជាមួយឈ្មោះ ចាន់ គឺជាស័ក្តិ៤ដែលជាក្មួយរបស់គាត់ ហើយខ្ញុំគឺជាកូនធម៌របស់ ចាន់។ ផ្ទះរបស់ ចាន់មានទីតាំងនៅម្តុំទួលគោក។ ចាន់ បានចាត់តាំងខ្ញុំឱ្យដើរយកការណ៍តាមកន្លែងទាហានរស់នៅ និងពិនិត្យសកម្មភាពទាហាន។

នៅឆ្នាំ១៩៦០ ចាន់បញ្ចូលខ្ញុំជាសេ-អុី-អា និងឱ្យប្រាក់ខែខ្ញុំចំនួន១៨០០រៀល។ ប្រហែលជា២ខែក្រោយមក ចាន់ ឱ្យខ្ញុំទៅនៅផ្ទះឈ្មោះ ហុងយិ ដើម្បីធ្វើជានីរសារពីកំពតមកភ្នំពេញ។ ចាន់ បានប្រាប់ថានីរសារទៅមកកំពតមានភារកិច្ចពីរគឺ ទី១) ជានីរសារទាក់ទងខ្សែពីខាងភ្នំពេញ និងទី២) ចូលបង្កប់ខ្លួនក្នុងចលនាបដិវត្តន៍ តាមរយៈឈ្មោះ ពេជ ដែលជាសេ-អុី-អា បង្កប់ក្នុងចលនាបដិវត្តន៍ដែរ។ ពេលខ្ញុំទៅ

កំពតខ្ញុំបានទាក់ទងជាមួយឈ្មោះ ពេជ ត្រូវជាឪពុកធំខាងម្តាយខ្ញុំ។ នៅខែធ្នូ ឆ្នាំ១៩៦២ ពេជ នាំខ្ញុំមកខ្ទេសនាមឱ្យបង សែ នៅទួលគោក ក្រុងភ្នំពេញ។ ពេជ បានប្រាប់ខ្ញុំថា បងសែ គឺជាមនុស្សដែលគាត់គោរព និងជាខ្សែខាងលើ ហើយឱ្យខ្ញុំទាក់ទងគាត់ឱ្យជាប់។ ដើមឆ្នាំ១៩៦៣ បងសែ ណែនាំខ្ញុំឱ្យចេញទៅព្រៃភូមិភាគបូព៌ា ហើយឱ្យខ្ញុំទាក់ទងជាមួយឈ្មោះ ណាំសានគឺជាលេខាខេត្តស្វាយរៀងកាលជំនាន់នោះ។ ពេលទៅដល់បងសែ ហុចសំបុត្រពីរច្បាប់ឱ្យខ្ញុំយកទៅឱ្យ ណាំសាន។ សំបុត្រនោះមួយជាសំបុត្រចំហស្របច្បាប់ហើយ សំបុត្រមួយទៀតគឺជាសំបុត្រសម្ងាត់ខ្ទេសនាមខ្ញុំឱ្យ ណាំសាន។ ពេលខ្ញុំចេញមក បងសែជូនដំណើរដល់អ្នកលឿង ទើបនីសាររបស់ ណាំសានឈ្មោះ យនមកទទួលខ្ញុំ។ យនបាននាំខ្ញុំទៅជួប ណាំសាននៅខាងកើតភូមិ ក្នុងឃុំជីភូ (ខេត្តស្វាយរៀង)។ ណាំសាន ទទួលសំបុត្រហើយប្រាប់ខ្ញុំថា «ឥឡូវមិត្តនៅជាមួយខ្ញុំ វាយសម្រុកធ្វើការក្នុងមូលដ្ឋានជាមួយគ្នា ហើយខំរក្សាការសម្ងាត់កុំឱ្យបែកការណ៍»។ ខ្ញុំនៅជាមួយ ណាំសាន បានប្រហែលជា៥ខែខ្ញុំបានស្គាល់កម្លាំង សេ-អ៊ី-អា មួយចំនួនក្នុងនោះរួមមាន៖ ឈាន លេខាតំបន់២៣, គួន អនុលេខា តំបន់២៣, សូ លេខាតំបន់២៣, សំអឿន លេខាស្រុកក្រសាំង តំបន់២៣, សំអនលេខាស្រុកចន្ទ្រាតំបន់២៣,តាគ្រលីងគ្រលោង ហៅ លាង សព្វថ្ងៃប្រធានការដ្ឋានតំបន់២០, ចាន់ អនុលេខាស្រុករមាសហែក, សារុនសព្វថ្ងៃពាណិជ្ជកម្មភូមិភាគ, សារី កាន់ឃ្លាំងគ្រាប់តំបន់២០, យ៉ា សេនាធិការតំបន់២៣ (ចាប់ខ្លួន), សូផាត គណៈតំបន់២៣, អាន់ សព្វថ្ងៃលេខាវរៈសេនាតូច តំបន់២៣, ង៉ាន់ កងការពារណាំសានលេខាវរៈសេនាធំកងពល១៧០។ ក្រោយមកណាំសានទៅប្រជុំនៅមន្ទីរភាគនៅត្រែង។ ចាន់ សាម៉ន ហៅ ង៉ូវ បានស្នើសុំខ្ញុំពីណាំសានយកធ្វើជាកងការពាររបស់គាត់។ ណាំសានបានយល់ព្រម។ កងការពារ តាង៉ូវ មានចំនួន៤នាក់គឺ ខ្ញុំ, ចាប (ស្លាប់ឆ្នាំ១៩៧០), ម៉ន (ស្លាប់ឆ្នាំ១៩៦៨) និង ឈិន។ នៅឆ្នាំ១៩៦៣ តាង៉ូវ បានយកខ្ញុំមកនៅជាមួយគាត់នៅមន្ទីរ១០០។

នៅខែធ្នូ ឆ្នាំ១៩៧១ បង១៨ ដកខ្ញុំពីលេខាស្រុកមកធ្វើជាលេខាតំបន់២០ ចំណែក ឆន គឺជាអនុលេខាតំបន់ចាស់ដដែល។ តាំងពីខ្ញុំឡើងជាលេខាតំបន់មកខ្ញុំទាក់ទងជាប់ជាមួយបង១៨ ហើយរួមធ្វើសកម្មភាពជាមួយបង១៨ និងគណៈតំបន់គ្រប់តំបន់។ កម្មាភិបាលនៅតំបន់២០ បង១៨ មិនដែលយកពីតំបន់ផ្សេងចូលទេ ប៉ុន្តែបើកម្មាភិបាលតំបន់២០ បង១៨ មានដកទៅដាក់នៅតំបន់ផ្សេងទៀតដូចជា៖ សុត ដកពីសមាជិកស្រុកពញាក្រែក ទៅលេខាស្រុកត្រមូងមួយរយៈចាត់តាំងជាលេខាតំបន់២១, ស្រេង ដកពីសមាជិកស្រុកពញាក្រែកទៅលេខាស្រុកត្រមូង, សុខ ដកពីលេខាស្រុកព្រៃវែង ឱ្យទៅជាលេខាស្រុកក្រូចឆ្មារ តំបន់២១, ឈុន ដកពីសមាជិកស្រុកកំចាយមារទៅជាលេខាស្រុកទឹកជ្រៅ ចំណែកលេខាស្រុកឆ្លូងទៅពីតំបន់២០, ម៉ុល ដកពីគណៈពិនិត្យប្រវត្តិរូបរបស់តំបន់២០ ទៅចាត់តាំងជាអនុតំបន់២២, សាវ៉ាន់ អនុតំបន់២៤ ដកពីតំបន់២០។

នៅខែឧសភា ឆ្នាំ១៩៧៥បង១៨ហៅកម្លាំងមកប្រជុំនៅព្រៃគរ ហើយអ្នកចូលរួមមាន៖ បង១៨, ភួង, ឈាន, ពាម, ស៊ាត ឆែ ហៅ ទុំ លេខាតំបន់២២, ឈូក លេខាតំបន់២៤, សុត លេខាតំបន់២០, អ៊ុក សាវ៉ាន ហៅ សូ លេខាតំបន់២៣, សារុន និង ខ្ញុំ។ បង១៨ ណែនាំពីការរៀបចំផែនការ ទាក់ទងភាគផ្សេងៗនិងការទាក់ទងយួន ព្រមទាំងឱ្យរៀបចំសកម្មភាពក្នុងភូមិភាគ ទាំងមូល និងគ្រប់ផ្នែក។

នៅឆ្នាំ១៩៧៦ បង១៨ បានណែនាំកម្លាំងនៅគ្រប់តំបន់មានឈ្មោះ៖ សូ, សុត, ឈាន, ពាម និង ខ្ញុំ។ បង១៨ បានលើកឡើងពីគោលការណ៍ដូចតទៅ៖ សម្រិតសម្រាំងកម្លាំងនៅក្នុងយោធា និងរដ្ឋអំណាចមូលដ្ឋានដែលជាកម្លាំងល្អរបស់អង្គការដកចេញ, ពង្រីកកម្លាំង សេ-អ៊ី-អា បង្កប់នៅក្នុងសហករណ៍កងធំនិងកងតូច និង គ្រប់ក្រសួងមន្ទីរ ជុំវិញភាគតំបន់ស្រុក, រៀបចំរំលាយរបបសមូលហភាពក្នុងសហករណ៍ពេលដែលវាយបក្សភ្លាមៗ។ នៅខែឧសភា ឆ្នាំ១៩៧៦ ខ្ញុំបានរៀបចំកម្លាំងហើយដាក់កម្លាំង សេ-អ៊ី-អា ឱ្យក្តាប់ដើម្បីរៀបចំកម្លាំង អនុវត្តផែនការវាយបក្សនៅចុង

ឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧។ ក្រោយពីសម្រិតសម្រាំងហើយខ្ញុំឈប់ឱ្យកម្លាំងធំទៅវាយយួន និងអប់រំកងទ័ពបំផុសសីលធម៌ទី៦ ទូទៅទាំងអង្គការនារីមូលដ្ឋាននារីចល័ត និងកសាងកម្លាំង សេ-អ៊ី-អា។

នៅឆ្នាំ១៩៧៧ បង១៨ ហៅខ្ញុំ, សូ, សារុន, ម៉ុន ទៅទាក់ទងជាមួយយួនឈ្មោះ ហាយ សូគណៈមជ្ឈិម, ទីកាមគណៈទាក់ទងរបស់មជ្ឈិម និងប៉ៃម៉ាប់អនុគណៈទាក់ទងរបស់មជ្ឈិម។ បង១៨ បានរាយការណ៍ពីសភាពការណ៍កម្មាភិបាល មានការតឹងរឹង ហើយបក្សកុម្មុយនីស្តកម្ពុជាមានការបោសសំអាតអ្នកតស៊ូចាស់ៗ បន្ទាប់ពីពិភាក្សាគ្នា យួនលើកពីវិធានការណ៍ឱ្យរៀបចំកងទ័ពភូមិភាគបូព៌ា និងកសាងកម្លាំង សេ-អ៊ី-អា, កសាងកម្លាំងបង្អែក គឺយកយួនជាមូលដ្ឋាន, រៀបចំផែនការវាយបក្សកុម្មុយនីស្តកម្ពុជា ព្រោះបើមិនផ្ទុះអាវុធវាយបក្សកុម្មុយនីស្តកម្ពុជាទេ គឺដោះស្រាយសភាពការមិនរួចទេ។ ផែនការវាយកំណត់នៅខែកញ្ញា ឆ្នាំ១៩៧៧ម្តង និងខែវិច្ឆិកា ឆ្នាំ១៩៧៧ ម្តងទៀត។ ក្រៅពីនេះបានពិភាក្សាគ្នាពីបញ្ហាឧបត្ថម្ភ សេដ្ឋកិច្ច គឺឱ្យជ្រូកចំនួន១០០ក្បាលទៅយួន។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧ យើងបានបើកប្រជុំមួយនៅក្នុងឃុំដូនតីខាងកើតក្នុងស្រុកពញាក្រែក សមាសភាពចូលរួមមាន៖ បង១៨គឺជាលេខាភូមិភាគ២០៣, ភួងចម្ការកៅស៊ូរដ្ឋ, ញឹម លេខាភូមិភាគពាយ័ព្យ, ពាម មន្ទីរភូមិភាគបូព៌ា, ឈាន លេខាតំបន់២២, សុត តំបន់២១, រិន លេខាកងពលទី៤, កែវ សំណាង ហៅ ម៉ុន សេនាធិការភូមិភាគបូព៌ា ២០៣, សារុន ពាណិជ្ជកម្ម២០៣ និងខ្ញុំតំបន់២០។ ខ្លឹមសារប្រជុំពិនិត្យសភាពការណ៍កម្លាំងបដិវត្តន៍សព្វថ្ងៃ, កម្លាំងបក្សពលករយើងមួយចំនួន កម្លាំងបក្សកុម្មុយនីស្តកម្ពុជា កម្ទេចនៅសល់មួយចំនួននិងបែងចែកភារកិច្ច, កសាងកម្លាំងបក្សពលករ។ ពេលខ្ញុំទាក់ទងយួនហើយ យើងឱ្យអាវុធមួយឡានម៉ាកកាត់សង់កាត់ ទៅរៀបចំកងពលរបស់តំបន់២០ ហើយនៅសល់អាវុធចំនួន១៥០ដើម បានយកទៅលាក់នៅខាងកើតភូមិត្រាចខោល។ អាវុធនេះគាស់យកមកបំពាក់ឱ្យក្រុមនារីគ្រប់ស្រុក នៅខែកញ្ញា ឆ្នាំ១៩៧៧។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ យើងបានរៀបចំចាត់តាំងកងពលរបស់តំបន់២០ ពេលនោះខ្ញុំណែនាំ បេ, សារុន និង វិបុល លើកគោលការណ៍រៀបចំចាត់តាំងកម្លាំង សេ-អ៊ី-អា ក្តាប់កងវរសេនាតូចទាំងអស់របស់តំបន់២០។

នៅខែឧសភា ឆ្នាំ១៩៧៨ ខ្ញុំលែងបានជួបជាមួយភឹម ដូច្នេះការទាក់ទងជាមួយយួនខ្ញុំទាក់ទងជាមួយឈ្មោះ ថាំង និង ង៉ុយ ជាប់រហូតពីបញ្ហារៀបចំចាត់តាំងកងទ័ពលាយជាមួយយួន។ កម្លាំងខាងក្រោយទាក់ទងជាមួយលេខាស្រុកគ្រប់ស្រុកហើយ ទុយអនុតំបន់២០ ខ្ញុំបានណែនាំធ្វើសកម្មភាពត្រូវប្រយ័ត្នព្រោះសភាព-ការណ៍បែកហើយ ត្រូវក្តាប់សភាពការណ៍ឱ្យជាប់ហើយយុទ្ធវិធីដោះស្រាយតាមសភាពការណ៍ជាក់ស្តែងនៅតាមស្រុកនីមួយៗ។ នៅខែឧសភា ឆ្នាំ១៩៧៨ នេះខ្ញុំជាប់រៀបចំអង្គភាពដើម្បីឱ្យយួនដឹកនាំដោយលាយជាមួយកម្លាំងយួនរហូតដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៨ អង្គការបានចាប់ខ្លួនខ្ញុំតែម្តង។

**កំណត់ចំណាំ៖** អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D៤១៥៨១ និងឯកសារផ្សេងទៀតតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ គង់ ជាស៊ិន ហៅ សិន ពិតប្រាកដប៉ុណ្ណោះទេ យ៉ាងណានោះទេ។



កម្មាភិបាលខ្មែរក្រហមចុះទៅតាមសហករណ៍ អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គង់ គៀន ៖ លេខាធរសេនាតូច៦៣១

**មេក ទិន**



កងទ័ពបដិវត្តន៍ខ្មែរក្រហម នៅលើសមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គង់ គៀន ហៅ អ៊ុង វ៉េត ភេទប្រុស អាយុ២៨ឆ្នាំ មានទីកន្លែងកំណើតនៅភូមិវត្តស្វាយ ឃុំពាមខ្ទកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្ដាល។ គ្រួសារខ្ញុំប្រកបមុខរបរជាកសិករ។ នៅក្នុងវ័យ១៧ឆ្នាំ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៩ នៅសាលា ណយ យឹម។ បន្ទាប់មកខ្ញុំបានឈប់រៀនដើម្បីទៅធ្វើការស៊ីឈ្នួលនៅរោងចក្រទៀន (ហាង តៃ គួង) ភ្នំពេញ។ ក្រោយពីការងារនៅរោងចក្រទៀន ខ្ញុំបានទៅធ្វើការជាអ្នករត់តុនៅ ហាងលក់បាយ ហាងគុយទាវ និងរត់រឺម៉ក់។ ខ្ញុំធ្វើការស៊ីឈ្នួលនៅភ្នំពេញរហូតដល់មានរដ្ឋប្រហារកើតឡើងក្នុងឆ្នាំ១៩៧០ ទើបខ្ញុំត្រឡប់មកផ្ទះវិញ។ ពេលខ្ញុំមកដល់ផ្ទះបានប្រហែល១ខែ ឈ្មោះ ណារិន (អ្នកតស៊ូបង្កប់នៅសេនាធិការ) និង នារី លីន ដែលបង្កប់នៅក្នុងភូមិខ្ញុំបានមកអប់រំខ្ញុំឱ្យជួយការងារបដិវត្តន៍។ ក្រោយពេលអ្នកទាំងពីរត្រឡប់ទៅភ្នំពេញវិញ ឃើញមានទាហានចូលមកនៅក្នុងភូមិខ្ញុំតែម្ដង។ កាលនោះ ចៅហ្វាយស្រុកប្រចាំនៅបន្ទាយ ទឹកឃ្លាំងពាក់ស័ក្ដិបួន ហើយគាត់បានបង្កើតកងប្រជាចលនានៅក្នុងភូមិរបស់ខ្ញុំដែលមានមនុស្សសំខាន់ចំនួន៣រូបដឹកនាំផ្ទាល់នៅកងប្រជាចលនា រួមមាន លាង ហាក់, អំ និង ណាំ។

ក្រោយមកខ្ញុំបានចូលក្នុងកងប្រជាចលនាតាមរយៈឈ្មោះ អំ គឺជាអ្នកនាំខ្ញុំចូល។ ក្រោយពីនោះ ខ្ញុំមានកម្លាំងនៅក្នុងភូមិចំនួនប្រាំពីរនាក់ថែមទៀតចូលក្នុងកងប្រជាចលនាដែររួមមានប៊ិន, ឆុន, លន, លៀន,

ជិន, ជ័រ ហៅ សុវ៉ាន់ និង អឿន ហៅ សុផល។ បន្ទាប់ពីខ្ញុំបានចូលរួមក្នុងកងប្រជាចលនាហើយ មេដឹកនាំទាំងបី បានផ្តល់ភារកិច្ចឱ្យខ្ញុំធ្វើមានបីចំណុចគឺ៖ ទីមួយ) ការពារភូមិកុំឱ្យបដិវត្តន៍ចូល។ ទីពីរ) បំផុសប្រជាជនឱ្យគាំទ្រ លន់ នល់ ហើយប្រឆាំងនឹងបដិវត្តន៍។ ទីបី) ណែនាំប្រជាជន បើឃើញអ្នកបដិវត្តន៍ត្រូវរាយការណ៍ភ្លាមៗ។ ចំពោះអ្នកចូលរួមកងប្រជាចលនា ទទួលបានកាំភ្លើងកាប៊ីនមួយដើម និងប្រាក់ចំនួន៣០រៀលក្នុងមួយថ្ងៃ ប៉ុន្តែហូបបាយខ្លួនឯង។ កាលនោះ ខ្ញុំចូលបានមួយថ្ងៃឈ្មោះ អំ បានចាត់តាំងយើងទាំងប្រាំបីនាក់មកការពារនៅបន្ទាយទឹកឃ្លាំង។ ក្នុងរយៈពេលដែលខ្ញុំរស់នៅក្នុងបន្ទាយទឹកឃ្លាំង មេដឹកនាំកងប្រជាចលនាទាំងបីនាក់បានអប់រំខ្ញុំជាបន្តបន្ទាប់ឱ្យស្អប់បដិវត្តន៍ និងធ្វើសកម្មភាពប្រឆាំងបដិវត្តន៍តាមគ្រប់រូបភាពដែលអាចធ្វើទៅបាន។

ខ្ញុំធ្វើការនៅបន្ទាយទឹកឃ្លាំងបានរយៈពេល១៦ថ្ងៃ ខ្មែរក្រហមបានហៅខ្ញុំ រួមទាំង អឿន ហៅ សុផល, ជ័រ ហៅ សុវ៉ាន់ និង ជិនឱ្យត្រឡប់មកបង្កប់ខ្លួននៅក្នុងភូមិវិញ។ បន្ទាប់មក ខ្មែរក្រហមណែនាំខ្ញុំឱ្យទាក់ទងជាមួយខ្សែបដិវត្តន៍ដើម្បីចូលបង្កប់ជាមួយគ្នា។

នៅក្នុងឆ្នាំ១៩៧០ ខ្ញុំបានមកដល់តំបន់២៥ ដោយមានគ្នាចំនួនបីនាក់មាន អឿន ហៅ សុផល និង ជ័រ ហៅ សុវ៉ាន់ ក្នុងគម្រោងទៅជួប តាន់ ម៉េង ប៉ុន្តែយើងមិនបានជួបទេ។ ដូច្នេះ យើងទាំងបីនាក់បានពិភាក្សាគ្នាក្នុងការសម្រេចឱ្យ ជ័រ ហៅ សុវ៉ាន់ ទៅរាយការណ៍ប្រាប់ លាង ហាក់ អំពីបញ្ហាមិនជួប តាន់ ម៉េង។ នៅក្នុងឆ្នាំ១៩៧០ដដែល តាន់ ម៉េង បានមកនៅតំបន់៣៣ ចំណែកខ្ញុំអង្គការឱ្យទៅនៅក្នុងកង១៨ ដែលមាន តាន់ ម៉េង ជាអ្នកដឹកនាំ រីឯ អឿន ហៅ សុផល អង្គការបញ្ជូនឱ្យទៅលើ។ ខ្ញុំរស់នៅក្នុងកង១៨នេះរហូតដល់ឆ្នាំ១៩៧១។ ខ្ញុំបានជួបជាមួយ តាន់ ម៉េង ហើយនៅពេលដែលស្គាល់ចិត្តគ្នា ខ្ញុំបានរាយការណ៍ប្រាប់ពីការណែនាំរបស់ លាង ហាក់។ តាន់ ម៉េង ចាប់ផ្តើមទទួលស្គាល់ខ្ញុំ ហើយអប់រំខ្ញុំជាបន្តបន្ទាប់ឱ្យខ្ញុំចេះជួយ លាក់ការណ៍បំផុសប្រជាជន ប្រាប់ប្រជាជនឱ្យធ្វើសកម្មភាពនៅក្នុងបដិវត្តន៍ និងចាត់តាំងខ្ញុំឱ្យនៅការពារគាត់។ មួយរយៈក្រោយមក អង្គការបានដក ហាក់ និង រិនឱ្យទៅអង្គភាពថ្មី ដូច្នេះការទំនាក់ទំនងគ្នាបានដាច់រហូត។ រហូតដល់ឆ្នាំ១៩៧២ ខ្ញុំបានទៅកាន់កង១០៤ ហើយទទួលការអប់រំពីឈ្មោះ សំ ជាប់ជាប្រចាំ ព្រមទាំងអនុវត្តផែនការ និងសកម្មភាពក្រោមការគ្រប់គ្រងរបស់គាត់ផ្ទាល់។ ផែនការដែលខ្ញុំទទួលបានពី សំ រួមមាន៖ ទីមួយ) បំផុសប្រជាជនឱ្យមានជំទាស់ជាមួយអង្គការបដិវត្តន៍។ ទីពីរ) សម្ភារដែលយកបាន ត្រូវលាក់ទុក។ ទីបី) ធ្វើសកម្មភាពយ៉ាងណាកុំឱ្យអង្គការចាប់អារម្មណ៍។ ខ្សែរយៈរបស់ សំ មានគ្នាចំនួន១៦នាក់។

នៅឆ្នាំ១៩៧៣ សំ បានហៅខ្ញុំរួមទាំង គៀន, ទូច, ចិន មកប្រជុំនៅវត្តស្រះស្រង់នៅវេលាម៉ោង៧ព្រឹក ដែលមានខ្លឹមសារដូចតទៅ៖ ដកសម្ភាររបស់ប្រជាជនជម្លៀស ដើម្បីឱ្យប្រជាជនមានជម្លោះជាមួយអង្គការ រួចហើយយកទៅលាក់ទុកនៅតាមអង្គភាព។ ដល់ឆ្នាំ១៩៧៤ ខ្ញុំបានផ្លាស់មកកងពលទី៣ ក្នុងនោះមាន សំ គឺជាលេខាអនុសេនាធំ១៦៤ និង វិត, ថន រួមទាំង កុល។ ក្រោយមកឮថាអង្គការបានចាប់ សំ។ នៅឆ្នាំ១៩៧៥ ពេលអង្គភាពវាយនៅសមរភូមិទួលលាប ឈ្មោះ ស្រស់ បានចាត់តាំងខ្ញុំឱ្យទៅប្រាប់ សារី, ហន និង ឈឿន មិនឱ្យចូលប្រយុទ្ធទេ គឺឱ្យតែកងទ័ពចូលបានហើយ ដើម្បីការពារខ្សែកុំឱ្យមានគ្រោះថ្នាក់។ អំឡុងពេលវាយប្រយុទ្ធ ខ្ញុំត្រូវរបួស ពេលដែលទាហានវាយបុកយកបន្ទាយទួល១៥។ រហូតដល់ឆ្នាំ១៩៧៦ ការទំនាក់ទំនងខ្សែកាន់តែមានភាពមមាញឹក និងការប្រជុំកម្លាំងបានធ្វើច្រើនដងដើម្បីបង្កើនសមាជិកបន្ថែម។ ឈ្មោះ សារី តែងតែហៅប្រជុំជាប់ជានិច្ច។ ថ្ងៃមួយ សារី បានហៅខ្ញុំរួមទាំង ហន, អ៊ួច, ឈឿន និង ឈឿ មកប្រជុំទាក់ទងខ្លឹមសាររៀបចំផែនការឱ្យគ្រប់មុខសញ្ញា ទុកអនុវត្តកាលណាមានបញ្ហា ដូចជាធ្វើរដ្ឋប្រហារដើម្បីក្តាប់រដ្ឋអំណាច។ ភ្លាមៗនោះ ខ្ញុំបានសួរថា«តើមានកម្លាំងប៉ុន្មាននាក់ហើយក្នុងការត្រៀមធ្វើរដ្ឋប្រហារនេះ»?



កងទ័ពបដិវត្តន៍ខ្មែរក្រហម នៅលើសមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពេលនោះ សារី បានឆ្លើយតបថា «មិនខ្វះទេកម្លាំង»។ ប៉ុន្តែពេលនោះ សារី មិនបានប្រាប់ឈ្មោះទេ។ បន្តមកទៀត សារី បានណែនាំថា ឱ្យតែយើងខិតខំប្រឹងទៅមានហើយកម្លាំង ប៉ុន្តែសំខាន់នៅខ្វះតែកម្លាំងទ័ព។ ចំណែកឯវិធីធ្វើរដ្ឋប្រហារ គឺយើងដកបុទម្នាក់ចេញ ហើយប្រកាសចាត់តាំងខ្សែរបស់យើងឱ្យគ្រប់គ្រងកងពលតែម្តង។ ពេលនោះ ឈឿន បានសួរ សារី ថាតើគោលការណ៍ធ្វើរដ្ឋប្រហារនៅថ្ងៃណា? សារី បានប្រាប់ថា កុំទាន់ចង់ដឹង គ្រាន់តែត្រៀមកម្លាំងឱ្យរួចរាល់ទៅបានហើយ ពេលណាធ្វើបាន ចាំគេប្រាប់។ ក្រោយពីបានជួបប្រជុំគ្នាជាច្រើនដងមក យើងចាប់ផ្តើមចេញធ្វើការទៅតាមផែនការរៀងៗខ្លួនរហូតដល់ថ្ងៃទី៤ ខែមេសា ទើបត្រឡប់មកជួបជុំគ្នាវិញ។ ពេលនោះខ្ញុំបានទៅជួប សារី នៅផ្ទះរបស់ សារី ដោយមុនដំបូងយើងសួរសុខទុក្ខគ្នាធម្មតា។ នៅចុងបញ្ចប់ការប្រជុំទើប សារី កំណត់ថ្ងៃជួបជុំគ្នាសាជាថ្មី ដោយកំណត់យកថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៧។ ក្នុងថ្ងៃទី៥ ខែមេសា ខ្ញុំត្រូវបានអង្គការចាប់ខ្លួន។ កម្លាំងក្បត់នៅក្នុងបក្សរបស់យើងមានចំនួនសរុប៦៥នាក់។

**កំណត់ចំណាំ៖** អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J០០៣០០ តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និង ធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ គង់ គៀន ហៅ អ៊ីង វ៉ែត ពិតប្រាកដបុយ៉ាងណានោះទេ។

# គង់ ប៊ុនលិន ៖ ប្រធានរោងពុម្ព ភូមិភាគឦសាន

នេន ស្រីមុំ



រោងពុម្ពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាយប់ម៉ោង៩ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៦៧ ជាពេលវេលាដែល គង់ប៊ុនលិនបានស្ម័គ្រចិត្តបម្រើការងារនៅក្នុងកម្លាំង សេ-អ៊ី-អា តាមរយៈការខ្ទេសនាមពីឈ្មោះ យោង (ជាគ្រូបង្រៀនថ្នាក់ទី១) និងប្រពន្ធរបស់យោង។ យោង បានធ្វើការប្រកាសបើកកម្មវិធីខ្ទេសនាមដោយការគោរពទង់ជាតិ សេ-អ៊ី-អា និងបានខ្ទេសនាមសកម្មភាពសំខាន់ៗ ព្រមទាំងលើកភារកិច្ចចំនួនពាគឺ ខិតខំកសាងកម្លាំងឱ្យបានច្រើន, តាមដានក្តាប់ឱ្យបាននូវកម្លាំងបដិវត្តន៍របស់ខ្មែរក្រហម និងរក្សាការសម្ងាត់របស់ក្រុម។ បន្ទាប់ពីនោះ ប៊ុនលិនបានប្តេជ្ញាចិត្តចំពោះភាពស្មោះត្រង់ និងស្ម័គ្រចិត្តបម្រើសេ-អ៊ី-អាអស់មួយជីវិតហើយ យោង បានប្រកាសគោរពទង់ជាតិមុនបិទកម្មវិធី។

គង់ ប៊ុនលិន ហៅ អុន ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិបុសលាវ ឃុំបុសលាវ ស្រុកក្រចេះ ខេត្តក្រចេះ។ ប៊ុនលិន មានឪពុកឈ្មោះ គង់ គិន ម្តាយឈ្មោះ អោ អឿន។ ប៊ុនលិន មានប្រពន្ធឈ្មោះ ចាន់ ហឿ ហៅ សំ មានទីកន្លែងកំណើតនៅភូមិ ហាងខូបាន សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ ប៊ុនលិន និងប្រពន្ធមានកូនប្រុសម្នាក់។

ប៊ុនលិន មានភារកិច្ចក្តាប់កម្លាំងបដិវត្តន៍ និងកសាងកម្លាំង។ ចាប់ពីពេលចូលរួមជាមួយ សេ-អ៊ី-អា គាត់ខិតខំធ្វើសកម្មភាពកសាងកម្លាំងជាប់ជានិច្ច និងកសាងកម្លាំងបានចំនួនពីរនាក់ គឺឈ្មោះ រឿង គឹមធន់ និង ម៉ុងគ្រី ហៅ ចាប់។ នៅពាក់កណ្ដាលឆ្នាំ១៩៦៧ ប៊ុនលិន បានប្រឡងជាប់មធ្យមសិក្សាប័ត្រភាគទី១ នឹងត្រូវទៅរៀននៅវិទ្យាល័យកំពង់ចាម។ គាត់ទទួលបានសំបុត្រពីប្រពន្ធរបស់ យោង ឱ្យគាត់ទៅជួប និងទាក់ទងជាមួយឈ្មោះ ស៊ុវ៉ាន គឺជាគ្រូបង្រៀននៅវិទ្យាល័យកំពង់ចាម។ នៅចុងឆ្នាំ១៩៦៧ ទើប ប៊ុនលិន អាចទាក់ទងជាមួយគ្រូ ស៊ុវ៉ាន់ បន្ទាប់មកបានណែនាំកម្លាំងជាច្រើនឱ្យគាត់បានស្គាល់ មានទាំងសាស្ត្រាចារ្យ និងសិស្ស-និស្សិត។

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧០ សមាជិក សេ-អ៊ី-អា ចំនួន៨នាក់ មានឈ្មោះ ប៊ុនលិន, ម៉ាត់ សារូ, ម៉ុង គ្រី, ដាវ, សន, រឿង គឹមធន់ និង ភាព បានចូលរួមក្នុងបដិវត្តន៍ខ្មែរក្រហម នៅភូមិរកាកណ្ដាល ស្រុកក្រចេះ ខេត្តក្រចេះ។ ក្រោយមកនៅចុងខែកក្កដា ឆ្នាំ១៩៧០អ្នកទាំងអស់បានចេញដំណើរពីខេត្តក្រចេះ ទៅខេត្តរតនគិរី និងបានជួបជាមួយ យោង នៅមន្ទីរនីរសារភូមិភាគ ដើម្បីពិភាក្សាពីការចាប់ផ្ដើមធ្វើសកម្មភាពឡើងវិញ ព្រមទាំងណែនាំឱ្យស្គាល់ខ្សែបណ្ដាញចំនួន២នាក់ មានឈ្មោះ គឹម និងឈ្មោះ កុំ។ នៅពេលនោះ អ្នកទាំងអស់មានតួនាទីធ្វើចម្ការនៅក្នុងមន្ទីរនីរសារ។ នៅចុងខែសីហា ឆ្នាំ១៩៧០អង្គការបានដកអ្នកទាំងអស់នោះឱ្យទៅធ្វើជាអ្នកដាំបាយនៅសាលាវគ្គ។ មានយប់មួយ គឹម បានហៅសមាជិកចំនួន៨នាក់ ទៅប្រជុំ ក្នុងនោះមាន ប៊ុនលិន ម្នាក់ដែរ។ គឹម បានអប់រំឱ្យសមាជិកធ្វើយ៉ាងណាត្រូវតែរក្សាការសម្ងាត់ឱ្យបានល្អ ទាក់ទងសកម្មភាពបង្កប់ស៊ីរូងនៅក្នុងជួរបដិវត្តន៍។

នៅដើមឆ្នាំ១៩៧១ អង្គការបានបំបែកសមាជិក សេ-អ៊ី-អា ទាំងអស់ ឱ្យទៅធ្វើការងារនៅកន្លែងផ្សេងៗគ្នា។ គឹម ត្រូវដកឱ្យទៅធ្វើការងារនៅកន្លែងផ្សេង, ប៊ុនលិន និង សារូ ទៅធ្វើការងារនៅពេទ្យពុម្ព ហើយនៅពេលនោះជាពេលដែលខ្មែរក្រហមបានចាត់តាំង ប៊ុនលិនឱ្យធ្វើជាប្រធានពេទ្យពុម្ព, ភាព, ដាវ ព្រមទាំង អន ទៅធ្វើការងារនៅមន្ទីរសេនាធិការ, ចំណែក សន ទៅធ្វើការងារនៅមន្ទីរពេទ្យព-២, រីឯ ម៉ុងគ្រី និង រឿង គឹមធន់ ទៅធ្វើការងារនៅមន្ទីរទូរលេខ។ នៅខែមីនា ឆ្នាំ១៩៧១ ភាព និង ដាវ បានអប់រំឈ្មោះ អន គឺជាយុទ្ធជននៅមន្ទីរសេនាធិការ។ នៅខែមិថុនា ឆ្នាំ១៩៧១ អង្គការបានបើកវគ្គយុវជនមន្ទីរ ប៊ុនលិន, សារូ, ម៉ុងគ្រី, គឹមធន់, ដាវ, ភាព, សន និង អនបានចូលរួមសិក្សាវគ្គយុវជនមន្ទីរ ទាំងអស់គ្នា។ ប៊ុនលិន និងសមាជិកទាំងអស់ បានបន្តធ្វើសកម្មភាពកសាងកម្លាំង និងតាមដានពីសកម្មភាពព្រមទាំងទីតាំងរបស់ខ្មែរក្រហម។

នៅដើមឆ្នាំ១៩៧៥ សភាពការណ៍ស្មុគស្មាញកាន់តែខ្លាំងឡើងៗ។ សើយ បាននាំយោធាស្រុកមួយកងអនុសេនាតូចរត់ចូលព្រៃ, ចំណែកថងដាំ និងថងបែ ចាប់និងបំផុសយុវជន-យុវនារី ព្រមទាំងប្រជាជនរស់នៅភូមិពង់, ភូមិហ្វាំង(តំបន់១០២), ភូមិថ្មី, ភូមិរើនសែ និងភូមិប៉ាកកាឡាន់ (តំបន់១០១) រត់ចូលព្រៃទិសទៅប្រទេសវៀតណាម។ នៅពេលទៅដល់ប្រទេស វៀតណាម ថងដាំ មានបំណងរៀបចំកងទ័ពរួមផ្សំជាមួយកងទ័ពវៀតណាម ចូលមករំដោះខេត្តរតនគិរី និងខេត្តស្ទឹងត្រែង។ ទន្ទឹមនោះ ថងដាំ បានណែនាំ ប៊ុនលិនឱ្យទាក់ទងជាមួយ ចាន់ថា ឱ្យបានដើម្បីធ្វើសកម្មភាព។ សកម្មភាពរបស់ក្រុម សេ-អ៊ី-អា គឺនៅបន្តមកជាប់ជានិច្ច ហើយកសាងកម្លាំងថ្មីមកជាបន្តបន្ទាប់។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ អង្គការបានដក ប៊ុនលិនចេញពីពេទ្យពុម្ពឱ្យទៅធ្វើការងារនៅតំបន់១០៤។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ប៊ុនលិនបានជួបជាមួយ សឹម, បូវ៉ាន់ និង ញឹម នៅមាត់ទន្លេជិតមន្ទីរអកមាស ដើម្បីរាយការណ៍ពីសមិទ្ធផលដែលសម្រេចបាន និងលើកឡើងពីផែនការថ្មីដែលត្រូវអនុវត្តនៅពេលបន្ទាប់។ នៅខែសីហា ឆ្នាំ១៩៧៦ ប៊ុនលិនបានជួបជាមួយ អន និង សឹម។ អ្នកទាំងពីរត្រូវបានអង្គការចាត់តាំងឱ្យមកចូលរួមវគ្គសិក្សានៅតំបន់ពន្ធុង។ បន្ទាប់ពី

ជួបជុំគ្នា អ្នកទាំងអស់បានរាយការណ៍ស្ថានភាពកម្លាំង និងប្រជាជននៅទីតាំងរៀងៗខ្លួន។ សឹម បានរាយការណ៍ថាប្រជាជននៅទីតាំងរបស់គាត់ចង់នៅធ្វើចម្ការជាងធ្វើស្រែដែលអង្គការចាត់តាំងឱ្យទៅ។ ប្រជាជនទាំងនោះបានលើកឡើងថា ប្រសិនជាអង្គការបង្ខំឱ្យទៅធ្វើស្រែអ្នកទាំងនោះនឹងនាំគ្នារត់ចូលទៅប្រទេសវៀតណាម។ ចំណែក អន បានរាយការណ៍ថាគាត់កំពុងធ្វើសកម្មភាពរារាំងចលនាធ្វើស្រែឱ្យបានទិន្នផលចំនួន៣តោន និង ៦តោន។ អន ព្យាយាមបំផុសយុវជន-យុវនារី ក្នុងកងចល័តឱ្យខ្ជិលច្រអូស ស្ពឹកស្រពន់មិនធ្វើការងារ។ ក្រៅពីបំផុសយុវជន អន បានកសាងកម្លាំងថ្មីបានម្នាក់ឈ្មោះ ខាំបន គឺជាអ្នកទទួលបន្ទុកខាងបច្ចេកទេសទ្វារទឹក នៅអូរតាង។ បន្ថែមពីនោះ ប៊ុនលិន បានរាយការណ៍ប្រាប់អ្នកទាំង២នាក់នោះដែរអំពីសភាពការណ៍របស់ប្រជាជននៅ៤២ តំបន់១០៤ ដែលរង់ចាំការចូលរំដោះពីសំណាក់កងទ័ពរបស់ ចាន់ថា។

នៅខែមករា ឆ្នាំ១៩៧៧ ប៊ុនលិន បានជួបជាមួយ អន និង ខាំបន នៅទំនប់អូរតាង និងបានរាយការណ៍ពីសកម្មភាព និងព្រឹត្តិការណ៍នៅក្នុងតំបន់ដែលខ្លួនរស់នៅ។ នៅខែឧសភា ឆ្នាំ១៩៧៧ អង្គការបានដក ប៊ុនលិនឱ្យធ្វើការងារនៅតំបន់១០៧។ ពេលទៅដល់ទីនោះ គាត់ព្យាយាមទាក់ទងខ្សែបណ្ដាញដើម្បីចេញទៅប្រទេសវៀតណាម ប៉ុន្តែគាត់មិនអាចទាក់ទងនរណាម្នាក់បានឡើយ។ ចាប់តាំងពីពេលនោះមក សមាជិកក្រុមទាំងអស់បានទាក់ទងទៅខ្សែបណ្ដាញនៅវៀតណាម រហូតដល់ខែសីហា ទើប វ៉ាង អាចទាក់ទងខាងវៀតណាមបាន។ ក្រោយពីទទួលបានដំណឹងថា វ៉ាង អាចទាក់ទងជាមួយខាងវៀតណាមបាន ប៊ុនលិនបានសរសេរសំបុត្រមួយច្បាប់ផ្ដល់ដំណឹងឱ្យ សឹម ដឹងពីព័ត៌មាននោះ។

ប៊ុនលិន និង វ៉ាង បានជួបគ្នាដើម្បីពិភាក្សាពីផែនការដែលត្រូវធ្វើសកម្មភាពនៅពេលបន្ទាប់។ នៅក្នុងខ្លឹមសារប្រជុំ វៀតណាមបានដាក់ផែនការចំនួន៤ចំណុចឱ្យ ប៊ុនលិនស្វែងរក ទី១) ទីកន្លែងដែលខ្មែរក្រហមបោះទីតាំងទ័ព, ចំនួនកម្លាំង និងប្រភេទអាវុធ។ ទី២) ស្វែងរកទីតាំងឃ្លាំងអាវុធ។ ទី៣) រកទីតាំងជង្រុកស្រូវ និងទី៤) ទីកន្លែងដែលមានប្រជាជនច្រើន។ ក្រោយពីបញ្ចប់ការជួបជុំ ប៊ុនលិន បានយកផែនការនោះទៅអនុវត្ត និងបានចាត់តាំងឱ្យសមាជិកដទៃទៀតជួយស្វែងរកបន្ថែម។ សកម្មភាពនៃការស្វែងរកទីតាំងធំរបស់ខ្មែរក្រហម គឺជាប់មកជានិច្ច ប៉ុន្តែសមាជិកទាំងអស់មិនភ្លេចពីភារកិច្ចក្នុងការកសាងកម្លាំងថ្មីបន្ថែមនោះទេ។ បន្ថែមពីនោះទៀតអ្នកទាំងនោះបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការជួយរំដោះប្រជាជនពីសំណាក់វៀតណាម។

នៅខែមករា ឆ្នាំ១៩៧៨ ប៊ុនលិន និងសមាជិកបានធ្វើសកម្មភាពរារាំងចលនារបស់បដិវត្តន៍ជាបន្តបន្ទាប់។ សកម្មភាពធ្វើការងាររបស់យុវជន-យុវនារីកាន់តែមានភាពយឺតយ៉ាវ ស្ពឹកស្រពន់ និងមានសកម្មភាពខុសសីលធម៌ជាហូរហែ។ ប៊ុនលិន ខិតខំព្យាយាមបំផុសប្រជាជន និងកសាងកម្លាំងប្រឆាំងនឹងបដិវត្តន៍ខ្មែរក្រហម ប៉ុន្តែគាត់មិនបានគិតឃើញទេថាខ្មែរក្រហមបានតាមដានពីសកម្មភាពរបស់គាត់ដូចគ្នា។ គង់ ប៊ុនលិន ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧៨ នៅទីក្រុងភ្នំពេញ។

**កំណត់ចំណាំ៖** អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J00៥០៨ និងឯកសារផ្សេងទៀតតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ គង់ ប៊ុនលិន ពិតប្រាកដបុ យ៉ាងណានោះទេ។

# មុត សុន ហៅ វណ្ណៈ ត្រូវចាប់ខ្លួនដោយសារបំផុសឱ្យយុវជនប្រឆាំងនឹងអង្គការបដិវត្តន៍

ឌីម សុខគា



*ប្រជាជននៅតាមសហករណ៍ និងកម្មាភិបាលខ្មែរក្រហម កំពុងប្រមូលផលស្រូវ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ឯកសារចម្លើយសារភាពសរសេរដោយដៃចំនួន ២៣ទំព័ររបស់ មុត សុន ហៅ វណ្ណៈ មុនអង្គការចាប់ខ្លួន មានតួនាទីយុទ្ធជនមន្ទីរក១១។ តាមរយៈចម្លើយសារភាពនៅក្នុងឯកសារ J00១៩៥ បង្ហាញអំពីសកម្មភាពឈ្មោះ វណ្ណៈ ចូលបម្រើក្នុងជួរបដិវត្តន៍តាមការណែនាំពីឈ្មោះ ចាន់និងទទួលស្គាល់ដោយឈ្មោះ តូនីម។ វណ្ណៈ បានជាប់ពាក់ព័ន្ធជាមួយមនុស្សចំនួន ៧៣នាក់ ដោយធ្វើផែនការបំផុសឱ្យយុវជនប្រឆាំងនឹងអង្គការបដិវត្តន៍។ រហូតមកដល់ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៧ វណ្ណៈ ត្រូវបានអង្គការចាប់ខ្លួន។ នៅក្នុងអត្ថបទនេះ យើងឃើញមានការចុះហត្ថលេខា និងឈ្មោះអ្នកសួរចម្លើយជាកម្មាភិបាលខ្មែរក្រហម រួមទាំងការចុះហត្ថលេខា សាមីខ្លួន និងបានកត់ត្រា កាលបរិច្ឆេទនៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៧ ។ ខាងក្រោមនេះ ជាចម្លើយសារភាពរបស់ មុត សុន ហៅ វណ្ណៈ ៖

**មុត សុន** ហៅក្រៅ វណ្ណៈ ភេទប្រុស អាយុ២៣ឆ្នាំ (ក្នុងឆ្នាំ១៩៧៧) ជនជាតិខ្មែរ នៅលីវ មានស្រុកកំណើតនៅភូមិព្រៃផ្តៅ ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ តាំងពីធំដឹងក្តីមក វណ្ណៈ រស់នៅជាមួយឪពុកម្តាយ និងប្រកបមុខរបរធ្វើស្រែចម្ការ។

នៅចន្លោះពីឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧៣ វណ្ណៈ ស្នើសុំអង្គការចូលធ្វើកងឈ្លប (យោធា) នៅភូមិព្រៃផ្ដៅ។ ពេលនោះ អង្គការចាត់តាំង វណ្ណៈ ឱ្យទៅនៅស្នាក់ការសែងយុទ្ធជនរងរបួស នៅវរសេនាតូច១១១ វរសេនាធំ១៥២ ភូមិភាគពិសេស។ រយៈពេលមួយខែ អង្គការបញ្ជូនវណ្ណៈ ទៅនៅអង្គភាពយោធាអនុសេនាធំ១១ វរសេនាតូច១១១ វរសេនាធំ១៥២។ បន្ទាប់មក វណ្ណៈ បានឡើងទៅវាយជាមួយខ្មាំង នៅសមរភូមិវត្តស្វែង (ខាងត្បូងព្រៃសរ) ហើយបានត្រូវគ្រាប់បណ្ដាលឱ្យរងរបួស។ អង្គភាពយោធាបានបញ្ជូនវណ្ណៈ ទៅព្យាបាលនៅមន្ទីរពេទ្យឃុំក្រាំងយ៉ូវ ស្រុក២០ (ស្រុកស្អាង) តំបន់២៥ ខេត្តកណ្ដាល។ វណ្ណៈ នៅព្យាបាលរបួសរយៈពេល២៨ថ្ងៃ ទើបត្រឡប់មកអង្គភាពវិញ។ ស្របពេលជាមួយគ្នានោះ វណ្ណៈ បានសុំអង្គភាពមកលេងផ្ទះនៅពេលដែលឪពុករបស់គាត់ស្លាប់ ហើយម្ដាយរបស់គាត់បានឃាត់គាត់ឱ្យនៅជួយធ្វើស្រែនៅស្រុកកំណើត។ នៅវេលាយប់មួយ វណ្ណៈ បានទៅចូលរួមពិធីបុណ្យមីទ្ទីញនៅវត្តព្រៃផ្ដៅ និងបានជួបមនុស្សចំនួន៨នាក់ ដែលនៅស្នាក់ការសែងរបួសវរសេនាតូច១១១វរសេនាធំ១៥២ភូមិភាគពិសេសជាមួយគ្នា។ ក្រោយមក អង្គភាពមកហៅ និងបញ្ជូនវណ្ណៈ ទៅអង្គភាពយោធា អនុសេនាធំ១១ វរសេនាតូច១១១ វរសេនាធំ១៥២ វិញ។ នៅពេលនោះ វណ្ណៈ បានទាក់ទងជាមួយឈ្មោះ អ៊ូ ទង និងឈ្មោះ ស៊ុំ អតីតប៉ូលីសនៅខេត្តស្វាយរៀងមានស្រុកកំណើតនៅភូមិព្រៃផ្ដៅ ឃុំព្រៃផ្ដៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ រយៈពេល៥ថ្ងៃក្រោយមក វណ្ណៈ និងមនុស្សចំនួន៦នាក់ទៀត ត្រូវអង្គភាពបញ្ជូនទៅដាក់នៅមន្ទីរ១៣។ រំលងបានមួយសប្ដាហ៍អង្គភាពបញ្ជូនវណ្ណៈ បន្តទៅដាក់នៅមន្ទីរស្រុក៥៥ តំបន់៣៣ ខេត្តកណ្ដាល មួយរយៈពេលខ្លី ទើបត្រឡប់មកនៅភូមិវិញ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៣ តាមរយៈឈ្មោះ ចាន់ មានតួនាទីជាប្រធានក្រុម នៅវរសេនាតូច១១១ វរសេនាធំ១៥២ ភូមិភាគពិសេស បានប្រគល់ វណ្ណៈ និងមនុស្សចំនួន៨នាក់ទៀតឱ្យឈ្មោះ តូ នឹម ជាអ្នកដឹកនាំ និងអប់រំកុំឱ្យរត់ចោលអង្គភាព។ រយៈពេល៥ទៅ៦ថ្ងៃក្រោយមក មានការវាយខ្មាំងនៅសមរភូមិព្រះធាតុ (ផ្លូវជាតិ៣៨)។ ពេលនោះ តូនឹម ហៅ វណ្ណៈ និងមនុស្សចំនួន៤នាក់ខាងលើទៅប្រជុំនៅខាងលិចភូមិកោះខ្នុរឱ្យស្គាល់មនុស្ស១២នាក់ទៀតដែលធ្វើការនៅក្នុងអង្គភាពជាមួយគ្នា។ អ្នកទាំងនោះណែនាំវណ្ណៈ និងសមាជិកឱ្យលាក់ការណ៍ និងចូលបង្កប់ខ្លួនក្នុងជួរកងទ័ពដើម្បីធ្វើសកម្មភាពបំផុសឱ្យយុវជនប្រឆាំងនឹងបដិវត្តន៍។ ក្រោយមក តាមរយៈឈ្មោះ សាវុត មានតួនាទីជាអនុលេខាអង្គភាពយោធា១១ បានចាត់តាំងវណ្ណៈ ឱ្យធ្វើជានីរសាររបស់ខ្លួនតាមរយៈការងារបដិវត្តន៍ និងការងារសង្កាត់។

នៅដើមឆ្នាំ១៩៧៤ សាវុត កសាងកម្លាំងបានចំនួន៤នាក់ និងបានរាយការណ៍ឈ្មោះទាំង៤នេះ ទៅឱ្យឈ្មោះ តូនឹម ហើយ តូនឹម បានផ្ញើសំបុត្រមួយច្បាប់ឱ្យ សាវុត វិញតាមរយៈ វណ្ណៈ។ វណ្ណៈ បានលួចបើកមើលសំបុត្រដែលមានខ្លឹមសារថា«ឱ្យបង សាវុត ខិតខំកសាងកម្លាំង ព្រោះផែនការនេះគឺ បងសោម ប្រធានវរសេនាធំ១៥២» គឺជាអ្នកកំណត់។ បន្ទាប់ពី វណ្ណៈ អានសំបុត្រចប់ ទើបយកទៅប្រគល់ដល់ដៃ សាវុត។ នៅខែកុម្ភៈ ឆ្នាំ១៩៧៤ វណ្ណៈ បានជួបមនុស្ស៤នាក់ខាងលើ និងទទួលបានការអប់រំពីឈ្មោះ តូនឹម ដូចគ្នាដែរ។ ក្នុងចំណោមអ្នកទាំង៤នោះតូនឹមចាត់តាំងឈ្មោះ គ្រី មានតួនាទីជាអនុក្រុម ឱ្យទៅនៅស្នាក់ការសែងអ្នករបួសជាមួយ អ៊ូ ទង។ នៅខែមេសា ឆ្នាំ១៩៧៤ តូនឹម និងវណ្ណៈ ឡើងទៅវាយជាមួយខ្មាំងនៅសមរភូមិដីក្រហម (ផ្លូវលេខ៣៨)។ លុះនៅខែឧសភា ឆ្នាំ១៩៧៤ តូនឹម និង វណ្ណៈ បានធ្វើសកម្មភាពបំផុសយុវជនកុំឱ្យជឿបដិវត្តន៍ទៀត ហើយកិច្ចការនេះ វណ្ណៈ និងមនុស្ស៣នាក់ទៀតគឺជាអ្នកទទួលខុសត្រូវ។ ក្រោយមកតាមរយៈ ឈ្មោះ ប៉ុនបានណែនាំ វណ្ណៈ ឱ្យខិតខំលាក់ការណ៍សម្ងាត់ទាក់ទងកិច្ចការងារនៅតាមសមរភូមិមុខ និងសមរភូមិក្រោយ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៤ អង្គភាពយោធាបានចាត់តាំង វណ្ណៈ ជាប្រធានកងឈ្លបដឹកនាំអង្គភាពឈ្លបទៅត្រៀមនៅកោះភ្នៅ ក្នុងស្រុកស្អាង

ខេត្តកណ្ដាល ហើយពេលនោះ វណ្ណៈ ក្ដាប់បានយុវជនកងឈ្លបចំនួន៤នាក់ដែលមានទស្សនមិនពេញចិត្តនឹងបដិវត្តន៍។ បន្ទាប់មក វណ្ណៈ បំផុសឱ្យយុវជនទាំងនោះឃើញពីទុក្ខលំបាកថែមទាំងលើកទឹកចិត្តឱ្យយុវជនខិតខំធ្វើការ និងត្រៀមធ្វើសកម្មភាពបំផុសក្នុងអង្គភាពនៅភូមិធ្លកយល់, ភូមិយមពន្លៃក្នុងស្រុក៥៥ តំបន់៣៣ ប៉ុន្តែមិនទាន់ចេញជាលទ្ធផលឡើយ។

ក្រោយថ្ងៃរំដោះ ទី១៧ ខែមេសា ឆ្នាំ១៩៧៥ រយៈពេល២ថ្ងៃ អង្គភាពយោធាបានដកកងឈ្លបមួយចំនួនចេញ ដោយទុកត្រឹមតែ១២នាក់តែប៉ុណ្ណោះ។ អ្នកឯទៀតត្រូវបញ្ជូនត្រឡប់មកឃុំព្រៃផ្ដៅវិញ។ ចំណែក វណ្ណៈ ត្រូវអង្គការចាត់តាំងឱ្យធ្វើជាប្រធានកងឈ្លប និងរស់នៅជាមួយមនុស្សចំនួន៣នាក់ទៀត។ នៅចុងខែកក្កដា ឆ្នាំ១៩៧៥ ឈ្មោះ យឿ ដែលជាខ្មែរចាស់ធ្វើការនៅស្នាក់ការសែងរបួសវរសេនាតូច១១១ វរសេនាធំ១៥២ បានទទួលសំបុត្រពីឈ្មោះ តូនីម ផ្ញើមកឱ្យ វណ្ណៈ ដើម្បីបញ្ជូនបន្តទៅកាន់មនុស្សចំនួន៣នាក់ទៀត ដោយសំបុត្រទី១ ជូនចំពោះបង ប៉ុន មានខ្លឹមសារថា «សូមរាយការណ៍ពី សមមិត្ត តូនីម អំពីកម្លាំងដែលកសាងបាននៅក្នុងស្រុក៥៥ តំបន់៣៣ មានចំនួន៥នាក់», សំបុត្រទី២ ជូនចំពោះបង ស្រី ហ៊ឹម មានខ្លឹមសារដូចតទៅ «ពីសមមិត្ត តូនីម បង្ហាញអំពីកម្លាំងដែលអប់រំបាន នៅស្រុក៥៦ តំបន់៣៣ មានចំនួន៤នាក់ និងសំបុត្រទី៣ ជូនចំពោះបង ហ៊ិត ដែលអត្ថន័យក្នុងសំបុត្របង្ហាញអំពីកម្លាំងដែលកសាងបាននៅស្រុក៥៤ តំបន់៣៣ មានចំនួន៤នាក់។

នៅខែតុលា ឆ្នាំ១៩៧៥ អង្គការដក វណ្ណៈ, យុវជន និងយុវនារី នៅក្នុងស្រុក៥៥ តំបន់៣៣ ខេត្តកណ្ដាល មួយចំនួន ដើម្បីបញ្ជូនទៅធ្វើកម្មកររោងចក្រនៅមន្ទីរស្រុក៥៥។ នៅពេលនោះ ប៉ុន បានដាក់ផែនការ និងបញ្ជូន វណ្ណៈ និងមនុស្សចំនួន៣នាក់ឱ្យចូលបង្កប់ខ្លួនក្នុងជួរយុវជន និងយុវនារី មន្ទីរស្រុក៥៥។ អ្នកទាំងនោះត្រូវធ្វើសកម្មភាពកសាងកម្លាំង និងបំផ្លិចបំផ្លាញគ្រឿងម៉ាស៊ីនរោងចក្រ ដើម្បីកុំឱ្យបដិវត្តន៍ជឿនលឿនទៅមុខ។ ក្រោយមក វណ្ណៈ រួមទាំងមនុស្សចំនួន៣នាក់ ត្រូវអង្គការបញ្ជូនទៅកាន់ខេត្តក្រចេះ ដោយធ្វើដំណើរតាមរថភ្លើងឆ្ពោះទៅកាន់ទីក្រុងភ្នំពេញ និងត្រូវសម្រាកនៅក្រុងភ្នំពេញរយៈពេលមួយយប់។ លុះស្អែកឡើង ទើប វណ្ណៈ និងសមាជិកក្រុមបន្តដំណើរតាមកប៉ាល់សំដៅទៅកាន់ខេត្តក្រចេះ។ បន្ទាប់ពីទៅដល់ខេត្តក្រចេះ វណ្ណៈ និងសមាជិកក្រុមត្រូវអង្គការបញ្ជូនទៅវរសេនាតូច១១៣ កងពល៩២០ ជាបណ្ដោះអាសន្ន។ ពេលនោះឈ្មោះ វ៉ាន់ គឺជាប្រធានវរសេនាតូច១១៣, ឈ្មោះ ប៊ិន គឺជាអនុប្រធានវរសេនាតូច១១៣ រីឯ វណ្ណៈ និងបក្ខពួកធ្វើជាប្រធានក្រុម។

នៅខែមករា ឆ្នាំ១៩៧៦ វេលាម៉ោង៨យប់ ឈ្មោះ ប៊ិន បានហៅ វណ្ណៈ រួមទាំងមនុស្សចំនួន៤នាក់ទៀត ទៅប្រជុំនៅជិតវត្តក្រចេះជាប់នឹងទន្លេជាមួយ វ៉ាន់។ វ៉ាន់បានសួរថា «តើនៅតំបន់៣៣ មានសកម្មភាពយ៉ាងម៉េចខ្លះ? នៅពេលនោះ ឈ្មោះ អេង បានឆ្លើយថា សកម្មភាពនៅតំបន់៣៣ ទាំងនៅសមរភូមិមុខ និងសមរភូមិក្រោយ គឺមានខ្មែរមួយចំនួនបានប្រឆាំងនឹងអង្គការបដិវត្តន៍។ បន្ទាប់មក វ៉ាន់បានណែនាំទៅកាន់មនុស្សចំនួន៤នាក់ដែលជាខ្មែររយៈនៅក្នុងកងពល៩២០ ទៅដល់ វណ្ណៈ និងបក្ខពួកឱ្យបានស្គាល់។ លើសពីនេះ ឈ្មោះ វ៉ាន់ណែនាំ វណ្ណៈ និងសមាជិកចំនួន៣នាក់ទៀតឱ្យលាក់ការណ៍ និងបំផុសដល់អ្នកទាំង៤នាក់ឱ្យមានទំនាស់ស្អប់នឹងការធ្វើបដិវត្តន៍។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ វណ្ណៈ និងបក្ខពួក បានធ្វើដំណើរមកដល់ភូមិស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ប៉ុន្តែ ត្រូវអង្គការចាប់ខ្លួន និងបញ្ជូនទៅឃុំឃាំងនៅមន្ទីរសន្តិសុខនៅស្រុកស្នួល។ រយៈពេល៧ថ្ងៃក្រោយមក វណ្ណៈ ធ្លាក់ខ្លួនឈឺ ទើបប្រធានមន្ទីរសន្តិសុខបញ្ជូន វណ្ណៈ ទៅព្យាបាលមន្ទីរពេទ្យស្រុកស្នួល។ រយៈពេល៣ទៅ៤ថ្ងៃក្រោយមក ជំងឺរបស់ វណ្ណៈ កាន់តែធ្ងន់ឡើងៗ ទើបអង្គការបញ្ជូនបន្តទៅព្យាបាលនៅមន្ទីរពេទ្យតំបន់៥០៥ នៅខេត្តក្រចេះ។ វណ្ណៈ សម្រាកព្យាបាលនៅមន្ទីរពេទ្យតំបន់៥០៥ រយៈពេល៦ខែ ទើបបានធូរស្រាល ហើយអង្គការបញ្ជូនគាត់ត្រឡប់មកអង្គភាពដើមវិញ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ វណ្ណៈ និង សុង ត្រូវ

អង្គការបញ្ជូនទៅខេត្តមណ្ឌលគិរី ដោយរស់នៅក្នុងកងវរសេនាតូច៩៣០ ក្នុងអង្គភាពយោធាទី៤ មានតួនាទីជាយុទ្ធជន។ ពេលនោះ វណ្ណៈ និង សុង បានជួបជាមួយឈ្មោះ ប៊ិន មានតួនាទីជាភស្តុភារ អនុសេនាធំទី១, អេង ភស្តុភារ អនុសេនាធំទី២ និងសុន យុវជននៅកងអនុសេនាធំទី១។ ពេលនោះ ខ្មែរក្រហមបានបោះអង្គភាពទ័ព នៅតាមបណ្ដោយអូរច្បារ។ ក្រោយមក វណ្ណៈ បានជួបជាមួយ អេង ប៊ិន និង សុន នៅ ខាងលិចអូរច្បារ។ កាលនោះ វ៉ាន់ និង ប៊ិន ទាក់ទងកម្លាំងបានចំនួន៦នាក់ នៅកងពល៩២០។

នៅខែធ្នូ ឆ្នាំ១៩៧៦ អង្គការបានដកកម្លាំងថ្មីអស់ចំនួនជាង១០០០នាក់ នៅក្នុងកងពល៩២០។ ក្នុងនោះ មានវណ្ណៈ, ប៊ិន, សុន, អេង និងប្រជាជនជាច្រើនទៀត។ វណ្ណៈ និង អេង ត្រូវអង្គការចាត់តាំងឱ្យនៅមន្ទីរក១១តំបន់១០៥ មានតួនាទីភស្តុភារ កងអនុសេនាតូច។ ចំណែក ប៊ិន និងសុន ត្រូវអង្គការបញ្ជូនទៅមន្ទីរក១៦ តំបន់១០៥ នៅភូមិអ៤ ដែលមានចម្ងាយ១០គីឡូម៉ែត្រពីកន្លែង វណ្ណៈ រស់នៅ។ នៅឆ្នាំ១៩៧៧ វណ្ណៈ ក្ដាប់បានសភាពការណ៍នៅក្នុងមន្ទីរក១១ ហើយរកឃើញកើតមានទំនាស់រវាងជនជាតិភាគច្រើន និងជនជាតិភាគតិច ពីការហូបចុកទទួលបានមិនស្មើគ្នា។ ជាងនេះទៅទៀត មានសមាសភាពថ្មី នៅក្នុងមន្ទីរក១១បានបន្តជាទំនាស់ ព្រោះអង្គការបានបំបែកបំបាក់អ្នកទាំងនោះចេញពីឪពុកម្ដាយ ឃ្លាតឆ្ងាយពីស្រុកភូមិ ហើយត្រូវទៅរស់នៅក្នុងព្រៃ។ ទន្ទឹមនឹងនេះ វណ្ណៈ តាមដានឃើញមនុស្សចំនួន៨នាក់ ដែលមានទំនាស់ជាមួយអង្គការ និងមានទំនាក់ទំនងនៅក្នុងអង្គភាពកងពល៩២០។ នៅខែមេសា ឆ្នាំ១៩៧៧ វណ្ណៈ និង អេង ធ្វើដំណើរទៅខេត្តមណ្ឌលគិរី និងបាននិយាយបំផុសអ្នកទាំង៨នាក់បន្ថែមទៀត ដោយលើកឡើងថា បើចង់ជួបមុខឪពុកម្ដាយ និងវិលត្រឡប់មកស្រុកភូមិវិញ យើងត្រូវតែរួមគ្នាប្រឆាំងនឹងអង្គការបដិវត្តន៍។ អ្នកទាំងនោះយល់ស្របតាមផែនការនេះ។ ក្នុងពេលនោះ វណ្ណៈ, ប៊ិន និងស៊ុន ចាត់តាំងឈ្មោះ ញ៉ន កាន់តួនាទីជាអនុប្រធានមន្ទីរក១១ ឱ្យបន្តធ្វើសកម្មភាពនៅក្នុងមន្ទីរក១១ដដែល។ ស្របពេលជាមួយគ្នា ឈ្មោះ ញ៉ន ណែនាំ វណ្ណៈ ឱ្យខិតខំសាមគ្គី និងប្រមូលបងប្អូនជនជាតិមកធ្វើជាកម្លាំង។

នៅចុងខែមេសា ឆ្នាំ១៩៧៧ ប្រធានមន្ទីរក១១ ចាត់តាំង វណ្ណៈ ឱ្យទៅបាញ់សត្វ រយៈពេលកន្លះខែជាមួយបងប្អូនជនជាតិ នៅព្រៃភ្នំអូត្រាត ដើម្បីយកសាច់មកផ្គត់ផ្គង់នៅមន្ទីរ។ នៅខែកក្កដា ឆ្នាំ១៩៧៧ វណ្ណៈ ត្រឡប់មកមន្ទីរវិញ ហើយទាក់ទងមនុស្ស៨នាក់ ដែលជាកម្លាំងដែលអូសទាញបានឱ្យមកធ្វើការនៅផ្ទះមួយកន្លែងនៅក្នុងព្រៃ ខាងកើតមន្ទីរក១១ ដោយផ្ទះនោះពុំមានមនុស្សរស់នៅឡើយ។ បន្ទាប់មក អេង រៀបចំប្រជុំដោយលើកឡើងពីការខិតខំសាមគ្គីជាមួយបងប្អូនជនជាតិដើម្បីងាយស្រួលក្នុងការទាក់ទង និងប្រមូលមកធ្វើជាកម្លាំង។ ជាពិសេសនោះ ត្រូវប្រមូលកម្លាំងមនុស្សដែលមកពីស្រុកជាមួយគ្នា ហើយណែនាំឱ្យស្គាល់ពីមេដឹកនាំឈ្មោះ ញ៉ន និងមេធំឈ្មោះ ម៉ុ មានតួនាទីជាគណៈតំបន់១០៥។ នៅពាក់កណ្ដាលខែកក្កដា ឆ្នាំ១៩៧៧ វណ្ណៈ បានទៅដឹកជ្រូកនៅកាវ៉ាស់ឡានតំបន់១០៥ នៅខេត្តមណ្ឌលគិរី និងជួបឈ្មោះ ស៊ុន និង ប៊ិន នៅកន្លែងនោះដែរ។ ក្រោយមក អង្គការប្រកាសការប្រជុំដោយមានការយាមកាមយ៉ាងប្រុងប្រយ័ត្នបំផុត ព្រោះគណៈកងនៅស្រុកកោះញែក ឈ្មោះ ស្វាយបានក្បត់ និងលួចបាញ់សម្លាប់កម្មាភិបាលក្នុងកងស្លាប់អស់ចំនួន២នាក់ ហើយរត់ចូលព្រៃបាត់ ថែមទាំងយកកាំភ្លើងចំនួនមួយដើមទៅជាមួយ។ នៅថ្ងៃទី២ខែសីហា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួនវណ្ណៈ និងឈ្មោះ សយ រួមទាំងមនុស្សមួយចំនួនទៀតនៅក្នុងមន្ទីរក១១បញ្ជូនទៅដាក់នៅមន្ទីរសន្តិសុខ១០៥។

**កំណត់ចំណាំ៖** អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខJ០០១៩៥តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និង ធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ មុត សុន ហៅ វណ្ណៈ ពិតប្រាកដយ៉ាងណានោះទេ។

# វីរកងទ័ព កឹយ គៀន ចូលចិត្តវិស័យយោធាតាំងពីវ័យក្មេង

**សា ហ្វី**



វីរកងទ័ព កឹយ គៀន ពលីជីវិតនៅសមរភូមិថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ក្នុងការប្រយុទ្ធតតាំងនឹងការឈ្លានពានទឹកដីពីកងទ័ពថៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីក្មេងកូនប្រុសខ្ញុំចូលចិត្តលេងកាំភ្លើងដើររត់ដេញបាញ់គ្នាជាមួយក្មេងដទៃទៀតនៅក្នុងភូមិស្ទើររៀងរាល់ថ្ងៃ។ ពេលធំពេញវ័យ និងរៀនចប់ថ្នាក់វិទ្យាល័យកូនប្រុសខ្ញុំបានសុំអនុញ្ញាតពីខ្ញុំ និងម្ដាយរបស់ខ្លួនចូលបម្រើកងទ័ពតាមក្ដីស្រមៃកាលពីវ័យកុមារ។ លោក ឡាំ កឹយ អាយុ៦៨ឆ្នាំរស់នៅភូមិពងទឹក ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ បានរៀបរាប់រឿងរ៉ាវកូនប្រុសឈ្មោះ កឹយ គៀន គឺជាវីរកងទ័ពដែលបានពលីនៅសមរភូមិថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ដូចខាងក្រោម៖

ខ្ញុំមានប្រពន្ធឈ្មោះ ម៉ សឹ អាយុ៦១ឆ្នាំ និងមានកូនប្រុសចំនួន៥នាក់គឺ កូនទី១) ឈ្មោះ ឡាំ សិលា កូនទី២) ឈ្មោះ ឡាំ សេងហួត កូនទី៣) ឈ្មោះ ឡាំ សេងលីម កូនទី៤) ឈ្មោះ ឡាំ សារ៉ាត់ និងកូនទី៥) ឈ្មោះ កឹយ គៀន។ កូនប្រុសខ្ញុំ៤នាក់បានរៀបការប្រពន្ធ និងបែកទៅរស់នៅតាមគ្រួសាររៀងៗខ្លួន គឺនៅតែកូនប្រុសពៅឈ្មោះ កឹយ គៀន មានអាយុ២២ឆ្នាំ បានពលីនៅសមរភូមិ។

កាលពីក្មេង គៀន រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យអំពិលក្នុងឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ បន្ទាប់មក គៀន បានទៅរៀនបន្តនៅវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ ក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ។ កូនខ្ញុំឧស្សាហ៍ព្យាយាមរៀនសូត្រតាំងពីនៅវ័យកុមារ រហូតប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ទទួលបាននិទ្ទេសល្អនៅវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ ក្រុងសំរោង ខេត្តឧត្តរមានជ័យ នៅក្នុងឆ្នាំ២០២៣។ ក្រោយពីរៀន កូនខ្ញុំគឺជាក្មេងដែលចេះគោរពចាស់ទុំ សុភាពរាបសារ និងមិនដែលធ្វើឱ្យឪពុកម្ដាយពិបាកចិត្តឡើយ។

នៅឆ្នាំ២០២៥ គៀន បានសម្រេចចិត្តចុះឈ្មោះប្រឡងចូលបម្រើកងទ័ព។ បន្ទាប់ពីប្រឡងជាប់ក្របខ័ណ្ឌកងទ័ព គៀន ត្រូវបានថ្នាក់ដឹកនាំកងយោធពលខេមរភូមិន្ទបញ្ជូនទៅបណ្ដុះបណ្ដាល និងហ្វឹកហ្វឺនជំនាញកងទ័ពជើងគោកនៅសាលាពលទាហានទី៤ នៃយោធភូមិភាគទី៤ ក្នុងស្រុកបន្ទាយស្រី ខេត្តសៀមរាប។



វីរកងទ័ព កឹយ គៀន ពលីជីវិតនៅសមរភូមិថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ក្នុងការប្រយុទ្ធតតាំងនឹងការឈ្លានពានទឹកដីពីកងទ័ពថៃ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅអំឡុងពេលផ្ទុះសង្គ្រាមលើកទី១ រវាងកម្ពុជា និងថៃ នៅចន្លោះថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ កូនខ្ញុំកំពុងហ្វឹកហ្វឺននៅក្នុងសាលាពលទាហានទី៤ នៅឡើយ។ នៅខែវិច្ឆិកា ឆ្នាំ២០២៥ កូនខ្ញុំត្រូវបានអង្គភាពបញ្ជូនទៅសមរភូមិថ្មដា ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ គៀន ត្រូវបានថ្នាក់ដឹកនាំអង្គភាពកងទ័ពបញ្ចូលទៅក្នុងកងវរសេនាតូចលេខ ៥៥៦ ចំណុះតំបន់ប្រតិបត្តិការសឹករង ខេត្តពោធិ៍សាត់ យោធភូមិភាគទី៥ កងទ័ពជើងគោក។

ចាប់តាំងពីផ្ទុះសង្គ្រាមលើកទីពីរនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ស្ថានភាពតាមព្រំដែនកម្ពុជា-ថៃកាន់តែក្តៅ ពេលនោះខ្ញុំបារម្ភអំពីសុវត្ថិភាពកូនប្រុសខ្ញុំកាន់តែខ្លាំង។ ខ្ញុំបានទូរសព្ទទៅសួរសុខទុក្ខកូន និងពីស្ថានភាពសង្គ្រាម ហើយកូនខ្ញុំបានទាក់ទងមកខ្ញុំសឹងតែរាល់ថ្ងៃ។ ខ្ញុំ និងប្រពន្ធបារម្ភពីកូនគ្រប់ពេល។ ពេលខ្ញុំទូរសព្ទទៅកូនម្តងៗ ពាក្យដែលកូននិយាយមកកាន់ខ្ញុំនោះគឺ ឪម៉ែមិនបាច់បារម្ភពីកូនទេ! កូនមិនអីទេ! អង្គភាពរបស់កូនមានលេណដ្ឋានធំៗណាស់ ហើយមានកងទ័ពជាច្រើននាក់នៅក្នុងលេណដ្ឋានជាមួយដែរ! ឪម៉ែថែទាំសុខភាពផង កូនមិនអីទេ។

នៅវេលាម៉ោងប្រមាណ៩ព្រឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ យន្តហោះចម្បាំងF-16 របស់សត្រូវឈ្លានពានទឹកដីបានហោះមកទម្លាក់គ្រាប់ត្រូវចំលេណដ្ឋានកូនរបស់ខ្ញុំ និងវីរកងទ័ព៣៦នាក់ទៀតដែលកំពុងត្រៀមខ្លួនប្រយុទ្ធបណ្តាលឱ្យស្លាប់។

នៅម៉ោងប្រមាណពាររសៀល ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ សពកូនប្រុសខ្ញុំត្រូវបានរថយន្តពេទ្យដឹកពីសមរភូមិថ្មដា ក្នុងស្រុកវាលវែង មកដល់កន្លែងខ្ញុំ និងក្រុមគ្រួសារ ដែលកំពុងស្នាក់នៅក្នុងមណ្ឌលជនភៀសសឹកវត្តចុងកាល់ ស្រុកចុងកាល ខេត្តឧត្តរមានជ័យ។ ពិធីបុណ្យសពកូនខ្ញុំមិនសូវមានបងប្អូនចូលរួមច្រើនឡើយ គឺដោយសារខ្ញុំរត់ភៀសខ្លួនចេញពីភូមិស្រុកមកស្នាក់នៅមណ្ឌលជនភៀសសឹកក្នុងស្រុកស្រុកចុងកាល់។ នៅពេលដែលសពកូនរបស់ខ្ញុំមកដល់ជំរំភៀសសឹក ខ្ញុំបានសុំអនុញ្ញាតពីព្រះគ្រូចៅអធិការ លោកតាអាចារ្យវត្តជួយរៀបចំបូជាសពកូនខ្ញុំនៅក្នុងវត្តតែម្តង។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ អង្គភាពយោធាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយខេត្តឧត្តរមានជ័យ បាននាំយកថវិកា និងសាររំលែកមរណទុក្ខពីនាយករដ្ឋមន្ត្រី និងកាកបាទក្រហមកម្ពុជាមកប្រគល់ជូនគ្រួសារខ្ញុំដែលមានកូនធ្វើពលិកម្មជូនជាតិមាតុភូមិ។

ក្នុងនាមជាឪពុករបស់វីរកងទ័ពកឹយ គៀន ខ្ញុំមានអារម្មណ៍ឈឺចាប់ និងសោកស្តាយជាខ្លាំងនៅពេលឮដំណឹងថាកូនប្រុសជាទីស្រឡាញ់ត្រូវបានយន្តហោះចម្បាំង (F-16) របស់សត្រូវឈ្លានពានទឹកដីបានទម្លាក់គ្រាប់ត្រូវចំលេណដ្ឋានកូនរបស់ខ្ញុំ។ ខ្ញុំ និងប្រពន្ធទន់ដៃទន់ជើងស្ទើរតែសន្លប់បាត់ស្មារតីពេលសពកូនប្រុសត្រូវបានបញ្ជូនមកដល់វត្តសំរោងចុងកាល់។ សព្វថ្ងៃ ខ្ញុំនៅមិនទាន់អាចកាត់ចិត្តបាន និងធ្វើការងារអ្វីកើតនៅឡើយ ដោយសារនឹកអាឡោះអាល័យកូន។

# វីរកងទ័ព គូ សែនសុភា ពលីនៅសមរភូមិប្រាសាទតាមាន់

ធី គឹមហុង

អ្នកគ្រូ ក្រាញ់ សុភី បង្រៀននៅសាលាបឋមសិក្សាសៀងណាំសណ្ដាន់ ត្រូវជាម្ដាយរបស់វីរកងទ័ព គូ សែនសុភា ដែលបានពលីនៅសមរភូមិទិសប្រាសាទតាមាន់នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥ បានរៀបរាប់រឿងរ៉ាវកូនប្រុសច្បង និងក្រុមគ្រួសារ ដូចខាងក្រោម៖

ខ្ញុំឈ្មោះ ក្រាញ់ សុភី អាយុ៥១ឆ្នាំ មានប្ដីឈ្មោះ គូ គៀ អាយុ៥២ឆ្នាំ និងមានកូនចំនួន៤នាក់ គឺប្រុស ២នាក់ និងស្រី២នាក់។ សព្វថ្ងៃគ្រួសារខ្ញុំរស់នៅភូមិបឹងខ្នា ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប។



វីរកងទ័ព គូ សែនសុភា បានពលីជីវិតនៅសមរភូមិទិសប្រាសាទតាមាន់ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥ ក្នុងការប្រយុទ្ធតតាំងនឹងការឈ្លានពានទឹកដីពីកងទ័ពថៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កូនប្រុសច្បងខ្ញុំមានឈ្មោះ គូ សែនសុភា ឋានន្តរសក្តិអនុសេនីយ៍ត្រី កើតនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៦។ កាលពីក្មេង សុភា បានចូលរៀននៅសាលាបឋមសិក្សាបឹងខ្នា និងបន្តរៀននៅវិទ្យាល័យពួក ខេត្តសៀមរាប រហូតដល់បញ្ចប់ការសិក្សានៅឆ្នាំ២០១៦។ បន្ទាប់មក សុភាបានទៅរៀននៅសាកលវិទ្យាល័យមួយនៅរាជធានីភ្នំពេញ និងបានចូលធ្វើការក្នុងសណ្ឋាគារមួយកន្លែងដើម្បីដោះស្រាយជីវភាព និងផ្គត់ផ្គង់ការសិក្សា។ ដោយសារជំងឺកូវីដ-១៩ បានរាតត្បាតខ្លាំងនៅប្រទេសកម្ពុជាបណ្ដាលឱ្យ សុភា បាត់បង់ការងារ និងផ្អាកការសិក្សាជាបណ្ដោះអាសន្ន។

នៅឆ្នាំ២០២១ សុភា បានសុំខ្ញុំ និងប្ដីរបស់ខ្ញុំដើម្បីប្រឡងចូលបម្រើជាកងទ័ព ហើយពេលនោះខ្ញុំ និងប្ដីបានយល់ព្រម។ បន្ទាប់ពីបានប្រឡងជាប់ជាកងទ័ព សុភា ត្រូវថ្នាក់ដឹកនាំកងយោធពលខេមរភូមិន្ទបញ្ជូនទៅហ្វឹកហាត់នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប រហូតដល់បញ្ចប់វគ្គ ទើបបញ្ជូនគាត់ទៅបម្រើការងារនៅអង្គភាពវរសេនាតូចអន្តរាគមន៍លេខ២៨១ កងពលតូចអន្តរាគមន៍លេខ៤ ចំណុះឱ្យកងពលធំអន្តរាគមន៍លេខ២ ស្ថិតនៅក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ ចាប់តាំងពីចូលបម្រើកងទ័ព សុភា ខិតខំបម្រើការងារមិនសូវមានពេលទំនេរមកលេងផ្ទះទេ។ ដោយមានការនឹករឭកដល់កូនប្រុស ខ្ញុំនិងប្ដីតែងតែធ្វើដំណើរទៅសួរសុខទុក្ខ និងហូបអាហារជុំជាមួយកូននៅស្រុកបន្ទាយអំពិលជាញឹកញាប់។

នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៥ សុភា ត្រូវបានមេបញ្ជាការកងវរសេនាតូចអន្តរាគមន៍២៨១ បញ្ជូនទៅរៀនផ្នែកភស្តុភារកងទ័ពនៅសាលាយោធភូមិ

ភាគទី៤ ខេត្តសៀមរាប ដែលទទួលខុសត្រូវលើការរៀបចំផែនការ ការគ្រប់គ្រង ការផ្គត់ផ្គង់ និងការថែរក្សាកងទ័ព ដើម្បីទ្រទ្រង់រាល់ប្រតិបត្តិការយោធា និងបេសកកម្មនានា។ បន្ទាប់ពីរៀនសូត្របានរយៈពេល២ខែ ស្រាប់តែមានការផ្ទុះអាវុធរវាងកម្ពុជា និងថៃនៅចន្លោះថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ ពេលនោះ សុភាបានត្រៀមខ្លួនទៅសមរភូមិដែរ ប៉ុន្តែស្ថានភាពបានល្អប្រសើរឡើងវិញព្រោះមានបទឈប់បាញ់។ សុភា បានបន្តការសិក្សារហូតដល់បញ្ចប់វគ្គនៅខែកញ្ញា ឆ្នាំ ២០២៥ ទើបត្រឡប់មកអង្គភាពកងវរសេនាតូចអន្តរាគមន៍២៤១វិញ។

បន្ទាប់ពីរៀនវគ្គភស្តុភារកងទ័ពចប់ សុភា បន្តកិច្ចការងារជាធម្មតា ប៉ុន្តែ ខ្ញុំ និងក្រុមគ្រួសារមានការព្រួយបារម្ភពីសុវត្ថិភាពរបស់គាត់យ៉ាងខ្លាំង ទោះបីជាសង្គ្រាមរយៈពេល៥ថ្ងៃបានបញ្ចប់។ ខ្ញុំបានទៅសួរសុខទុក្ខ និងទុកម៉ូតូមួយគ្រឿងឱ្យ សុភា ជិះទៅធ្វើការងារ និងជិះមកលេងផ្ទះ។ នៅក្នុងខែកញ្ញា ឆ្នាំ២០២៥ ដដែល មេបញ្ជាការកងវរសេនាតូចអន្តរាគមន៍លេខ២៤១បានបញ្ជូន សុភា ទៅប្រចាំការនៅ ប្រាសាទតាមាន់(ស្លាបផ្លេង) ពីព្រោះ សុភា ទើបតែរៀនចប់ផ្នែកភស្តុភារកងទ័ព ត្រូវទទួលខុសត្រូវលើការរៀបចំផែនការ ការគ្រប់គ្រង ការផ្គត់ផ្គង់ និងការថែរក្សាកងទ័ពនៅសមរភូមិជួរមុខ។

ពេលទៅប្រចាំការនៅជួរមុខ ខ្ញុំ និងក្រុមគ្រួសារតែងតែទូរសព្ទទៅសួរសុខទុក្ខ សុភា ជាហូរហែមិនសូវលោះថ្ងៃឡើយ។ ខ្ញុំតែងតែទិញរបស់ប្រើប្រាស់ និងម្ហូបអាហារផ្ញើទៅឱ្យ សុភា ព្រោះខ្លាចកូនប្រុសពិបាក និងគ្មានអាហារហូបចុកគ្រប់គ្រាន់។ នៅថ្ងៃសម្រាកពីការបង្រៀនសិស្ស ខ្ញុំតែងតែឆ្លៀតធ្វើដំណើរទៅសួរសុខទុក្ខកូនប្រុសជាញឹកញាប់រហូតដល់ពេលផ្ទុះអាវុធលើកទី២ នៅខែធ្នូ ឆ្នាំ២០២៥។

នៅរសៀលថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ស្ថានភាពនៅតាមព្រំដែនបានតានតឹងយ៉ាងខ្លាំង ពេលនោះ សុភា បានហៅទូរសព្ទមកប្រាប់ខ្ញុំ និងបានស្នើសុំឱ្យខ្ញុំជួយធ្វើខ្សែកបន្តោងរូបព្រះពុទ្ធមួយខ្សែសម្រាប់ពាក់ការពារខ្លួន ដោយគាត់ពោលថា៖ «ម៉ែ! ជួយធ្វើខ្សែកបន្តោងរូបព្រះពុទ្ធមួយខ្សែទុកឱ្យខ្ញុំការពារខ្លួនផង»។



ពិធីបុណ្យសពរបស់វីរកងទ័ព គូ សែនសុភា ដែលបានពលីជីវិតនៅសមរភូមិទិសប្រាសាទតាមាន់ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥ ក្នុងការប្រយុទ្ធតតាំងនឹងការឈ្លានពានទឹកដីពីកងទ័ពថៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពេលទទួលបានដំណឹងថាកូនប្រុសចង់បានខ្សែកបន្តោងរូបព្រះពុទ្ធ ខ្ញុំបានពឹងពាក់កូនប្រសារឱ្យជួយរកទិញខ្សែកបន្តោងរូបព្រះពុទ្ធ និងនាំយកទៅបញ្ចុះអាគមគាថាតាមជំនឿដូនតា។ លុះធ្វើខ្សែកបន្តោងរូបព្រះពុទ្ធរួចរាល់នៅថ្ងៃទី៩ ខែធ្នូ ខ្ញុំបានព្យាយាមទាក់ទងទៅកូនប្រុស ប៉ុន្តែមិនអាចទាក់ទងបានឡើយ។ ខ្ញុំបានសម្រេចចិត្តជិះរថយន្តឈ្នួលយកខ្សែកបន្តោងរូបព្រះពុទ្ធទៅឱ្យកូនដោយផ្ទាល់ ប៉ុន្តែដោយសារស្ថានភាពកាន់តែតានតឹង កម្លាំងសមត្ថកិច្ចកម្ពុជាបានបិទផ្លូវមិនឱ្យប្រជាពលរដ្ឋចេញចូលឡើយ ធ្វើឱ្យខ្សែកបន្តោងរូបព្រះពុទ្ធនោះមិនបានទៅដល់ដៃកូនប្រុសរបស់ខ្ញុំឡើយ។

ទោះបីជាយ៉ាងណា សុភា តែងតែទូរសព្ទមកប្រាប់ខ្ញុំអំពីស្ថានភាពព្រំដែន និងសុវត្ថិភាពរបស់ខ្លួនជាប្រចាំ ប៉ុន្តែប៉ុន្មានថ្ងៃក្រោយមកស្រាប់តែបាត់ដំណឹងកូនប្រុសខ្ញុំសូន្យឈឹងមិនឃើញទាក់ទងមកដូចរាល់ដង ធ្វើឱ្យខ្ញុំព្រួយបារម្ភកាន់តែខ្លាំង។ លុះពេលខ្ញុំទាក់ទងទៅមេបញ្ជាការរបស់ សុភា មេបញ្ជាការបានពន្យល់ប្រាប់ខ្ញុំថា ថ្នាក់លើបានបញ្ជាឱ្យបិទប្រព័ន្ធទំនាក់ទំនងទាំងអស់ មិនឱ្យទាក់ទងមកគ្រួសារឡើយ។ មេបញ្ជាការរបស់ សុភា បាននិយាយលួងលោមខ្ញុំថា៖ «មិនអីទេបង ខ្ញុំទើបតែជួបអាភាអម្បាញ់មិញហ្នឹងទេ»។ ឮដូច្នោះ ខ្ញុំ និងគ្រួសារ បានធូរចិត្តមួយកម្រិត។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំបានទទួលដំណឹងយ៉ាងក្រៀមក្រំថា កូនប្រុសរបស់ខ្ញុំបានពលីជីវិតនៅក្នុងសមរភូមិហើយ។ ដំណឹងនេះធ្វើឱ្យខ្ញុំស្ទើរតែទទួលយកមិនបាន ព្រោះវាជាការបាត់បង់កូនប្រុសជាទីស្រឡាញ់ស្មើជីវិត។ អ្វីដែលកាន់តែសោកសៅជាងនេះទៅទៀតនោះគឺ កូនប្រុសខ្ញុំបានពលីតាំងពីថ្ងៃទី១៣ ខែធ្នូ មកម្ល៉េះ ប៉ុន្តែដោយសារស្ថានការណ៍វឹកវរខ្លាំងពេក និងការគ្រប់គ្រងកម្លាំងមានភាពមមាញឹក ទើបអង្គភាពកងវរសេនាតូចអន្តរាគមន៍លេខ២៨១ មិនទាន់អាចទាក់ទងមកគ្រួសារខ្ញុំបានភ្លាមៗ។

យោងតាមការរៀបរាប់ពីមិត្តរួមអាវុធនៅជួរមុខម្នាក់របស់កូនប្រុសខ្ញុំបានឱ្យដឹងថា នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ក្នុងពេលកំពុងប្រយុទ្ធគ្នាយ៉ាងសន្ធប់ មានកងទ័ពជាច្រើននាក់បានរងរបួស។ កូនរបស់ខ្ញុំបានជួយលាងរបួសឱ្យមិត្តរួមអាវុធ រហូតប្រឡាក់ឈាមពេញខ្លួន។ បន្ទាប់មក កូនខ្ញុំបានដើរចេញពីលេណដ្ឋាន ដើម្បីទៅលាងសម្អាតខ្លួនប្រាណ។ ពេលលាងខ្លួនរួចរាល់ កូនខ្ញុំបានដើរត្រឡប់មកចូលក្នុងលេណដ្ឋានវិញ។ មួយសន្ទុះក្រោយមក ស្រាប់តែយន្តហោះសត្រូវឈ្លានពានទឹកដីបានហោះមកទម្លាក់គ្រាប់បែកចំលេណដ្ឋានរបស់កូនប្រុសខ្ញុំតែម្តង បណ្តាលឱ្យដីបាក់សង្កត់ជាប់នៅក្នុងលេណដ្ឋាន រហូតដល់បាត់បង់ជីវិត។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ដដែល ក្រុមគ្រួសាររបស់ខ្ញុំបានរៀបចំបុណ្យសព សុភា តាមប្រពៃណីសាសនានៅផ្ទះ ស្ថិតក្នុងភូមិបឹងខ្លា ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប ប៉ុន្តែការធ្វើបុណ្យគ្រាន់តែរៀបចំខ្ទិសកុសលដល់កូនប្រុសជាមួយនឹងរូបថតមួយសន្លឹកតែប៉ុណ្ណោះ ព្រោះតែសាកសពកូនប្រុសរបស់ខ្ញុំបានកប់ក្នុងលេណដ្ឋានមិនទាន់អាចយកចេញបានឡើយ។ ខ្ញុំនិងក្រុមគ្រួសារមានការឈឺចាប់យ៉ាងខ្លាំង ពីព្រោះមិនបានឃើញមុខ និងឃើញសាកសពកូនប្រុសជាលើកចុងក្រោយ ។

រហូតដល់ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៦ ទើបសាកសពរបស់កូនប្រុសខ្ញុំ និងវីរកងទ័ពដទៃទៀតត្រូវបានកាយចេញពីលេណដ្ឋានដោយត្រាក់ទ័រជីកដី និងអេស្កាវ៉ាទ័រ យកមកធ្វើបុណ្យរួមគ្នានៅវត្តពងទឹក ក្នុងភូមិពងទឹក ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមាន-ជ័យ ស្ថិតក្បែរបន្ទាយកងវរសេនាតូចអន្តរាគមន៍លេខ២៨១។ បន្ទាប់ពីបូជាសពរួចរាល់ហើយ គ្រួសារសពទាំងអស់បានប្រមូលធាតុកូន និងប្តីត្រឡប់មកផ្ទះរៀងៗខ្លួន។

ខ្ញុំ និងគ្រួសារមានសេចក្តីអាឡោះអាល័យជាពន់ពេកចំពោះការបាត់បង់កូនប្រុសខ្ញុំ ប៉ុន្តែខ្ញុំនិងក្រុមគ្រួសារមានមោទនភាពចំពោះកូនប្រុសដែលបានលះបង់សាច់ស្រស់ឈាមស្រស់ក្នុងបុព្វហេតុការពារជាតិមាតុភូមិពីសត្រូវឈ្លានពានទឹកដី។ នេះជាវីរភាពដ៏ឧត្តុង្គឧត្តមដែលធ្វើឱ្យប្រជាជនកម្ពុជាមិនអាចបំភ្លេចបាន។

# ហាច ហៀកៈ ប្រជាជនភៀសសឹកនៃសង្គ្រាម ឈ្លានរបស់ថៃ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ចាន់ ណារិទ្ធ



ហាច ហៀក អាយុ៧០ឆ្នាំ បច្ចុប្បន្នស្នាក់នៅមណ្ឌលជនភៀសសឹកក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហាច ហៀក អាយុ៧០ឆ្នាំ កើតនៅភូមិអូរស្រឡៅ ឃុំអូរដំបង ស្រុកសង្កែ ខេត្តបាត់ដំបង។ ក្រោយមក ហៀក បានផ្លាស់មករស់នៅភូមិឯកភាព ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយប្រកបរបរធ្វើចម្ការ។ ហៀក មានប្រពន្ធឈ្មោះ អ៊ឹម សារឿន អាយុ៧០ឆ្នាំ និងមានកូនចំនួន៥នាក់ គឺប្រុស២នាក់ និងស្រី៣នាក់។ ហៀកមានម្ដាយឈ្មោះ អឿងយុត ស្លាប់ដោយសារជំងឺ និងឪពុកឈ្មោះ ធៀប ហាច ស្លាប់ដោយសារតែអត់អាហារក្នុងរបបខ្មែរក្រហម។ ហៀក មានបងប្អូនបង្កើតចំនួន៤នាក់ គឺប្រុស២នាក់ និងស្រី២នាក់។

ហៀកបានរៀបរាប់ថា កាលពីខ្ញុំនៅក្មេង ខ្ញុំរៀនបានត្រឹមថ្នាក់ទី១១ក្នុងសង្គមចាស់ នៅសាលាបឋមសិក្សាអូរស្រឡៅ។ គ្រូបង្រៀនខ្ញុំឈ្មោះ គ្រូលុយ និងគ្រូប៉ុល។ នៅឆ្នាំ១៩៧២ ខ្ញុំបានឈប់រៀន។ បន្ទាប់មកឪពុកខ្ញុំបានយកខ្ញុំទៅផ្ញើជាមួយព្រះចៅអធិការវត្តចែងរង្សី ដើម្បីឱ្យរៀនអក្សរ និងរៀនធម៌។ ខ្ញុំនៅចាំថា ព្រះចៅអធិការវត្តចែងរង្សី ព្រះនាម ងុយ, គ្រូសូត្រស្ដាំព្រះនាម លី និងគ្រូសូត្រឆ្វេងព្រះនាម សួរ។ ខ្ញុំរស់នៅក្នុងវត្ត ចែង រង្សី បានរយៈពេល២ឆ្នាំ កងទ័ពរំដោះខ្មែរក្រហមបានចូលមកវាយជាមួយ ទាហាន

លន់ នល់ នៅក្នុងភូមិអូរស្រឡៅ។ ខណៈពេលនោះ ខ្ញុំបានរត់ចេញពីវត្ត ចែងរង្សី ត្រឡប់ទៅរកឪពុកម្តាយនៅផ្ទះវិញ។ ពេលមកដល់ផ្ទះ ឪពុកម្តាយ ខ្ញុំបានរៀបចំរទេះគោ ដើម្បីដឹកសម្ភាររបស់របរប្រើប្រាស់ រួមទាំងកូនចៅជម្លៀសទៅកន្លែងសុវត្ថិភាពស្ថិតនៅក្នុងឃុំអន្លង់វិល ចម្ងាយប្រមាណ៦គីឡូម៉ែត្រ ពីភូមិអូរស្រឡៅ។ ឪពុក ខ្ញុំបាននាំកូនចៅទៅ ស្នាក់នៅផ្ទះមិត្តភក្តិរបស់គាត់ឈ្មោះ ហួន ដែលជាអ្នកសម្តែងល្ខោនរឿងរាមកេរ្តិ៍។

បន្ទាប់ពីស្នាក់នៅឃុំអន្លង់វិលបានរយៈពេល ២ខែ កងទ័ពខ្មែរក្រហមបានបាញ់ផ្លោងគ្រាប់ចូលមក ហេតុនេះក្រុមគ្រួសាររបស់ខ្ញុំបាននាំគ្នាជម្លៀសបន្តទៅស្នាក់នៅភូមិដំណាក់ហ្លួងរយៈពេល៥ថ្ងៃ ទើបធ្វើដំណើរទៅស្នាក់នៅភ្នំសំពៅ ក្នុងស្រុកបាណន់ ខេត្តបាត់ដំបង បណ្តោះអាសន្ន។ ពេលឪពុកខ្ញុំបររទេះគោចូលមកដល់ភ្នំសំពៅ ខ្ញុំបានឃើញទាហាន លន់ នល់ ជាច្រើននាក់យាមការពារនៅលើភ្នំសំពៅ។ បន្ទាប់ពីស្នាក់នៅភ្នំសំពៅបានកន្លះខែ កងទ័ពខ្មែរក្រហមបានបាញ់ផ្លោងគ្រាប់ និងដឹកនាំកម្លាំងចូលមកវាយជាមួយទាហាន លន់ នល់ នៅលើភ្នំសំពៅ។ នៅអំឡុងពេលនោះ ឪពុកម្តាយរបស់ខ្ញុំបានភៀសខ្លួនទៅរស់នៅផ្ទះបងស្រីខ្ញុំស្ថិតនៅអូរតាឃួច។

នៅឆ្នាំ១៩៧៥ សង្គ្រាមបានបញ្ចប់ ប្រជាជនដែលរស់នៅភ្នំសំពៅបាននាំគ្នាចេញមកឈរត្រៀបត្រាតាមបណ្តោយផ្លូវជាតិលេខ៥ ដើម្បីចាំទទួលស្វាគមន៍កងទ័ពរំដោះខ្មែរក្រហមដែលបានទទួលជ័យជម្នះទៅលើរបប លន់នល់។ បន្ទាប់ពីចប់សង្គ្រាម ខ្ញុំនិងក្រុមគ្រួសារបានចាកចេញពីអូរតាឃួចវិលត្រឡប់ទៅផ្ទះសម្បែងនៅភូមិអូរស្រឡៅវិញ។ ពេលចូលមកដល់ក្នុងភូមិ ខ្ញុំនិងបងៗបាននាំគ្នាដើររើសកួរស្រូវយកកិនទុកដាំបាយហូប។ នៅពាក់កណ្តាលឆ្នាំ១៩៧៥ ពេលខ្ញុំមានអាយុ១៥ឆ្នាំ ខ្មែរក្រហមបានជ្រើសរើសខ្ញុំឱ្យចូលធ្វើឈ្លបភូមិនៅតំបន់៤ ដើម្បីដើរស្តាប់ និងលបយកការណ៍នៅតាមផ្ទះប្រជាជនមករាយការណ៍ជូនថ្នាក់លើ។ បងៗរបស់ខ្ញុំត្រូវបានខ្មែរក្រហមបំបែកចេញពីឪពុកម្តាយឱ្យទៅធ្វើការងារនៅក្នុងកងចល័ត។ ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមប្រើទៅចាំចម្ការ រីឯម្តាយរបស់ខ្ញុំត្រូវខ្មែរក្រហមប្រើឱ្យនៅមើលក្មេងៗនៅក្នុងសហករណ៍ ព្រោះគាត់មានវ័យចំណាស់មិនអាចធ្វើការងារធ្ងន់បាន។

ខ្ញុំនៅចាំមិនភ្លេចសំណួរប្រធានឈ្លបសួរខ្ញុំ «បើឪពុកម្តាយជាខ្មាំង តើហ៊ានសម្លាប់ឬទេ»? ខ្ញុំបាននិយាយតបទៅកាន់គាត់វិញថា «ខ្ញុំមិនហ៊ានសម្លាប់ទេ ព្រោះគាត់ជាអ្នកមានគុណ»។ បន្ទាប់ពីខ្ញុំនិយាយរួច ខ្មែរក្រហមបានដកខ្ញុំចេញពីឈ្លបភូមិ រួចបញ្ជូនឱ្យទៅធ្វើស្រែជាមួយក្រុមយុទ្ធជននៅអូរស្តាស់ ស្ថិតនៅភូមិកំពង់ព្រះ ឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ ខ្ញុំត្រូវបានខ្មែរក្រហមបញ្ចូលទៅក្នុងកងយុទ្ធជនដែលមានសមាជិក៣០នាក់ នឹងត្រូវបែងចែកជា៣ក្រុមតូចៗ ដោយក្នុងមួយក្រុមមានសមាជិក១០នាក់ៗ។ នៅក្នុងក្រុមនីមួយៗ ត្រូវជ្រើសរើសមេក្រុមម្នាក់ដើម្បីគ្រប់គ្រង និងដឹកនាំសមាជិកចុះធ្វើការងារ ដូចជា ធ្វើស្រែ ជីកប្រឡាយ និងលើកទំនប់ទប់ទឹកបញ្ចូលស្រែ។ ប្រធានគ្រប់គ្រងក្រុមយុទ្ធជនមានឈ្មោះ ឈួន ដែលត្រូវជាបងប្អូនរបស់ខ្ញុំមកពីភូមិអូរស្រឡៅ។ លុះដល់រដូវច្រូតកាត់ ថ្នាក់លើបានស្នើសុំកម្លាំងមួយចំនួនធំពីកន្លែងរបស់ខ្ញុំដើម្បីបញ្ជូនទៅធ្វើការងារនៅ ទីរួមខេត្តបាត់ដំបង។ ខ្ញុំត្រូវបង ឈួន ជ្រើសរើសនិងបញ្ជូនឱ្យទៅធ្វើការងារនៅ ទីរួមខេត្តបាត់ដំបង។

លុះស្អែកឡើង ខ្ញុំនិងយុទ្ធជន២៩នាក់ទៀតបាននាំគ្នាធ្វើដំណើរមករង់ចាំរថយន្តនៅតាមបណ្តោយផ្លូវជាតិលេខ៥។ មិនយូរប៉ុន្មាន ខ្ញុំឃើញខ្មែរក្រហមបើករថយន្តទ្រុងមកដឹកក្រុមរបស់ខ្ញុំ។ ខ្ញុំភ័យខ្លាំងណាស់ ព្រោះគិតថាខ្មែរក្រហមដឹកខ្ញុំយកទៅសម្លាប់។ រថយន្តចូលមកដល់ទីរួមខេត្តបាត់ដំបង ហើយអ្នកបើកបរបានដឹកក្រុមខ្ញុំយកទៅដាក់នៅវត្តពោធិ៍ក្នុង។ ខ្ញុំនិងយុទ្ធជនទាំង២៩នាក់ចុះពីលើរថយន្ត ហើយអ្នកគ្រង់គ្រងខ្មែរក្រហមនៅទីនោះបានបែងចែកយើងឱ្យទៅធ្វើការតាមកន្លែងផ្សេងៗ។ អ្នកខ្លះត្រូវបានបញ្ជូនឱ្យទៅកាប់ឫស្សី ខ្លះទៅបោចវល្លិ និងខ្លះទៀតទៅកាប់ឈើធ្វើ

បង្គោលរបង។ ចំណែកខ្ញុំត្រូវខ្មែរក្រហមបញ្ជូនទៅកន្លែងផលិតស្បែកជើងពីកង់ឡាន។

ខ្ញុំធ្វើការងារនៅកន្លែងផលិតស្បែកជើងមួយរយៈពេលខ្លី គណៈស្រុកបានចុះមកប្រជុំ និងបានបែងចែកកម្លាំងយុវជនឡើងវិញ។ បន្ទាប់មក ក្រុមនារី និងក្រុមយុវជនមួយចំនួនត្រូវបានគណៈស្រុកបែងចែកឱ្យទៅរកត្រីនៅតាមទន្លេ និងខ្លះទៀតទៅកន្លែងបោចវល្លិ និងកាប់បុស្សីវិញ។ ចំណែកខ្ញុំនិងយុវជនផ្សេងទៀត ត្រូវបានបែងចែកឱ្យទៅកាប់បុស្សីនៅស្រុកសំឡូត ខេត្តបាត់ដំបង។ ពេលយើងធ្វើដំណើរមកដល់ស្រុកសំឡូតយុវជនទាំងអស់ត្រូវបានខ្មែរក្រហមបែកចែកជាក្រុមតូចៗ ដោយក្នុងមួយក្រុមមានគ្នាចំនួន១០នាក់។ ខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសឱ្យធ្វើជាប្រធានក្រុមដើម្បីដឹកនាំកម្លាំងចុះកាប់ដើមបុស្សី។ ខ្ញុំនិងយុវជនទាំងអស់ត្រូវខ្មែរក្រហមកំណត់ក្នុងមនុស្សម្នាក់ត្រូវកាប់បុស្សីឱ្យបានចំនួន១៥ដើមក្នុងមួយថ្ងៃ ហើយបុស្សីទាំងនោះត្រូវលួសបន្ទាឱ្យស្អាត។ យុវជនដែលធ្វើរួចរាល់តាមការកំណត់របស់ខ្មែរក្រហមអាចឈប់សម្រាកបុត្រឡប់មកកន្លែងស្នាក់នៅមុនៗ។ បុស្សីដែលកាប់បានភាគច្រើនត្រូវឡានមកដឹកជញ្ជូនយកទៅទីរួមខេត្តបាត់ដំបង។ ក្រោយពីខ្ញុំនៅកាប់បុស្សីអស់ជាច្រើនខែ ខ្ញុំបានរងរបួសជើងដើរមិនរួចដោយសារត្រូវពូថៅខ្លួនឯង។ ពេលនោះខ្មែរក្រហមបញ្ជូនខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យព-២ ដែលមានទីតាំងនៅខាងជើងរូបសំណាកតាដំបងក្រញូង ក្រុងបាត់ដំបង។ លុះពេលខ្ញុំសម្រាកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យបានរយៈពេល២ថ្ងៃ ខ្ញុំបានកើតជំងឺគ្រុនចាញ់ ហើយបានបន្តសម្រាកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យព-២អស់រយៈពេលជាច្រើនខែបន្ថែមទៀត។ ខណៈពេលនោះ មានយុវជនដែលទៅកាប់បុស្សីនៅស្រុកសំឡូតមួយចំនួនធំបានស្លាប់ដោយសារជំងឺគ្រុនចាញ់ ហើយសពយុវជនទាំងនោះត្រូវបានដឹកតាមរថយន្តឡង់រ៉ូវែទៅដុតនៅក្នុងវត្តសាក់ភិត។

បន្ទាប់ពីខ្ញុំជាសះស្បើយពីជំងឺគ្រុនចាញ់ ខ្មែរក្រហមបញ្ជូលខ្ញុំទៅក្នុងកងដឹកជញ្ជូនជើងគោក ដែលមានទីតាំងនៅពោធិ៍២ ដើម្បីដឹកជញ្ជូនត្រីងៀតប្រហុកចេញពីទន្លេយកទៅផ្ដល់ឱ្យក្រុមយុវជននៅបាក់ព្រា និងនៅព្រៃទោល។ ប្រធានគ្រប់គ្រងកងដឹកជញ្ជូនឈ្មោះតាជ័យ។ ខ្ញុំធ្វើការងារនៅកងដឹកជញ្ជូនបានប្រហែលកន្លះឆ្នាំ តាជ័យបានរៀបចំឱ្យខ្ញុំមានប្រពន្ធ។ ពេលនោះខ្ញុំបានជ្រើសរើសនារីកាត់ដេរម្នាក់ ប៉ុន្តែមិនទាន់បានរៀបចំពិធីទេ ស្រាប់តែកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកកាន់កាប់ទីរួមខេត្តបាត់ដំបង។ បន្ទាប់មក ខ្ញុំត្រូវបានកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីបញ្ជូនឱ្យទៅធ្វើស្រែនៅភូមិប្រហាល ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់។ ខ្ញុំដើររយៈពេលមួយថ្ងៃទើបមកដល់ភូមិប្រហាល ហើយកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីបានប្រើខ្ញុំនិងយុវជន ៤នាក់ទៀតឱ្យដើរគាស់គល់ឈើនៅក្នុងដីស្រែ។ បន្ទាប់មកទៀតកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីចាប់ផ្ដើមធ្វើបាបប្រជាជន និងកងទ័ពនៅភូមិភាគពាយ័ព្យ ដោយបានបង្អត់អាហារ ប្រើឱ្យធ្វើការងារហួសកម្លាំង និងចាប់ខ្លួនយកទៅសម្លាប់។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានដឹកនាំកម្លាំងចូលមករំដោះខេត្តពោធិ៍សាត់។ ខ្ញុំបានរត់ចេញពីភូមិប្រហាលសំដៅទៅផ្លូវជាតិលេខ៥ ដើម្បីធ្វើដំណើរទៅរកឪពុកម្ដាយនៅខេត្តបាត់ដំបងវិញ។ ខ្ញុំបានឃើញប្រជាជន និងកងទ័ពវៀតណាមជាច្រើននាក់កំពុងតែធ្វើដំណើរតាមផ្លូវជាតិលេខ៥។ ពេលខ្ញុំធ្វើដំណើរទៅដល់ខេត្តបាត់ដំបង ខ្ញុំបានជួបបងប្រុសរបស់ខ្ញុំនៅភូមិសំរោងកោង ហើយពេលគាត់ឃើញខ្ញុំភ្លាម គាត់បានឈរយំព្រោះតែនឹកប្អូនខ្លាំងពេក។ បន្ទាប់មកបងប្រុសខ្ញុំបាននាំខ្ញុំទៅរកម្ដាយនៅដំណាក់ហ្លួង។ ពេលម្ដាយខ្ញុំឃើញខ្ញុំភ្លាម គាត់បានអង្គុយយំព្រោះគាត់គិតថា ខ្ញុំត្រូវខ្មែរក្រហមយកទៅសម្លាប់បាត់ហើយ។ ម្ដាយខ្ញុំបាននិយាយទាំងអួលដើមកមកកាន់ខ្ញុំថា «ឪពុកកូនបានស្លាប់ហើយ ដោយសារតែគ្មានអាហារហូបចុកមុនពេលកងទ័ពវៀតណាមចូលមករំដោះ»។ បន្ទាប់ពីពុ

ម្តាយខ្ញុំនិយាយរួច ខ្ញុំបានត្រឹមអង្គុយយំព្រោះតែអាណិតឪពុក។ ក្រោយពីជួបជុំគ្នា ក្រុមគ្រួសារខ្ញុំបាននាំគ្នាត្រឡប់មករស់នៅភូមិអូរស្រឡៅវិញ ដោយប្រកបមុខរបរធ្វើត្រីងៀត ត្រីឆ្អើរ យកទៅលក់ឱ្យប្រជាជនដែលរស់នៅក្នុងជំរំថ្មី និងជំរំចាស់។ ពេលបានលុយពីការលក់ត្រីងៀត ត្រីឆ្អើរ ខ្ញុំបានទិញអង្ករដឹកត្រឡប់មកផ្ទះវិញ។ នៅឆ្នាំ១៩៩៧ ម្តាយខ្ញុំបានរៀបចំពិធីរៀបការឱ្យខ្ញុំ។

នៅឆ្នាំ២០០៦ ប្អូនថ្លៃរបស់ខ្ញុំដែលជាយោធាការពារនៅព្រំដែនថ្មដា បានហៅខ្ញុំ និងប្រពន្ធខ្ញុំឱ្យមកចាប់ដីរស់នៅភូមិឯកភាព ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ពេលខ្ញុំមកដល់តំបន់ថ្មដាដំបូងគឺឃើញមានប្រជាជន និងគ្រួសារកងទ័ពរស់នៅប្រហែល៧០គ្រួសារតែប៉ុណ្ណោះ។ បន្ទាប់មក ខ្ញុំនិងប្រពន្ធបាននាំគ្នាកាប់ឆ្ការព្រៃដើម្បីដាំដើមទុរេន និងដំណាំផ្សេងៗ។ ក្រៅពីការងារធ្វើចម្ការ ខ្ញុំនិងប្រពន្ធបាននាំគ្នាកាប់ដើមផ្អាវយកមកក្រងធ្វើជាអំបោសលក់ និងដើរស៊ីឈ្នួលកាត់ស្មៅ។

នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ទាហានឈ្លានពានថៃបានចល័តកងទ័ព និងសព្វាវុធធុនធ្ងន់ចូលមកដល់ព្រំដែនថ្មដា។ នៅពេលឃើញសភាពការណ៍មិនស្រួល ខ្ញុំបម្រុងនាំប្រពន្ធទៅស្នាក់នៅភូមិផ្សេង ប៉ុន្តែប្រពន្ធខ្ញុំបាននិយាយថាមិនអីទេ ហេតុនេះយើងបាននាំគ្នាសម្រាកនៅផ្ទះបន្តទៀត។ លុះព្រឹកឡើង ទាហានថៃបានបាញ់គ្រាប់ផ្លោងចូលមកលើទីតាំងភូមិសាស្ត្របន្ទាយអូរភ្លុកដំរី ដែលស្ថិតនៅក្នុងភូមិឯកភាព ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំនិងប្រពន្ធបាននាំគ្នារត់ចេញពីផ្ទះទៅលាក់ខ្លួននៅតាមអណ្តូងទឹក។ លុះដល់សភាពការណ៍ស្ងប់ស្ងាត់ ខ្ញុំ ប្រពន្ធ និងក្មួយម្នាក់ទៀតបាននាំគ្នារៀបចំអីវ៉ាន់ដាក់លើម៉ូតូជិះចេញពីភូមិដើម្បីទៅរកកន្លែងដែលមានសុវត្ថិភាព។ ពេលខ្ញុំកំពុងជិះម៉ូតូចេញពីផ្ទះបានបន្តិច ទាហានថៃបានបាញ់ផ្លោងជាច្រើនគ្រាប់បន្ថែមទៀត។ ខណៈពេលនោះ ខ្ញុំ និងប្រពន្ធមានការភិតភ័យយ៉ាងខ្លាំង និងជិះម៉ូតូយ៉ាងលឿនសំដៅទៅផ្ទះមេភូមិ នី ដើម្បីទៅរកកន្លែងដែលមានសុវត្ថិភាព។ បន្ទាប់មកមេភូមិ នីបានដឹកនាំខ្ញុំ និងប្រជាជនផ្សេងទៀតជម្លៀសខ្លួនចេញពីភូមិមកសម្រាកនៅក្នុងវិទ្យាល័យ ហ៊ុនសែនប្រម៉ោយ ដែលមានទីតាំងនៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ បណ្តោះអាសន្ន។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ នាយករដ្ឋមន្ត្រីកម្ពុជា និងនាយករដ្ឋមន្ត្រីថៃបានធ្វើកិច្ចចរចាពីបទឈប់បាញ់ ដែលសម្របសម្រួលដោយប្រទេសម៉ាឡេស៊ី។ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ បន្ទាប់ពីសភាពការស្ងប់ស្ងាត់ ខ្ញុំនិងប្រពន្ធបានរៀបចំរបស់របរត្រឡប់ទៅផ្ទះសម្បែងវិញ។ ពេលត្រឡប់ចូលទៅដល់ក្នុងផ្ទះ មាន់ទា ដែលខ្ញុំចិញ្ចឹមរាប់រយក្បាលបានងាប់អស់ទៅហើយ។

នៅថ្ងៃទី៧ ខែធ្នូឆ្នាំ២០២៥ ទាហានថៃបានចល័តសព្វាវុធធុនធ្ងន់ និងដាក់ពង្រាយទាហាននៅព្រំដែនថ្មដាម្តងទៀត។ ខ្ញុំនិងប្រពន្ធមិនហ៊ានសម្រាកនៅក្នុងផ្ទះទេ។ ខ្ញុំនិងប្រពន្ធបាននាំគ្នាជិះម៉ូតូចេញពីផ្ទះ ទៅសម្រាកនៅផ្ទះតា សម្បត្តិ ដែលមានទីតាំងនៅក្នុងភូមិកណ្តាល ដើម្បីត្រៀមភៀសខ្លួនទៅកន្លែងសុវត្ថិភាពពេលដែលមានការផ្ទុះអាវុធ។

នៅថ្ងៃទី៨ ខែធ្នូឆ្នាំ២០២៥ មេភូមិបានប្រកាសថាសភាពការណ៍មិនស្រួល សូមឱ្យប្រជាជនភៀសខ្លួនចេញពីភូមិជាបន្ទាន់។ ពេលនោះ ខ្ញុំបានជិះម៉ូតូចេញពីភូមិកណ្តាលសំដៅទៅវត្តគិរីបុទុម្ព ហៅវត្តប្រម៉ោយ ប៉ុន្តែដោយសារទីនៅតាំងវត្តមានប្រជាជនភៀសសឹកចូលមករស់នៅច្រើន ខ្ញុំនិងប្រពន្ធបានផ្លាស់មកស្នាក់នៅវិទ្យាល័យ ហ៊ុនសែន ប្រម៉ោយវិញ។ សម្រាប់អាហារហូបចុករបស់ខ្ញុំ គឺហូបបានគ្រប់គ្រាន់មិនមានការខ្វះខាតទេ។ ផលវិបាកដែលខ្ញុំស្នាក់នៅជំរំជនភៀសសឹកមានដូចជា អាកាសធាតុក្តៅ ខ្វះទឹកស្អាតផឹក និងប្រើប្រាស់។ បន្ទាប់ពីមានកិច្ចព្រមព្រៀងឈប់បាញ់ ខ្ញុំមិនទាន់អាចវិលត្រឡប់ទៅផ្ទះវិញបានទេ ដោយសារផ្ទះរបស់ខ្ញុំជាប់តំបន់ក្រហម។ សព្វថ្ងៃ ខ្ញុំរស់នៅក្នុងមណ្ឌលជនភៀសសឹក វិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ។

# ក្រឹង នួន៖ ប្រធានកងកុមារ ក្នុងរបបខ្មែរក្រហម

ភា រស្មី

នៅក្នុងរបបខ្មែរក្រហម ខ្ញុំចងចាំ និងមិនអាចបំភ្លេចបានពីភាពនឿយហត់នៅពេលធ្វើជាប្រធានកងកុមារ និងជួបក្មេងម្នាក់ឈ្មោះ សុភណ្ឌ ដែលតែងតែចេញដើររកអាហារនៅពេលយប់ៗ ដំបូងឡើយ ខ្ញុំមានការភ័យខ្លាច ប៉ុន្តែដោយសារការអាណិតក្មេងនោះទើបធ្វើឱ្យខ្ញុំលែងខ្លាច និងបានណែនាំឱ្យគាត់ចេញដើររកអាហារតែពេលដែលខ្ញុំត្រូវយាមនៅក្នុងកងៗ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានរត់ឡើងលើភ្នំលះបង់ ហើយនៅទីនោះ ខ្ញុំបានឃើញឪពុកម្តាយបោះបង់ចោលកូនតូចៗ និងមនុស្សស្លាប់ជាច្រើនៗ

ខ្ញុំឈ្មោះ ក្រឹង នួនអាយុ៥៨ឆ្នាំ (ក្នុងឆ្នាំ២០២១) បច្ចុប្បន្នរស់នៅភូមិបានយ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំធ្វើជាប្រធានក្រុមកងកុមារតាមការចាត់តាំងរបស់ប្រធានភូមិ។ ខ្ញុំបានដឹកនាំកុមារមូលដ្ឋានដើរបោសសំរាមតាមផ្លូវក្នុងភូមិ និងកើបអាចម៍គោ។ បន្ទាប់ពីធ្វើការងាររួច ខ្ញុំឱ្យកុមារលាងដៃ ងូតទឹក មុនពេលទៅហូបអាហារនៅរោងបាយរួម និងចូលដេក។ ក្នុងពេលជាមួយគ្នា ខ្ញុំបានឆ្លៀតពេលយកអាហារទៅឱ្យតា វង យាយអេង និងម្តាយធំរបស់ខ្ញុំឈ្មោះ ហន ដែលសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យអកយំ។ ក្រៅពីដឹកនាំកុមារធ្វើការនៅពេលថ្ងៃ ខ្ញុំត្រូវផ្លាស់ទៅយាមកុមារថ្មីចំនួន៦០នាក់ ចាប់ពីម៉ោងប្រមាណ១រំលងអធ្រាត្រ រហូតដល់ព្រឹកព្រលឹមៗ

ថ្ងៃមួយ នៅពេលដែលខ្ញុំចូលទៅរាប់កុមារនៅក្នុងរោង ខ្ញុំបានឃើញក្មេងម្នាក់ឈ្មោះ សុភណ្ឌ ដេក



ក្រឹង នួន អាយុ៥៨ឆ្នាំ (ក្នុងឆ្នាំ២០២១) សព្វថ្ងៃរស់នៅភូមិបានយ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយឃើញតែដងខ្លួនតែប៉ុណ្ណោះៗ នៅពេលឃើញដូច្នេះ ខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង ប៉ុន្តែខ្ញុំមិនបានស្រែកធ្វើឱ្យអ្នកក្បែរនោះភ្ញាក់ផ្អើលឡើយ គឺយករឿងរ៉ាវដែលខ្ញុំជួបប្រទះទៅប្រាប់ប្រធានកងរបស់ខ្ញុំ។ នៅថ្ងៃបន្ទាប់ ប្រធានកងបានប្រាប់ខ្ញុំឱ្យធ្វើការធម្មតា និងនិយាយបំភ័យខ្ញុំថា សមាជិកក្រុមរបស់ខ្ញុំឈ្មោះ សុភណ្ឌ គឺបេះអាបដែលតែងតែចេញរកអាហារពេលយប់ ប៉ុន្តែប្រធានកងរបស់ខ្ញុំមិនបានវាយសម្លាប់ សុភណ្ឌ ឡើយ ព្រោះយោគយល់ដល់ខ្ញុំៗ ពេលព្ទុដូច្នេះ ខ្ញុំបានទៅហាមឃាត់ សុភណ្ឌ កុំឱ្យចេញទៅរកអាហារហូបនៅពេល

យប់បន្តទៀតនៅពេលដែលខ្ញុំមិននៅយាមព្រោះប្រសិនបើជួបអ្នកផ្សេង សុភណ្ឌ និងមានគ្រោះថ្នាក់ ឬត្រូវខ្មែរក្រហមវាយសម្លាប់ចោល។ ចាប់តាំងពីពេលនោះមក សុភណ្ឌមិនហ៊ានចេញទៅរកអាហារផ្តេសផ្តាសបន្តទៀតទេ។ ចំណែកខ្ញុំមិនមានអារម្មណ៍ខ្លាចអាបទេ បើទោះបីខ្ញុំធ្លាប់ឃើញ សុភណ្ឌ ដេកមានតែដងខ្លួន។

ខ្ញុំបានសម្គាល់ឃើញ សុភណ្ឌ មានអាកប្បកិរិយាខុសប្លែកពីក្មេងដទៃទៀត។ នៅពេលដែលអង្គការកាត់សក់ខ្លីឱ្យក្មេងស្រីទាំងអស់នៅក្នុងកង សុភណ្ឌបានស្នើសុំកោសក់ចេញ។ មួយវិញទៀត ខ្ញុំឃើញ សុភណ្ឌមានរូបរាងស្គមស្គាំង និងមិនហូបបបរនៅរោងបាយរួមឡើយ គឺគាត់បានត្រឹមអង្គុយមើលកុមារផ្សេងទៀតហូប។ នៅពេលខ្ញុំសួរ សុភណ្ឌពីមូលហេតុដែលមិនហូបបបរ គាត់ឆ្លើយប្រាប់ខ្ញុំថាមិនឃ្លាន។

ខ្ញុំមានការអាណិតអាសូរកុមារដែលអត់ឃ្លានខ្លាំងណាស់ និងមិនដែលវាយធ្វើបាបកុមារទាំងនោះទេ ដែលផ្ទុយពីឈ្មោះ ហា គឺជាប្រធានកងកុមារនៅកងផ្សេងពីខ្ញុំ ដែលតែងតែដាក់ទណ្ឌកម្ម និងវាយធ្វើបាបកុមារដែលប្រព្រឹត្តខុសវិន័យអង្គការ។ នៅពេលខ្ញុំឃើញដូច្នេះ ខ្ញុំបានស្នើសុំប្រធានកងកុមារនោះឱ្យមានការយោគយល់ដល់កុមារដែលអត់ឃ្លាន និងកុំវាយធ្វើបាបបន្តទៀត។ ប៉ុន្តែប្រធានកងកុមារទាំងនោះមិនបានស្តាប់ហេតុផលរបស់ខ្ញុំទេ ហើយថែមទាំងធ្វើការទិតៀនខ្ញុំនៅពេលមានប្រជុំថែមទៀត។

ក្រោយមក នៅពេលខ្មែរក្រហមប្រើខ្ញុំឱ្យធ្វើការងារលំបាកខ្លាំងពេក យាយ ហ៊ានបានហៅខ្ញុំទៅធ្វើការងារនៅក្នុងអង្គភាពរបស់គាត់ដែលគ្រប់គ្រងដោយឈ្មោះ តាចាប។ នៅពេលធ្វើដំណើរយាយ ហ៊ានបាននាំខ្ញុំហែលឆ្លងទឹកស្ទឹងដោយដៃម្ខាងរបស់គាត់ចាប់អូសខ្ញុំ និងដៃម្ខាងទៀតហែលសំដៅទៅត្រើយម្ខាងទៀត។ អំឡុងពេលនៅក្នុងទឹក ខ្ញុំបានស្រែកយ៉ាងខ្លាំង ព្រោះខ្ញុំមើលទៅយាយ ហ៊ានអស់កម្លាំងយ៉ាងខ្លាំង និងប្តូរក្បាច់ហែលច្រមុជទឹកចុះឡើងរហូតដល់ខ្ញុំឈ្លក់ទឹក។

នៅពេលធ្វើដំណើរទៅដល់កន្លែងធ្វើការ យាយ ហ៊ានបានប្រាប់ប្រធានអង្គភាពថា ខ្ញុំគឺជាបងប្អូនរបស់គាត់ និងបានស្នើសុំខ្ញុំឱ្យធ្វើការងារជាមួយគាត់។ ពេលឮដូច្នេះ កម្មាភិបាលខ្មែរក្រហមបានធ្វើការប្រជុំគ្នា រួចចាត់តាំងយាយ ហ៊ានឱ្យធ្វើការងារផ្នែកជ្រលក់សម្លៀកបំពាក់ពណ៌ខ្មៅ ចំណែកខ្ញុំត្រូវកាត់ខោអាវឱ្យបាន៣០សម្រាប់ក្នុងមួយថ្ងៃ។ ខ្ញុំបានយកសាច់ក្រណាត់មកកាត់នៅពេលយប់ ហើយពេលព្រឹកយកទៅឱ្យយាយ ហ៊ានជ្រលក់ពណ៌។ បន្ទាប់មក ខ្ញុំចាប់ផ្តើមដេរខោអាវពីម៉ោងប្រមាណ៨ព្រឹក រហូតដល់រួចរាល់គ្រប់ចំនួនអង្គការកំណត់៣០សម្រាប់ទើបឈប់សម្រាក។ នៅឆ្នាំ១៩៧៨ ខ្ញុំបានផ្លាស់ការងារពីក្រុមកាត់ដេរទៅធ្វើជាប្រធានកងកុមារនៅត្រពាំងរការ និងដឹកនាំកុមារធ្វើការងារដូចពេលមុន។

រហូតដល់ដើមខែមករា ឆ្នាំ១៩៧៩ អំឡុងពេលខ្ញុំដឹកនាំកុមារដើរកើបអាចម៍គោ ស្រាប់តែខ្ញុំឮប្រជាជនស្រែកថា កងទ័ពវៀតណាមវាយចូលមកហើយ។ នៅពេលនោះ មានការចលាចលយ៉ាងខ្លាំង ខ្ញុំបានរត់ទៅតាមរទេះគោយាយ សឿន ដែលបរចេញពីភូមិ ដោយនៅលើរទេះមានតាចាស់ជរាម្នាក់ឈ្មោះ ប្រាក់ កំពុងសម្រាន្ត។ ខ្ញុំបានជិះរទេះរយៈពេលមួយយប់ និងមួយថ្ងៃ ទើបទៅដល់ម្តុំពោធិ៍រៀល ហើយបានឈប់សម្រាកនៅទីនោះ។ នៅពោធិ៍រៀល អង្គការបានសម្លាប់សត្វគោមួយក្បាលដើម្បីធ្វើម្ហូបឱ្យប្រជាជនជម្លៀសរាប់រយនាក់ហូប។ បន្ទាប់មក ខ្ញុំបានជិះរទេះគោបន្តរហូតដល់ភ្នំលះបង់ទើបនាំគ្នាបោះបង់ចោលរទេះ និងគោ ព្រោះត្រូវធ្វើដំណើរឡើងទៅលើភ្នំ។ ខ្ញុំបានទៅសុំខមាទោស និងសេចក្តីសុខពីតា ប្រាក់ ព្រោះមិនអាចនាំយកគាត់ទៅជាមួយ ហើយប្រសិនបើខ្ញុំមិនព្រមឡើងភ្នំ ខ្មែរក្រហមនឹងវាយសម្លាប់ខ្ញុំ។

នៅលើភ្នំលះបង់ ខ្ញុំបានឃើញខ្មែរក្រហមបង្ខំឪពុកម្តាយឱ្យបោះបង់កូនរបស់ខ្លួនឱ្យយំនៅតាមផ្លូវជាច្រើននាក់ និងបង្ខំឱ្យធ្វើដំណើរទៅមុខជាបន្តទៀត ហើយ

ប្រសិនបើមានអ្នកមិនធ្វើតាម ខ្មែរក្រហមនឹងសម្លាប់ចោល។ កុមារដែលឪពុកម្ដាយបោះបង់ចោល ទាំងនោះគួរឱ្យអាណិតខ្លាំងណាស់ ដោយកុមារខ្លះត្រូវសត្វទាកខាំពេញខ្លួន និងចូលក្នុងរន្ធត្រចៀក។

ពេលខ្ញុំធ្វើដំណើរទៅមុខបានបន្តិច ខ្ញុំបានឃើញមនុស្សដេកស្លាប់ និងសាកសពហើមនៅតាមផ្លូវ។ នៅក្នុងចំណោមអ្នកស្លាប់ទាំងអស់ ខ្ញុំស្គាល់គ្រួសារឈ្មោះង៉ូយ និងគ្រួសារឈ្មោះ ផុលបានស្លាប់ដោយអត់អាហារ និងសត្វទាកខាំ។ ម្យ៉ាងវិញទៀត ខ្ញុំបានឃើញស្ត្រីពោះធំម្នាក់ឈឺពោះកើតកូននៅលើភ្នំលះបង់ ប៉ុន្តែនៅពេលកូនកើតរួចម្ដាយបានបោះកូនចោលឱ្យយំនៅក្នុងព្រៃ ព្រោះខ្លាចខ្មែរក្រហមមិនអនុញ្ញាតឱ្យធ្វើដំណើរទៅជាមួយ។

នៅលើភ្នំលះបង់តាសឹមបានយកពងមាន់៣គ្រាប់មកឱ្យខ្ញុំ និងស្នើសុំខ្ញុំធ្វើជាកូនធម៌របស់គាត់។ ចាប់តាំងពីពេលនោះមក ខ្ញុំលែងជួបប្រទះការអត់ឃ្លានទៀតហើយ ព្រោះឪពុកធម៌របស់ខ្ញុំបានស្ពាយអង្ករពីរទៃមកជាមួយ ហើយក្នុងមួយពេលគាត់យកអង្ករមួយកំប៉ុងតែប៉ុណ្ណោះមកដាំបបរហូបទាំងអស់គ្នា។ នៅពេលធ្វើដំណើរ ខ្ញុំនិងប្រជាជនទាំងអស់ខ្លាចកងទ័ពវៀតណាមខ្លាំងណាស់ និងរួតរះបន្តដំណើរទៅដល់ទឹកជ្រោះមួយកន្លែង ក្នុងស្រុកវាលវែង។



កងកុមារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅទីតាំងទឹកជ្រោះ ខ្មែរក្រហមបានបង្ខំប្រជាជនឱ្យតោងខ្សែព្រួរសម្រូតខ្លួនចុះមកក្រោមបន្តគ្នា ហើយខ្ញុំត្រូវតោងឪពុកធម៌របស់ខ្ញុំចុះពីជ្រោះមកមុន ដោយទុកប្រពន្ធរបស់គាត់រង់ចាំនៅលើភ្នំ។ នៅពេលរអិលម្ដងៗ ខ្ញុំស្ទើរតែតោងឪពុកធម៌របស់ខ្ញុំមិនជាប់ព្រោះទឹកហូរខ្លាំងពេក។ ពេលខ្ញុំចូលដល់ក្នុងស្ទឹង ឪពុកធម៌របស់ខ្ញុំបាននាំខ្ញុំហែលទៅរកកន្លែងសុវត្ថិភាព។ ប្រសិនបើមិនមានឪពុកធម៌ជួយ ខ្ញុំប្រហែលត្រូវស្លាប់នៅក្នុងព្រៃនោះតែម្ដង គឺស្លាប់ដោយសារអត់អាហារ និងនៅពេលតោងខ្សែព្រួរសម្រូតចុះតាមទឹកជ្រោះ។

នៅពេលមកដល់ក្រោម ខ្ញុំ និងប្រជាជនផ្សេងទៀតបានធ្វើដំណើររហូតទៅដល់ភូមិត្បែង។ នៅទីនោះ ខ្ញុំបានជួបជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមដែលស្រែកហៅប្រជាជនកុំឱ្យរត់គេចខ្លួនបន្តទៀត ព្រោះកងទ័ពវៀតណាមមកនាំត្រឡប់ទៅផ្ទះសម្បែងវិញ។ ពេលឮដូច្នេះ ខ្ញុំមិនបានបន្តដំណើរទៅមុខទៀតទេ លើកលែងតែប្រជាជនមួយចំនួនទៀតដែលមានការភ័យខ្លាចខ្លាំង បានបន្តរត់គេចខ្លួនភ្លាមៗអស់ជាងពាក់កណ្ដាល។

នៅតាមផ្លូវធ្វើដំណើរ កងទ័ពស្ម័គ្រចិត្តវៀតណាមបានចែកអង្ករឱ្យប្រជាជនម្នាក់មួយបាវ ព្រមទាំងយាមការពារប្រជាជនទាំងយប់ទាំងថ្ងៃ ព្រោះពេលនោះមានយោធាខ្មែរក្រហមចូលមកសម្លាប់ និងកៀរប្រជាជនត្រឡប់ចូលព្រៃវិញ។ ក្រោយមក ខ្ញុំបានធ្វើដំណើរត្រឡប់មកស្រុកកំណើតនៅខេត្តតាកែវវិញ។ បើទោះបីរបបខ្មែរក្រហមបានកន្លងទៅជាយូរឆ្នាំហើយ ខ្ញុំនៅតែមានអារម្មណ៍ខឹងនឹងខ្មែរក្រហម ព្រោះធ្វើឱ្យខ្ញុំជួបការលំបាក។

# ដួង សាម៉ុន ៖ គ្រូបង្រៀនកុមារ ក្នុងរបបខ្មែរក្រហម

ស្រេង លីដា

«រឿងរ៉ាវលំបាកវេទនានៃការធ្វើការងារហួសកម្លាំង របបអាហារលាយដើមល្ហុងមិនឆ្អែតក្រពះ និងការបាត់បង់មិត្តរួមក្រុមចល័តជិត២០នាក់ ដែលត្រូវខ្មែរក្រហមដឹកយកទៅសម្លាប់ក្នុងព្រៃ គឺជាស្រមោលអតីតកាលដ៏ឈឺចាប់ដែលខ្ញុំមិនអាចបំភ្លេចបាន។ ប៉ុន្តែភាពត្រជាក់ត្រជុំ និងការស្តារឡើងវិញនូវសណ្តាប់ធ្នាប់ភូមិឃុំក្រោយថ្ងៃរំដោះ បានប្រែក្លាយទំព័រជីវិតថ្មីនៅលើទឹកដីបុរីអូរស្វាយសែនជ័យរបស់ខ្ញុំ» ។

ខ្ញុំឈ្មោះ ដួង សាម៉ន អាយុ៧៦ឆ្នាំ កើតនៅភូមិកាំងដីសរ សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ បច្ចុប្បន្នខ្ញុំមករស់នៅភូមិអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ។ ឪពុករបស់ខ្ញុំឈ្មោះ ដួង ញាណ (ស្លាប់) និងម្តាយឈ្មោះ ម៉ែន ធា (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើតចំនួន៣នាក់ ក្នុងនោះមានប្រុសម្នាក់។ កាលពីក្មេងខ្ញុំរៀនបានត្រឹមថ្នាក់ទី៩ ពីសង្គមចាស់។ ខ្ញុំបានរៀបការនៅក្នុងឆ្នាំ១៩៧៧ ជាមួយប្តីឈ្មោះ ម៉ាន់ លីហ៊ គឺជាយោធាខ្មែរក្រហម ចំណែកខ្ញុំគឺជាប្រធានកងចល័តមើលការខុសត្រូវសមាជិកចំនួន១០០នាក់។ ក្រោយរៀបការ ប្តីប្រពន្ធខ្ញុំមានកូនប្រុសចំនួន៣នាក់។

ខ្ញុំគឺជាអ្នកចំណូលថ្មីមកពីខាងភូមិកាំងដីសរ ចំណែកប្តីរបស់ខ្ញុំមានស្រុកកំណើតដើមនៅអូរស្វាយ ឃុំអូរស្វាយ នេះតែម្តង។ ខ្ញុំធ្លាប់ឮប្តីនិយាយថា កាលសម័យសង្គមរាស្ត្រនិយម ព្រះករុណា សម្តេចព្រះនរោត្តម សីហនុ ព្រះអង្គបានរៀបចំបង្កើតភូមិអូរស្វាយ និងកសាងផ្ទះកាឡុងជាច្រើនខ្នង ដើម្បីចែកជូនប្រជាជនរស់នៅ ដោយក្នុងនោះឪពុកក្មេករបស់ខ្ញុំបានទទួលផ្ទះមួយខ្នងពីព្រះអង្គ។



ដួង សាម៉ន (រូបខាងស្តាំ) អាយុ៧៦ឆ្នាំ បច្ចុប្បន្នរស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហម ដល់អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្តេចព្រះ នរោត្តម សីហនុបានកសាងតំបន់នេះឡើងក្នុងគោលបំណងការពារទឹកដីមាតុភូមិ កុំឱ្យមានប្រទេសជិតខាងមកឈ្លានពាន និងបៀតបៀន។ ព្រះអង្គបានកសាងទាំងស្តូបអនុស្សាវរីយ៍ មន្ទីរពេទ្យ រោងតម្បាញ និងរចនាសម្ព័ន្ធផ្លូវខ្វាត់ខ្វែង។

នៅពេលដែលរបបខ្មែរក្រហមចូលមកដំបូង ខ្មែរក្រហមបានជម្លៀសប្រជាជននៅឃុំអូរស្វាយ ទាំងអស់ឱ្យទៅរស់នៅតំបន់ញើន។ កាលនោះប្រជាជនត្រូវជម្លៀសដោយថ្មើរជើង។ ខ្មែរក្រហមបានគំរាម និង

បំភ័យប្រជាជនថា៖ «ប្រសិនបើអ្នកណាមិនព្រមចាកចេញ នោះអាមេរិកាំងនឹងមកទម្លាំងគ្រាប់បែក»។ ពេលទៅដល់តំបន់ញើន ខ្មែរក្រហមបានបង្ខំប្រជាជនឱ្យធ្វើស្រែចម្ការ និងលើកទំនប់រួម ទាំងរៀបចំប្រជាជនឱ្យហូបរួមគ្នា ដោយមួយថ្ងៃហូប៣ពេល ប៉ុន្តែក្នុងមួយពេលៗ គឺប្រជាជនទទួលបានបបរតែមួយកូនចានចង្កឹះតែប៉ុណ្ណោះ ដែលធ្វើឱ្យប្រជាជនជួបប្រទះការអត់ឃ្លាន និងលំបាកវេទនាយ៉ាងខ្លាំង។ ដោយឡែក ពេលខ្មែរក្រហមឡើងកាន់អំណាច នៅខែមេសា ឆ្នាំ១៩៧៥ ខ្ញុំកំពុងរស់នៅភូមិកាំងជីសរនៅឡើយ។ ដំបូងខ្មែរក្រហមមិនទាន់រឹតបន្តឹងខ្លាំងទេ ប៉ុន្តែយូរៗទៅការគ្រប់គ្រងរបស់ខ្មែរក្រហមកាន់តែសាហាវឃោរឃៅ និងបង្ខំប្រជាជនឱ្យធ្វើការងារធ្ងន់ ព្រមទាំងផ្ដល់អាហារឱ្យប្រជាជនតែបន្តិចបន្តួចតែប៉ុណ្ណោះ។ ខ្មែរក្រហមបានរៀបចំតុវែងៗឱ្យប្រជាជនអង្គុយហូបអាហាររួមគ្នា ដោយបែងចែកអាហារក្នុងមនុស្សម្នាក់បបរមួយកូនចានតូចតែប៉ុណ្ណោះ។ កាលនោះ ខ្ញុំមានតួនាទីជាគ្រូបង្រៀនថ្នាក់ទី៣ ដោយអង្គការតម្រូវឱ្យខ្ញុំបង្រៀនក្មេងៗនៅពេលព្រឹក ហើយពេលរសៀល ខ្ញុំត្រូវចុះទៅធ្វើការងារស្រែចម្ការជាមួយប្រជាជនដទៃទៀត។ ខ្ញុំខំប្រឹងប្រែងធ្វើស្ទើរគ្មានពេលសម្រាក។ ចំពោះប្រជាជនពេលព្រឹកធ្វើការនៅវាលស្រែដោយអង្គការយកដំឡូងស្ងោរមកឱ្យហូបនៅការដ្ឋានរហូតដល់ថ្ងៃត្រង់ទើបឡើងទៅហូបបាយនៅរោងសហករណ៍រួម។ នៅវេលាម៉ោង៦ល្ងាច ប្រជាជនហូបបាយម្ដងទៀត រួចហើយត្រូវចុះទៅធ្វើស្រែបន្តទាំងយប់ ដោយប្រធានសហករណ៍ដាក់អំពូលភ្លើងអគ្គិសនីបំភ្លឺដើម្បីធ្វើការរហូតដល់ម៉ោង៩យប់ទើបអនុញ្ញាតឱ្យសម្រាក។ នៅរដូវច្រូតកាត់ ខ្មែរក្រហមធ្វើលានបោកបែនយ៉ាងស្អាត និងលាបដោយអាចម៍គោ អាចម៍ក្របី ហើយផលស្រូវដែលប្រមូលផលបាន ខ្មែរក្រហមដឹកយកទៅរក្សាទុកក្នុងជង្រុកស្រូវធំៗ។ សម្រាប់ក្មេងៗ ប្រធានកងថ្លឹងបាយចែកឱ្យម្នាក់៣ខាំតែប៉ុណ្ណោះ ធ្វើឱ្យឪពុកម្ដាយខ្លះអាណិតកូនពេក សុខចិត្តផ្ទេរចំណែករបស់ខ្លួនឯងឱ្យទៅកូនហូប។ ម្ហូបអាហារប្រចាំថ្ងៃក្នុងរបបខ្មែរក្រហមគឺមានតែទឹកគ្រឿង និងត្រួយដំឡូង ចំណែកបាយគឺដាំលាយជាមួយគ្រាប់ពោត។

នៅក្នុងរបបខ្មែរក្រហម អង្គការបានបែងចែកប្រជាជនតាមក្រុម ដោយនៅម្ខាងមាត់ទន្លេមានក្រុមនេសាទត្រី ក្រុមដាំបន្លែ និងក្រុមចុងភៅ។ កាលនោះ ខ្មែរក្រហមមានវិន័យតឹងតែងខ្លាំងណាស់ ប្រសិននរណាម្នាក់ហ៊ានលួចចាប់ត្រីយកមកហូបផ្ទាល់ខ្លួន ឬធ្វើខុសនឹងគោលការណ៍ដែលថ្នាក់លើបានកំណត់ នោះនឹងត្រូវចាប់យកទៅសម្លាប់ចោលភ្លាមៗ។ រឿងរ៉ាវដ៏រន្ធត់ និងប៉ះពាល់ផ្លូវចិត្តដែលខ្ញុំចងចាំមិនអាចបំភ្លេចក្នុងជីវិត គឺការបាត់ខ្លួនសមាជិកនៅក្នុងកងចល័តរបស់ខ្ញុំ។ កងចល័តខ្ញុំមានសមាជិកជិត២០នាក់ ត្រូវឈ្លបខ្មែរក្រហមចាប់ជាបន្តបន្ទាប់ និងដឹកយកទៅសម្លាប់នៅម្តុំ «គីឡូម៉ែត្រលេខ៨» តាមផ្លូវទៅអូរពងមាន់។ ឈ្លបខ្មែរក្រហមសម្លាប់ប្រជាជនចោលក្នុងព្រៃយ៉ាងព្រៃផ្សៃ ព្រោះខ្ញុំបានឃើញសម្លៀកបំពាក់អ្នកស្លាប់គរនៅក្នុងព្រៃ។ អ្នកដែលត្រូវអង្គការយកទៅសម្លាប់ ភាគច្រើនជាអ្នកជម្លៀសមកពីទីក្រុងភ្នំពេញ និងមានឋានៈខ្ពង់ខ្ពស់ ដោយខ្មែរក្រហមចោទប្រកាន់ថាជាវណ្ណៈពុករលួយ។ ខ្មែរក្រហមបានភូតកុហកជនរងគ្រោះថា «នាំយកទៅកាប់ឆ្ការដីចម្ការ» ប៉ុន្តែតាមពិតគឺយកទៅសម្លាប់ចោល។ ប្រជាជនខ្លះដឹងខ្លួនថាឈ្លបខ្មែរក្រហមនឹងយកទៅសម្លាប់ គឺបានត្រឹមតែអង្គុយយំសោកបោកខ្លួន។ ខ្ញុំអាណិតប្រជាជនថ្មីទាំងនោះខ្លាំងណាស់។

នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានហៅខ្ញុំទៅជួប និងប្រាប់ខ្ញុំថាមានយោធាម្នាក់មកស្នើខ្ញុំរៀបការ។ ដោយសារតែខ្ញុំខ្លាចខ្មែរក្រហម ខ្ញុំមិនហ៊ានប្រកែកឡើយ គឺបានយល់ព្រមរៀបការជាមួយប្ដីរបស់ខ្ញុំ។ ក្រោយមកទៀត ខ្មែរក្រហមមានផែនការជម្លៀសខ្ញុំទៅខេត្តរតនគិរីដើម្បីចិញ្ចឹមដង្កូវនាង សម្រាប់ត្បាញសូត្រ ប៉ុន្តែសំណាងល្អនៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលមករំដោះ ដោយពេលនោះខ្ញុំកំពុងស្ថិតនៅតំបន់អូរស្វាយ។

ក្រោយថ្ងៃរំដោះភ្លាមៗ សភាពការណ៍មានភាពធូរស្រាលឡើងវិញ ហើយខ្ញុំលែងមានការភ័យខ្លាច និងលំបាកវេទនាដូចមុនទៀតហើយ។ ប្រជាជនដែលនៅសេសសល់បាននាំគ្នាវិលត្រឡប់មកផ្ទះវិញ ប្រជាជនខ្លះស្នាក់នៅតាមវត្តអារាមបណ្តោះអាសន្ន។ ខ្ញុំបានសម្រេចចិត្តមករស់នៅភូមិអូរស្វាយ ដែលជាស្រុកកំណើតខាងប្តីរហូតមក ដោយសារនៅខាងភូមិកំណើតខ្ញុំមិនមានដីធ្លីសម្រាប់បង្កបង្កើនផល។ ក្រោយរបបខ្មែរក្រហមដួលរលំ យើងបានប្រកបមុខរបរធ្វើស្រែចម្ការ ប៉ុន្តែយើងធ្វើបាន៣ឆ្នាំទើបឈប់ ដោយសារប្តីរបស់ខ្ញុំត្រូវចូលបម្រើការងាររដ្ឋបាលឃុំ។ ប្រជាជននៅតំបន់អូរស្វាយភាគច្រើនគឺរស់ដោយសារការធ្វើស្រែចម្ការ និងនេសាទត្រីលក្ខណៈគ្រួសារ។

នៅក្នុងឆ្នាំ២០០២ ប្តីរបស់ខ្ញុំបានជាប់ឆ្នោតធ្វើជាមេឃុំនៅក្នុងស្រុកបុរីអូរស្វាយ។ នៅក្នុងអាណត្តិដឹកនាំរបស់គាត់ គាត់បានខិតខំរៀបចំភូមិឃុំឱ្យមានសណ្តាប់ធ្នាប់ល្អ ព្រមទាំងបានស្ថាបនាផ្លូវលំក្រាលគ្រួសក្រហមបានស្អាត ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ និងដឹកជញ្ជូនកសិផល។ ចំណែកខ្ញុំសព្វថ្ងៃមានជំងឺប្រចាំកាយ ដូចជា ជំងឺលើសឈាម ឈឺក្បាល វិលមុខ ព្រមទាំងឈឺចុកចាប់តាមគន្លាក់ដៃ និងគន្លាក់ជើង ដែលធ្វើឱ្យការរស់នៅប្រចាំថ្ងៃមានការលំបាក។



សាលារៀនកុមារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៧៧។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឈិត ឆេង ៖ កុមារជនជាតិដើមភាគតិចព័រ នៅក្នុងរបបខ្មែរក្រហម

មឿន ស្រីណុច

ខ្ញុំឈ្មោះ ឈិត ឆេង អាយុ៦៣ឆ្នាំ កើតនៅភូមិទួលគ្រួស ឃុំស្រែសាំងយ៉ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍-សាត់។ បច្ចុប្បន្ន ខ្ញុំរស់នៅជាមួយប្អូនស្រីបង្កើតដែលប្រកបរបរធ្វើស្រែចម្ការ និងចិញ្ចឹមក្របី នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ប៉ោយ ឈិត ស្លាប់ក្នុងរបបខ្មែរក្រហម និងម្តាយឈ្មោះ សេក ទុប ស្លាប់ក្នុងឆ្នាំ១៩៧៩ ដោយសារជំងឺ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់ ក្នុងនោះមានស្រី៣នាក់ ហើយខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ។ ប្អូនប្រុសតែម្នាក់របស់ខ្ញុំបានស្លាប់ក្នុងរបបខ្មែរក្រហមដោយសារអត់អាហារ។



ឈិត ឆេង អាយុ៦៣ឆ្នាំ បច្ចុប្បន្នរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីនៅក្មេង ខ្ញុំមិនបានចូលរៀនទេ ព្រោះត្រូវជួយធ្វើស្រែចម្ការឪពុកម្តាយដែលមានជីវភាពខ្វះខាត។ ខ្ញុំចាំបានថា ឪពុកខ្ញុំបន្ទាប់ពីប្រមូលផលស្រូវហើយរួចរាល់ គាត់ត្រូវធ្វើដំណើរចេញពីភូមិទួលគ្រួសចូលទៅក្នុងព្រៃជ្រៅ ដើម្បីរកជ័រទឹក ជ័រចុង ខ្លឹមចន្ទន៍ យកទៅលក់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ជារៀងរាល់មួយឆ្នាំម្តង ជនជាតិដើមភាគតិចព័របានប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ហើយក្មេងៗជនជាតិដើមភាគតិចព័រ ទាំងអស់តែងតែនាំគ្នាលេងល្បែងប្រជាប្រិយយ៉ាងសប្បាយរីករាយមានដូចជា បោះឈូង ទាញព្រាត់ លាក់កន្សែងបោះអង្គុញ និងល្បែងប្រជាប្រិយជាច្រើនទៀត នៅក្នុងវត្ត តាមផ្ទះ ដើម្បីអបអរពិធីចូលឆ្នាំថ្មី និងមានពិធីបុណ្យប្រពៃណីជាច្រើនរួមមាន ពិធីបុណ្យភ្ជុំបិណ្ឌ ពិធីបុណ្យកឋិនទាន និងពិធីបុណ្យពូនភ្នំស្រូវ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់ សម្តេចព្រះនរោត្តម សីហនុ ចេញពីតំណែង។ នៅអំឡុងពេលជាមួយគ្នាក្នុងភូមិទួលគ្រួសមិនមានចលាចល ឬហេតុការណ៍អ្វីកើតឡើងឡើយ គឺជនជាតិដើមភាគតិចព័រអាចប្រកបរបរធ្វើស្រែចម្ការបានធម្មតា។

នៅឆ្នាំ១៩៧៣ ខ្ញុំបានឮសំឡេងយន្តហោះទម្លាក់គ្រាប់បែកនៅភូមិតាលោ (បច្ចុប្បន្ននៅក្នុងស្រុកតាលោសែនជ័យ) ស្ថិតនៅខាងជើងភូមិទួលគ្រួស។ គ្រាប់បែកបានលាន់ឮពាសពេញភូមិ ធ្វើឱ្យប្រជាជនមានភាពភ័យខ្លាច និងបាននាំគ្នាជីកលេណដ្ឋានដើម្បីលាក់ខ្លួននៅក្បែរៗព្រៃខាងក្រោយផ្ទះ។ ក្រោយមក

មានយន្តហោះរបស់ទាហានអាមេរិកបានហោះមកឆ្វែលជុំវិញភូមិទួលគ្រួសជារៀងរាល់ថ្ងៃ ជាហេតុធ្វើឱ្យជនជាតិដើមភាគតិចព័ររស់នៅក្នុងភូមិទួលគ្រួសមានការភ័យខ្លាចតក់ស្លុតខ្លាំង ហើយក្រុមគ្រួសារមួយចំនួនបាននាំកូនចៅចាកចេញពីភូមិទួលគ្រួសទៅរស់នៅក្នុងលេណដ្ឋាន និងគ្រួសារមួយចំនួនទៀតរត់ចូលទៅក្នុងព្រៃជ្រៅ ប៉ុន្តែក្នុងភូមិទួលគ្រួសមិនមានការទម្លាក់គ្រាប់បែកទេ។ ចំណែកឪពុកម្តាយរបស់ខ្ញុំបាននាំកូនៗទាំងអស់រត់ចេញពីផ្ទះសំដៅទៅសម្ងំពួនក្នុងព្រៃ និងបានសាងសង់ខ្ទមតូចប្រក់ពីស្លឹកសំឡាញនៅតាមមាត់អូរទុកសម្រាប់ឱ្យកូនៗស្នាក់នៅបណ្តោះអាសន្ន។ ឪពុកម្តាយរបស់ខ្ញុំបានស្នាក់នៅក្នុងព្រៃរយៈពេលប្រហែល២សប្តាហ៍ ទើបនាំកូនៗត្រឡប់មករស់នៅក្នុងភូមិវិញ។

នៅក្នុងឆ្នាំ១៩៧៤ កងទ័ពខ្មែរក្រហមបានចូលមកគ្រប់គ្រងក្នុងភូមិទួលគ្រួសបានទាំងស្រុង និងចាប់ផ្តើមបែងចែកជនជាតិដើមភាគតិចព័រទាំងអស់ឱ្យធ្វើស្រែប្រវាស់ដៃគ្នា។ ដំបូងខ្មែរក្រហមមិនទាន់ប្រើឱ្យប្រជាជនធ្វើការងារធ្ងន់ធ្ងរទេ គឺប្រជាជនអាចស្នាក់នៅ និងហូបបាយនៅតាមផ្ទះរៀងៗខ្លួនបានគ្រប់គ្រាន់។ ជនជាតិដើមភាគតិចព័រទាំងអស់ត្រូវខិតខំធ្វើស្រែ និងចែកផលស្រូវស្មើគ្នា។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយដណ្តើមបានទីក្រុងភ្នំពេញ និងទទួលបានជ័យជម្នះទៅលើរបប លន់ នល់។ បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញបានមួយរយៈ ខ្មែរក្រហមបានចាប់ផ្តើមបង្កើតសហករណ៍ឈ្មោះ «សហករណ៍ស្រែតាំងយ៉» និងបានប្រមូល ចាន ឆ្នាំង មាស ប្រាក់ គោ ក្របី ជ្រូក មាន់ ទា និងទ្រព្យសម្បត្តិរបស់ជនជាតិដើមភាគតិចព័រដាក់ក្នុងសហករណ៍រួម និងឱ្យប្រជាជនមកហូបចុក ធ្វើការងារ និងស្នាក់នៅរួមគ្នាក្នុងសហករណ៍។ បន្តមក ខ្មែរក្រហមបានបែងចែកប្រជាជនឱ្យទៅធ្វើការងារនៅតាមទីកន្លែងផ្សេងៗពីគ្នា ដែលមានកងកុមារ កងយុវជនយុវនារី និងកងមនុស្សចាស់ៗ។ ខ្ញុំ និងប្អូនៗតូចៗត្រូវខ្មែរក្រហមជ្រើសរើសឱ្យចូលធ្វើការងារនៅក្នុងកងកុមារ ដែលគ្រប់គ្រងដោយ តាយាន ឡឿន (ជនជាតិព័រ) និងមានកុមារសរុបប្រមាណ៥០នាក់។ នៅក្នុងចំណោមកុមារទាំង៥០នាក់ តា យាន ឡឿន បានបែងចែកជាក្រុមតូចៗ គឺក្នុងមួយក្រុមមានកុមារចំនួន១៥ទៅ២០នាក់។ ដំបូង ខ្ញុំ និង ប្អូនៗ ត្រូវបានខ្មែរក្រហមចាត់តាំងឱ្យដើរកាត់ដើមទន្ទ្រានខេត្រ ប្រមូលលាមកសត្វ ដើម្បីលាយធ្វើជីដាក់ស្រែ។ តាយាន ឡឿន មានចិត្តល្អ និងមិនដែលធ្វើបាបកុមារទេ។ ចំណែកឪពុកម្តាយរបស់ខ្ញុំ ត្រូវបានខ្មែរក្រហមចាត់តាំងឱ្យធ្វើការក្នុងកងចាស់ៗ និងធ្វើស្រែនៅសហករណ៍ស្រែតាំងយ៉។ ចំណែករបបអាហារ ខ្ញុំហូបបាយលាយជាមួយសម្លបានគ្រប់គ្រាន់។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវប្តូរមកធ្វើការងារធ្ងន់ធ្ងរជាងមុន ហើយការងារដែលខ្ញុំត្រូវធ្វើជាប្រចាំថ្ងៃមានដូចជា ដកសំណាប ស្ទូងស្រូវ ដឹកជញ្ជូនកណ្តាប់បែនស្រូវ កាប់ដី លើកភ្លឺស្រែ ជីកប្រឡាយតាមស្រែក្នុងភូមិទួលគ្រួស និងលើកទំនប់អូរធំ (បច្ចុប្បន្នស្ថិតក្នុងភូមិទួលគ្រួស)។ ប្រធានកងបានកំណត់ក្នុងមួយក្រុមមានគ្នាប្រហែល១៥នាក់ឱ្យលើកទំនប់ក្នុងមួយព្រឹកមានប្រវែងទទឹង១ម៉ែត្រ និងបណ្តោយមានប្រវែង១០ម៉ែត្រឱ្យហើយ។ ប្រសិនបើកុមារលើកទំនប់មិនហើយតាមការកំណត់ ត្រូវនៅលើកឱ្យបានរួចរាល់ទើបអាចឈប់សម្រាកហូបបាយ។ បន្ទាប់ពីធ្វើការងារស្រែចម្ការ និងជីកប្រឡាយ ខ្ញុំនិងក្រុមកុមារទាំងអស់ត្រូវបានខ្មែរក្រហមប្រើឱ្យទៅកាប់ដី និងលើកភ្លឺស្រែបន្ត។ ខ្ញុំធ្វើការងារមិនមានពេលវេលាសម្រាកទេ និងហត់នឿយខ្លាំងណាស់ៗ រីឯការហូបចុកមានការលំបាកជាងមុន ដោយខ្មែរក្រហមបានចែកបាយលាយជាមួយពោតក្រហម ដំឡូង ហូបជាមួយសម្លមិនមានជីវជាតិ។ ខ្ញុំនិងមិត្តនៅក្នុងកង ហូបមិនបានគ្រប់គ្រាន់ទេបណ្តាលឱ្យសុខភាពទន់ខ្សោយ ស្គមស្គាំង និងអស់កម្លាំង។ នៅពេលហូបបាយ ខ្ញុំត្រូវទៅហូបនៅបាយរោងរួមក្នុងការដ្ឋាន។ ខ្ញុំត្រូវអង្គុយឱ្យចំកន្លែងដែលចុងភៅកំណត់ បើអង្គុយខុសកន្លែង ចុងភៅមិនផ្តល់របបអាហារឱ្យទេ។ នៅក្នុងរោងបាយមានតុវែង ហើយកុមារត្រូវ

អង្គុយទល់មុខគ្នា និងមានកូនចានសម្លរមួយសម្រាប់កុមារបួននាក់។

នៅឆ្នាំ១៩៧៧ ខ្ញុំនិងយុវនារីជនជាតិដើមភាគតិចព័រចំនួន៥នាក់ទៀត ត្រូវអង្គការជម្លៀសចេញពីភូមិទួលគ្រួសដោយធ្វើដំណើរតាមរថយន្ត ទៅកាន់ស្រុកភ្នំក្រវាញ ដោយមិនបានប្រាប់មូលហេតុជាមុន។ នៅពេលយើងធ្វើដំណើរដល់ភូមិព្រែក (បច្ចុប្បន្នភូមិព្រែក៣ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់) ខ្មែរក្រហមបានបញ្ជូនក្រុមខ្ញុំបន្តតាមទូកឆ្លងស្ទឹងពីភូមិព្រែក ទៅកាន់ភូមិលាច (បច្ចុប្បន្នផ្សារភ្នំក្រវាញ) ដើម្បីកាត់ដេរសម្លៀកបំពាក់។ នៅអង្គភាពកាត់ដេរមានកម្មការិនីប្រមាណ១០០នាក់។ ការងារប្រចាំថ្ងៃរបស់ខ្ញុំគឺកាត់សម្លៀកបំពាក់ ក្រៅពីនោះត្រូវធ្វើការងារតាមការចាត់តាំងរបស់ប្រធានអង្គភាព។

ក្រោយមក ខ្មែរក្រហមបញ្ជូនជនជាតិដើមភាគតិចព័រចំនួន២នាក់មកពីភូមិទួលគ្រួស ឈ្មោះ ថៃ នេន ភេទស្រី និងម្នាក់ទៀតដែលខ្ញុំមិនចាំឈ្មោះឱ្យមកកាត់ដេរជាមួយខ្ញុំ។ ខ្ញុំបានដឹងតាមរយៈ ថៃ នេន ថា ឪពុកម្តាយ និងប្អូនខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសមកស្រុកភ្នំក្រវាញដែរ ប៉ុន្តែខ្ញុំមិនបានជួបឪពុកម្តាយ និងប្អូនៗឡើយ។ សម្លៀកបំពាក់ដែលខ្ញុំកាត់ដេររួច ខ្មែរក្រហមបញ្ជូនទៅចែកឱ្យកម្មាភិបាលតាមភូមិ ឃុំ ស្រុក និងបញ្ជូនទៅឱ្យកងទ័ព។ ខ្ញុំធ្វើការងារគឺចាប់ពីម៉ោង៧ព្រឹក រហូតដល់ម៉ោង ៥ល្ងាច ទើបឈប់សម្រាក។ បន្ទាប់ពីហូបបាយពេលល្ងាចរួច ខ្ញុំត្រូវដាំ ស្ពៃ ត្រកួន ត្រសក់ ល្ពៅ ត្រឡាច និងបន្លែជាច្រើនទៀត ទុកផ្គត់ផ្គង់ក្នុងការដ្ឋាន។ ការហូបចុករបស់ខ្ញុំ និងកម្មការិនីកាត់ដេរគឺហូបបានគ្រប់គ្រាន់ មិនមានការខ្វះខាតទេ ព្រោះប្រធានអង្គភាពកាត់ដេរឈ្មោះ តា ថាស មានចរិតស្លូតបូត និងចិត្តល្អ។ ក្រៅពីការងារកាត់ដេរសម្លៀកបំពាក់ ខ្មែរក្រហមបានបញ្ជូនក្រុមខ្ញុំឱ្យទៅជួយធ្វើស្រែប្រជាជននៅតាមកងចល័តក្នុងឃុំលាច។ នៅពេលថ្ងៃ ខ្ញុំធ្វើការងារដកស្ទូង និងប្រូតកាត់ លុះដល់ពេលយប់ឡើង ខ្ញុំត្រូវចិញ្ច្រាំដីយកទៅដាក់ក្នុងស្រែ ឬបោកកណ្តាប់រហូតដល់ម៉ោង៩ ទៅម៉ោង១០យប់ ទើបឈប់សម្រាក។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយចូលមកដល់ស្រុកភ្នំក្រវាញ។ ក្នុងពេលជាមួយគ្នា ខ្ញុំមិនបានរត់ចេញពីស្រុកភ្នំក្រវាញទេ ព្រោះខ្ញុំឈឺសន្ធាក់ ទើបមិនអាចធ្វើដំណើរឆ្ងាយបាន ហើយកងទ័ពវៀតណាមមិនបានធ្វើបាបខ្ញុំ និងប្រជាជនដទៃទៀតទេ។ បន្ទាប់មក ម្តាយរបស់ខ្ញុំបានដឹងដំណឹងថា ខ្ញុំរស់នៅស្រុកភ្នំក្រវាញ ទើបគាត់មកយកខ្ញុំទៅរស់នៅភូមិព្រែកវិញ។ នៅពេលនោះខ្ញុំទទួលដំណឹងថា ឪពុកខ្ញុំនិងប្អូនប្រុសបានស្លាប់ដោយសារអត់អាហារនៅពេលរត់ទៅលើភ្នំ។ បន្ទាប់ពីខ្ញុំជួបជុំជាមួយបងប្អូន ម្តាយ និងក្រុមគ្រួសារវិញ យើងបាននាំគ្នាធ្វើស្រែដើម្បីចិញ្ចឹមជីវិត។

នៅឆ្នាំ២០០០ ខ្ញុំ និងគ្រួសារបានវិលត្រឡប់មកស្រុកកំណើតនៅភូមិទួលគ្រួសវិញ ហើយបានកាប់ឆ្ការព្រៃ ដើម្បីយកដីធ្វើស្រែចម្ការរហូតមកៗ សព្វថ្ងៃ ខ្ញុំនៅនឹកឃើញរឿងរ៉ាវលំបាកវេទនាកាលពីវ័យកុមារក្នុងអំឡុងរបបខ្មែរក្រហម។



ពិធីបុណ្យឡើងអ្នកតារបស់ជនជាតិដើមភាគតិចព័រនៅទួលគ្រួស និងទួលកកោះ ក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សុំ សឿម ៖ ចូលបដិវត្តន៍ខ្មែរក្រហម តាមគ្រូទទួលបន្ទុកថ្នាក់

មេក ទិន

សុំ សឿម អាយុ៦៦ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ចាម។ បច្ចុប្បន្ន សឿម រស់នៅក្នុងឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សឿម បានចែករំលែកអំពីបទពិសោធន៍ និងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួនក្នុងរបបខ្មែរក្រហមថា មុនឆ្នាំ១៩៧០ ខ្ញុំរស់នៅក្នុងគ្រួសារកសិករ ដោយមានឪពុកគឺជាជនជាតិចិន និងម្តាយគឺជាជនជាតិខ្មែរ។ គ្រួសារខ្ញុំរស់នៅជួបជុំគ្នាយ៉ាងសប្បាយរីករាយ និងសេចក្តីសុខ។ ជារៀងរាល់ថ្ងៃ ខ្ញុំក្រោកពីព្រឹកដើម្បីជួយធ្វើកិច្ចការផ្ទះ។ នៅពេលថ្ងៃ ខ្ញុំចេញទៅរៀននៅសាលាដូចក្មេងៗដទៃទៀត។



សុំ សឿម អាយុ៦៦ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់ សម្តេចព្រះ នរោត្តម សីហនុ ចេញពីព្រះតំណែង។ នៅឆ្នាំ១៩៧២ ខ្ញុំរួមជាមួយសិស្សប្រហែល៤០នាក់ទៀត បាននាំគ្នារត់ចូលព្រៃម៉ាគី ជាមួយគ្រូបន្ទុកថ្នាក់ទី១០។ កាលនោះ ខ្ញុំនៅវ័យក្មេង មិនទាន់ចេះគិតឱ្យបានច្បាស់លាស់ និងឆាប់ជឿពាក្យលួងលោមបញ្ចុះបញ្ចូលរបស់គ្រូ។ បានធ្វើឱ្យខ្ញុំត្រូវបែកពីឪពុកម្តាយ បងប្អូន និងស្រុកកំណើត។ ក្រោយពីបានធ្វើដំណើរទៅដល់ព្រៃម៉ាគី ខ្ញុំបានជួបជាមួយមេកងពលឈ្មោះ រឿន។ ដោយក្តីអាណិត និងស្រឡាញ់ រឿន បានយកខ្ញុំទៅធ្វើជានីសាររបស់គាត់។ នៅពេលនោះ ខ្ញុំមានតួនាទីរត់សំបុត្រទៅសមរភូមិខាងមុខ និងអមដំណើរ រឿន ទៅប្រជុំតាមភូមិភាគនានា។ ក្រៅពីនេះ ខ្ញុំទទួលខុសត្រូវលើការចម្អិនអាហារ និងដាំទឹកតែជូន រឿន។ ខ្ញុំរស់នៅ និងធ្វើជានីសារបានមួយឆ្នាំ រឿន អនុញ្ញាតឱ្យខ្ញុំឈប់ រួចបញ្ជូនឱ្យចូលធ្វើជាកងទ័ពវិញ។ រហូតដល់ឆ្នាំ១៩៧៣ ខ្ញុំបានចូលកងទ័ពខ្មែរក្រហម និងបានឡើងទៅសមរភូមិប្រយុទ្ធតទល់ជាមួយកងទ័ព លន់ នល់។ ខណៈពេលដែលកំពុងវាយប្រយុទ្ធគ្នា កងទ័ព លន់ នល់ បានទម្លាក់គ្រាប់បែក និងគ្រាប់គីមីជាច្រើនគ្រាប់បណ្តាលឱ្យខូចខាតសម្ភារ និងគ្រឿងសព្វាវុធខ្មែរក្រហមទាំងស្រុង ប៉ុន្តែសំណាងល្អ ខ្ញុំនិងកងកម្លាំងទាំងអស់មិនមានរងរបួសធ្ងន់ធ្ងរ ឬស្លាប់។

នៅអំឡុងឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហម វាយរំដោះបានទីក្រុងភ្នំពេញ។ ចំណែកខ្ញុំមានសេចក្តីត្រេកអរ និងសប្បាយចិត្តជាខ្លាំង ព្រោះគិតថានឹងវិលមកជួបជុំ

ឪពុកម្តាយនៅឯស្រុកកំណើតវិញ។ ប៉ុន្តែជាអកុសល ខ្ញុំមិនបានត្រឡប់មករកគ្រួសារទេ ព្រោះខ្ញុំមានរបួសត្រង់កំភួនជើងត្រូវនៅព្យាបាលនៅមន្ទីរពេទ្យលោកសង្ឃក្នុងទីក្រុងភ្នំពេញរយៈពេលមួយខែទៀត។ ក្រោយពីខ្ញុំចេញពីមន្ទីរពេទ្យខ្មែរក្រហមបានបញ្ជូនខ្ញុំត្រឡប់មកនៅអង្គភាពវិញ។

នៅឆ្នាំ១៩៧៧ ខ្ញុំបានទទួលដំណឹងអកុសលថា ឪពុកម្តាយ និងបងប្អូនខ្ញុំត្រូវឈ្លបភូមិសម្លាប់ចោលទាំងអស់។ ដំណឹងនេះធ្វើឱ្យខ្ញុំខឹងយ៉ាងខ្លាំង។ ខ្ញុំចាំបានថា ឃាតករដែលសម្លាប់ឪពុកម្តាយខ្ញុំ គឺជាអ្នកភូមិដែលធ្លាប់រស់នៅក្បែរគ្នា និងធ្វើជាឈ្លបភូមិក្នុងរបបខ្មែរក្រហម។ ឈ្លបភូមិនោះបានរាយការណ៍ទៅថ្នាក់លើថា គ្រួសារខ្ញុំក្បត់អង្គការ និងជាប់ខ្សែស្រឡាយចិន ដោយសារតែចង់បានមុខមាត់ និងបុណ្យស័ក្តិ។ នៅក្នុងរបបខ្មែរក្រហមឱ្យតែគ្រួសារជាប់សែស្រឡាយចិន គឺខ្មែរក្រហមធ្វើការកត់សម្គាល់ និងតាមដាន ទាំងដែលសាមីខ្លួនមិនបានប្រព្រឹត្តអ្វីខុស។ ខ្ញុំមានការសោកស្តាយឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំដែលបានស្លាប់យ៉ាងអាណោចអាធ័ម។

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយផ្តួលរំលំរបបខ្មែរក្រហម។ ខ្ញុំរួមទាំងកងទ័ពខ្មែរក្រហមជាច្រើននាក់ បានរត់គេចខ្លួនទៅកាន់ភ្នំឱរ៉ាល់ ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ។ ក្រោយពីធ្វើដំណើរទៅដល់ភ្នំឱរ៉ាល់ កងទ័ពទាំងអស់មានសភាពទ្រុឌទ្រោមជាខ្លាំង ដោយសារនៅតាមផ្លូវខ្វះខាតស្បៀងអាហារ និងទឹកផឹក។ នៅទីនោះយើងបាននាំគ្នាដើររកជីកមើមក្តួចយកមកធ្វើអាហារហូបដើម្បីបន្តជីវិតទៀត។ មិនយូរប៉ុន្មាន ខ្ញុំនិងកងទ័ពដែលនៅសេសសល់បានសម្រេចចិត្តចាកចេញពីភ្នំឱរ៉ាល់ឆ្ពោះទៅកាន់ភ្នំដងរែក។ ខ្ញុំធ្វើដំណើរជាច្រើនខែទើបទៅដល់ភ្នំ១០០១ ដែលស្ថិតនៅក្នុងខេត្តព្រះវិហារ។ នៅទីនោះ មេកងពល និងមេកងវរសេនាធំខ្មែរក្រហមបានប្រមូលកម្លាំងតាមភូមិភាគ តំបន់ ស្រុក មកជួបជុំគ្នាដើម្បីបង្កើតអង្គភាពទ័ពថ្មី។

ក្រោយពីប្រមូលកម្លាំងបានអស់ហើយ មេកងពលធំបានបង្កើត និងបែងចែកកម្លាំងទៅជាកងពលតូចច្រើនទៀត។ កាលនោះខ្ញុំ នៅកងពលធំលេខ៧៨៥។ បន្ទាប់មក អង្គភាពបានបញ្ជូនខ្ញុំឱ្យទៅនៅកងទ័ពជើងទឹក។ ខ្ញុំត្រូវធ្វើដំណើរដោយថ្មើរជើងចុះពីលើភ្នំដងរែកឆ្ពោះទៅកាន់ខេត្តកំពង់ធំ បន្ទាប់មកជិះទូកបន្តទៅកាន់ទន្លេសាប។ ទូកដែលខ្ញុំជិះមានប្រវែងប្រមាណ៩ម៉ែត្រ។ ខ្ញុំមិនដែលវាយប្រយុទ្ធជាមួយកងទ័ពខ្មែរគ្នាឯងទេ ព្រោះមុនពេលខ្ញុំឡើងទៅវាយជាមួយវៀតណាម ខ្ញុំបានសរសេរសំបុត្រផ្ញើទៅតាមរយៈអ្នកស្រុកឱ្យប្រាប់កងកម្លាំងខ្មែរឆាប់ចាកចេញពីសមរភូមិ និងឱ្យបានលឿនបំផុត ព្រោះខ្ញុំមិនចង់ឃើញកងទ័ពខ្មែរស្លាប់។

រហូតដល់ឆ្នាំ១៩៨២ ខ្ញុំបានទទួលតំណែងជាមេបញ្ជាការវរសេនាតូចលេខ៩៥១ ហើយកងកម្លាំងដែលខ្ញុំក្តោបក្តាប់មានចំនួន១១០នាក់។ ក្រោយពីបានទទួលតំណែងមេបញ្ជាការវរសេនាតូច ខ្ញុំបានទៅលេងបងប្អូននៅស្រុកកំណើត។ ក្រោយមក ខ្ញុំបានឈប់ធ្វើកងទ័ព និងរស់នៅជាប្រជាជនវិញ។



សុំ សឿម អាយុ៦៦ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គិន ហៀ៖ តស៊ូទៅសាលារៀន ទោះបីប្រឈមនឹងទឹកហូរខ្លាំងនៅរដូវវស្សា

**ស្រេង លីជា**



គិន ហៀ និងមិត្តភក្តិចេញពីសាលាត្រឡប់មកផ្ទះវិញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សានុសិស្សភាគច្រើន ធ្វើដំណើរទៅសាលារៀនតាមរយៈមធ្យោបាយដូចជាម៉ូតូ, ឡាន, ឡានក្រុងសាធារណៈ ឬដោយថ្មើរជើង ប៉ុន្តែសិស្សានុសិស្សរស់នៅតាមបណ្តាកោះដាច់ស្រយាល ក្នុងស្រុកបុរីអូរស្វាយ សែនជ័យ ត្រូវធ្វើដំណើរឆ្លងកាត់ផ្ទៃជលសា នៃទន្លេមេគង្គជារៀងរាល់ថ្ងៃ ដែលជារឿយៗពោរពេញទៅដោយស្ថានភាពគ្រោះថ្នាក់ពីភាពប្រែប្រួលនៃធម្មជាតិ។

នៅក្នុងអត្ថបទនេះ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង បានស្វែងយល់អំពីខ្សែជីវិតនៃការតស៊ូសិក្សារបស់យុវតីឈ្មោះ គិន ហៀ។ គិន ហៀ គឺជាសិស្សថ្នាក់ទី៨ នៃអនុវិទ្យាល័យអូរស្វាយ មានផ្ទះស្ថិតនៅលើទឹកដីភូមិកោះឈើទាលតូច ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ គិន ហៀ បានរៀបរាប់ទាំងស្នាមញញឹមរួមទាំងទឹកភ្នែក ពីភាពលំបាកនៃសិស្សានុសិស្ស និងប្រជាជនដែលរស់នៅតាមបណ្តាកោះដាច់ស្រយាល។ ប៉ុន្តែការរៀបរាប់របស់ គិន ហៀ បែរជាបង្ហាញពីការតស៊ូ ព្រមទាំងក្តីសង្ឃឹមក្នុងការទទួលបានការអប់រំ ដើម្បីក្លាយទៅជាធនធានសម្រាប់សហគមន៍របស់ខ្លួន។

ភូមិកោះឈើទាលតូច គឺជាភូមិមួយស្ថិតនៅក្រោមការគ្រប់គ្រងនៃរដ្ឋបាលឃុំព្រះរំកិល ស្រុកបុរីអូរស្វាយ សែនជ័យ។ កាលពីដើមមក ភូមិកោះឈើទាលតូច មានឈ្មោះថា កោះសិលា ប៉ុន្តែត្រូវបានផ្លាស់ប្តូរឈ្មោះឡើងវិញថា «កោះឈើទាលតូច» ដោយមូលហេតុ នៅចំណុចត្រង់កណ្តាលកោះ មានដើមឈើទាលដុះជាច្រើន ដែលធ្វើឱ្យអ្នកភូមិជិះឆ្លងកាត់មានការចំណាំ ហើយហៅតៗគ្នាថា ឈើទាលតូច រហូតមកដល់បច្ចុប្បន្ន។ ភូមិកោះឈើទាលតូច មានប្រជាជនរស់នៅ សរុបចំនួន១២៨គ្រួសារ ស្មើនឹងចំនួនមនុស្ស៥៥០នាក់។ មុខរបរចញ្ចឹមជីវិតរបស់អ្នកភូមិកោះឈើទាលតូច គឺការធ្វើកសិកម្ម (ដាំស្រូវ និងដំណាំកសិកម្ម), ការនេសាទតាមដងទន្លេមេគង្គ, ការលក់ដូរនៅផ្ទះ និងការធ្វើចំណាកស្រុក។ ដោយសារតែស្ថានភាពភូមិសាស្ត្រ ជាកោះដាច់ស្រយាល ភូមិកោះ

ឈើទាលតូច មានលទ្ធភាពផ្តល់ការអប់រំត្រឹមតែកម្រិតបឋមសិក្សា គឺសាលាបឋមសិក្សាកោះឈើទាលតូចៗ ហេតុដូច្នេះ សិស្សានុសិស្ស ដែលរៀនចប់ថ្នាក់ទី៦ និងចង់បន្តការសិក្សាត្រូវធ្វើដំណើរឆ្លងកាត់ទន្លេមេគង្គមកកាន់ដីគោកក្នុងស្រុកបុរីអូរស្វាយសែនជ័យ ដើម្បីចូលរៀននៅអនុវិទ្យាល័យអូរស្វាយ និងវិទ្យាល័យបុរីអូរស្វាយ សែនជ័យ។ ការធ្វើដំណើរតាមផ្លូវទឹក គឺជាក្តីបារម្ភដ៏ធំមួយ ដែលបណ្តាលឱ្យសិស្សានុសិស្សមួយចំនួនប្រឈមនឹងការបោះបង់ការសិក្សា ដោយសារតែកត្តាសុវត្ថិភាពកម្រិតជីវភាព និងភាពស៊ីទ្រាំ។ ក្រោយពីរៀនសូត្រសិស្សានុសិស្សក្នុងភូមិកោះឈើទាលតូច អាចចូលរួមចំណែកជួយការងារគ្រួសារ ដូចជារៀបចំសំណាញ់នេសាទ មើលថែទាំចម្ការ និងមើលថែប្អូនតូចៗនៅផ្ទះ។ ការចំណាយលើការធ្វើដំណើរតាមទូក ឬការទិញសម្ភារធ្វើទូក គឺជាឧបសគ្គផ្នែកហិរញ្ញវត្ថុយ៉ាងធ្ងន់ក្នុងគ្រួសារ ដែលជំរុញឱ្យសិស្សានុសិស្សខ្លះសម្រេចចិត្តបោះបង់ការសិក្សា។

ស្ថានភាពកន្លងមក គឺអាណាព្យាបាលសិស្ស និងសិស្សានុសិស្សផ្ទាល់តែងតែមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុវត្ថិភាព និងហានិភ័យក្នុងការធ្វើដំណើរឆ្លងកាត់ផ្ទៃទន្លេមេគង្គ ដូចជាបញ្ហាចរន្តទឹកហូរខ្លាំង និងការកើតមានភ្លៀងខ្យល់បោកបក់ខ្លាំងៗ បើទោះជាយ៉ាងនេះក្តី សិស្សានុសិស្សនៅតែខិតខំប្រឹងប្រែងលះបង់ទាំងពេលវេលា និងកម្លាំងកាយចិត្ត ក្នុងការពុះពារបន្តការសិក្សា ដោយហេតុថា ការអប់រំនឹងជួយបង្កើតឱកាសសម្រាប់ខ្លួនទទួលបានចំណេះដឹង និងក្លាយជាធនធានដ៏មានតម្លៃសម្រាប់សហគមន៍ទៅថ្ងៃអនាគត។

កិន ហៀ បាននិយាយថា ខ្សែជីវិតនៃការសិក្សារបស់ខ្ញុំ គឺមិនដូចរឿងនិទាន ឬរឿងប្រលោមលោកដែលតែងតែមានដំណោះស្រាយស្រាប់ដើម្បីនាំផ្លូវនោះទេ ប៉ុន្តែវាជាជីវិតពិតរបស់ខ្ញុំដែលត្រូវឆ្លងកាត់ផ្ទៃទឹកទន្លេមេគង្គដោយកម្លាំងចិត្ត និងស្មារតី។ ជារៀងរាល់ថ្ងៃ ខ្ញុំត្រូវក្រោកពីដេកនៅម៉ោង៤ទៀបភ្លឺ ដើម្បីបំពេញការងារផ្ទះ មានដូចជា ដាំបាយ, ខ្ចប់បាយ និងបោសសំអាតផ្ទះ មុនពេលចុះទូកជិះទៅកាន់ដែរង់ចាំអូរស្វាយ ដើម្បីបន្តទៅសិក្សានៅអនុវិទ្យាល័យអូរស្វាយ។ អ្វីដែលខ្ញុំត្រូវប្រឈម គឺភាពត្រជាក់ក្នុងរដូវវស្សា និងខ្សែទឹកហូរបោកបក់ដែលទាមទារឱ្យមានការតាំងស្មារតី និងសេចក្តីក្លាហានក្នុងដំណើរឆ្ពោះទៅកាន់ការសិក្សាអប់រំជារៀងរាល់ថ្ងៃ។ នៅថ្ងៃមួយខ្ញុំជួបគ្រោះថ្នាក់ ដោយសារតែចរន្តខ្សែទឹកហូរខ្លាំង


កិន ហៀ នៅខាងមុខផ្ទះ ស្ថិតនៅភូមិកោះឈើទាលតូច ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


កិន ហៀ ក្រោកដាំបាយនៅពេលព្រឹក ដើម្បីវេចខ្ចប់យកទៅហូបនៅសាលារៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កិន ហៀ និងមិត្តភក្តិនៅក្នុងភូមិ ជិះទូកសហគមន៍ទៅរៀន នៅអនុវិទ្យាល័យអូរស្វាយ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បណ្ដាលឱ្យទូកតូចរបស់ខ្ញុំហូរទៅបុកគល់ឈើ និងផ្ទាំងថ្ម ហើយស្ទើរតែបាត់បង់លំនឹង។ ប៉ុន្តែសំណាងល្អ ខ្ញុំមិនមានគ្រោះថ្នាក់អ្វីឡើយនៅពេលនោះ។ បើទោះជាយ៉ាងនេះក្ដី សៀវភៅ សម្ភារសិក្សា និងសម្លៀកបំពាក់បានទទឹកខូចខាតអស់។ បើទោះជាគ្រានោះ ពិបាកខ្លាំងយ៉ាងណា ខ្ញុំមិនព្រមបោះបង់ការសិក្សាទេ ពីព្រោះខ្ញុំតែងតែទទួលបានការគាំទ្រ និងលើកទឹកចិត្តពីឪពុកម្ដាយរបស់ខ្ញុំ ហើយរូបខ្ញុំផ្ទាល់មានជំនឿចិត្តយ៉ាងមុតមាំថា «មានតែការអប់រំតែប៉ុណ្ណោះ ទើបអាចជួយគ្រួសារខ្ញុំ និងសហគមន៍របស់ខ្ញុំឱ្យចាកចេញពីភាពលំបាកដែលខ្ញុំកំពុងតែជួបប្រទះ»។ រហូតមកដល់បច្ចុប្បន្ន ទុក្ខកង្វល់ និងភាពភ័យខ្លាចរបស់ឪពុកម្ដាយ និងខ្ញុំត្រូវបានជំនួសមកវិញនូវស្នាមញញឹម និងក្ដីសង្ឃឹម បន្ទាប់ពីទទួលបានទូកចម្លងសហគមន៍ ដែលមានទំហំធំ និងសុវត្ថិភាពខ្ពស់បំពាក់ទៅដោយអាវការពារសុវត្ថិភាពជាច្រើន ថែមទាំងមិនយកកម្រៃ ក្រោមការឧបត្ថម្ភគាំទ្រពីព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា។ បើទោះជាស្ថិតក្នុងស្ថានភាពលំបាកនៃការកើនឡើងតម្លៃប្រេងឥន្ធនៈសកល ដែលបង្កឡើងដោយសង្គ្រាម ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅតែបន្តជួយដឹកជញ្ជូនខ្ញុំ និងសិស្សផ្សេងទៀតនៅតាមបណ្ដាកោះដាច់ស្រយាលទៅរៀនជាធម្មតា ដែលផ្ដល់ឱ្យយើងខ្ញុំអាចបន្តការសិក្សាទៅមុខយ៉ាងរលូន ដោយគ្មានការអាក់ខានឡើយ។ ជំនួយមនុស្សធម៌នេះ មិនត្រឹមតែផ្ដល់ឱកាសដល់ខ្ញុំទទួលបានការអប់រំតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកទឹកចិត្តដល់ខ្ញុំឱ្យលែងមានគំនិតបោះបង់ការសិក្សា។

ខ្សែជីវិត និងការតស៊ូជម្នះឧបសគ្គរបស់ខ្ញុំ ព្រមទាំងសិស្សានុសិស្សនៅក្នុងភូមិកោះឈើទាលតូច គឺបង្ហាញឱ្យឃើញពីតម្លៃនៃការទទួលបានការអប់រំដែលមិនអាចមានអ្វីមករារាំងបានឡើយ មិនថាឧបសគ្គភូមិសាស្ត្រ ឬខ្សែទឹកហូរនៃទន្លេមេគង្គ។ ភាពស៊ូទ្រាំ និងការគាំទ្រពីគ្រួសារ និងសហគមន៍ ក្លាយជាកម្លាំងរុញច្រានយ៉ាងមុតមាំដល់ខ្ញុំបន្តដំណើរទៅមុខ។ បន្ថែមលើនេះទៀត វត្តមាននៃទូកចម្លងសហគមន៍ ដែលជាអំណោយមនុស្សធម៌ដ៏ថ្លៃថ្លាពីព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ មិនត្រឹមតែបានកែប្រែ «សេចក្ដីព្រួយបារម្ភ» ឱ្យក្លាយជា «ស្នាមញញឹម និងសុវត្ថិភាព» តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាស្ពានចម្លងទៅកាន់ពន្លឺនៃការអប់រំ សម្រាប់សិស្សានុ-សិស្ស និងយុវជនយុវនារីនៅតាមកោះដាច់ស្រយាល ឱ្យក្លាយជាធនធានមនុស្សដើម្បីមកចូលរួមអភិវឌ្ឍន៍សហគមន៍របស់ខ្លួនវិញ។



អនុវិទ្យាល័យអូរស្វាយ ស្ថិតនៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វដ្តជីវិត និងការបម្លាស់ទីតាមរដូវកាល របស់សត្វក្អែកទឹក នៅតំបន់រ៉ាមសារ

## នៃស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង

*ស្រេង លីដា*



*ហ្វូងក្អែកទឹកនៅដងទន្លេមេគង្គ ក្នុងស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ស្រុកបុរីអូរស្វាយ សែនជ័យ គឺជាស្រុកមួយរបស់ខេត្តស្ទឹងត្រែង ដែលមានជីវៈចម្រុះ និងសត្វស្លាបទឹកដ៏សម្បូរបែបជាច្រើនប្រភេទ និងបំពេញមុខងារយ៉ាងសំខាន់ក្នុងប្រព័ន្ធអេកូឡូស៊ី។ ក្នុងនោះលោកស្រេង លីដា គឺជាបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រចាំសាខាខេត្តស្ទឹងត្រែង បានធ្វើការសិក្សាស្រាវជ្រាវពីវដ្តជីវិត និងការបម្លាស់ទីរបស់សត្វក្អែកទឹក។ សត្វក្អែកទឹកគឺជាសត្វស្លាបមួយប្រភេទដែលមានភាពវៃឆ្លាត និងមានភាពបត់បែនក្នុងការរស់នៅតាមដងទន្លេមេគង្គ ទន្លេសាប ស្របទៅតាមការបម្លាស់ទីរបស់ហ្វូងត្រី។ ជារៀងរាល់ឆ្នាំ ក្អែកទឹក តែងតែធ្វើការបម្លាស់ទីទៅមកចន្លោះពីតំបន់បឹងទន្លេសាប និងតំបន់ទន្លេមេគង្គលើ ដែលបង្កើតឡើងនូវភាពបត់បែនក្នុងការរស់នៅរបស់សត្វស្លាបប្រភេទនេះ»។

ក្អែកទឹក គឺជាសត្វស្លាបទឹកមួយប្រភេទដែលមានរូបរាងស្រដៀងនឹងសត្វទា ប៉ុន្តែមានទំហំតូចជាងបន្តិច។ ក្អែកទឹកមានលក្ខណៈសម្គាល់ងាយមើលដឹងតាមរយៈមានរោមពណ៌ខ្មៅរលោង ចំពុះវែងពណ៌ប្រផេះ ក្អែកខ្មៅ និងមានប្រអប់ជើងជាប់គ្នាដូចជើងទា

ដែលជាអំណោយផលយ៉ាងប្រសើរសម្រាប់ការហែលទឹក។ លក្ខណៈពិសេសរបស់ក្អែកទឹក គឺមានសមត្ថភាពទាំងការហោះហើរលើអាកាស និងការជ្រមុជទឹកបានយ៉ាងជ្រៅ និងរហ័ស ដើម្បីដេញចាប់ត្រីធ្វើជាចំណី។ បន្ទាប់ពីចាប់ត្រីបានហើយ ក្អែកទឹកតែងតែហើរទៅទុំនៅលើមែកឈើងាប់ៗ ដែលដុះតាមដងទន្លេមេគង្គ, ស្ទឹង ឬតំបន់ឆ្នេរ ដើម្បីសម្រាក និងលាតស្លាបរបស់ខ្លួនហាលថ្ងៃឱ្យស្ងួត។

លោក ស្រេង លីដា បានបន្ថែមថា «តាមរយៈការអង្កេតនៅអំឡុងខែវិច្ឆិកា ឬខែធ្នូ ជារៀងរាល់ឆ្នាំ ក្អែកទឹក តែងតែបម្លាស់ទីចាកចេញពីតំបន់ទំនាបជុំវិញបឹងទន្លេសាប ឡើងមកកាន់តំបន់ទន្លេមេគង្គលើ ក្នុងតំបន់រាមសារ (ដីសើម) នៃស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ការរំកិលខ្លួនមកកាន់តំបន់រាមសារ គឺធ្វើឡើងស្របពេលដែលហ្វូង«ត្រីរៀល» និងត្រីតូចៗដទៃទៀតបម្លាស់ទីឡើងមកកាន់ខ្សែទឹកខាងលើដូចគ្នា។ ត្រីរៀលជាចំណីដ៏មានឱជារស និងងាយស្រួលចាប់បំផុតសម្រាប់ក្អែកទឹក»។

ក្អែកទឹកបន្តរស់នៅ និងរកចំណីយ៉ាងកុះករនៅតាមដងទន្លេមេគង្គ ពិសេសនៅក្នុងតំបន់រាមសារ ក្នុងស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង ដែលបង្កលក្ខណៈងាយស្រួល និងបង្កើនភាពទាក់ទាញដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិក្នុងការមកទស្សនាកម្សាន្ត។

នៅរដូវវស្សាឆ្នាំនេះ ក្រុមការងាររបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែងបានឃើញហ្វូងក្អែកទឹកជាច្រើន ចាប់ផ្ដើមធ្វើដំណើរវិលទៅកាន់តំបន់បឹងទន្លេសាបវិញ ដោយហេតុផល ដូចជា៖

១) នៅក្នុងខែកក្កដានេះ ទឹកទន្លេមេគង្គចាប់ផ្ដើមឡើងខ្លាំង និងមានសភាពល្អក់កករ ដែលធ្វើឱ្យក្អែកទឹកពិបាកមើលឆ្លុះទៅក្នុងទឹក ដើម្បីជ្រមុជចាប់ចំណី។

២) នាដើមរដូវវស្សានេះ គឺជាពេលវេលាដែលហ្វូងត្រីរៀល ត្រូវធ្វើដំណើរវិលទៅវិញ គឺវិលទៅកាន់ទន្លេសាប បន្ទាប់ពីទម្លាក់ពង-កូន នៅតំបន់រាមសាររួចរាល់។

៣) ការវិលទៅកាន់បឹងទន្លេសាបវិញ មិនត្រឹមតែដើម្បីភាពងាយស្រួលក្នុងការស្វែងរកចំណីតែប៉ុណ្ណោះទេ ប៉ុន្តែជារដូវកាលដ៏សំខាន់ដែលក្អែកទឹកត្រូវកសាងសម្បុក ដើម្បីបន្តពូជ និងពងកូន។



ហ្វូងក្អែកទឹកនៅដងទន្លេមេគង្គ ក្នុងស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ទេសភាពនៅតាមដងទន្លេមេគង្គ ក្នុងស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



អ្នកនេសាទនៅទន្លេមេគង្គ ក្នុងស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស្ថានទូតហ្វីលីពីន

## សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ រៀបចំវគ្គសិក្សាថ្នាក់ភាសាអង់គ្លេសទំនាក់ទំនងធុរកិច្ច និងទេសចរណ៍ សម្រាប់មន្ត្រីរដ្ឋបាលឃុំស្រុក និង សហគមន៍អេកូទេសចរណ៍ នៅស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង

**ស៊ាង ចិន្តា**




*ស្ថានទូតហ្វីលីពីន ប្រចាំទីក្រុងភ្នំពេញ សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង រៀបចំវគ្គសិក្សាថ្នាក់ភាសាអង់គ្លេស ទំនាក់ទំនងធុរកិច្ច និងទេសចរណ៍ សម្រាប់មន្ត្រីរដ្ឋបាលឃុំ/ស្រុក និងសហគមន៍អេកូទេសចរណ៍នៅស្រុកបុរីអូរស្វាយ សែនជ័យ ពីថ្ងៃចន្ទ ទី៦ ដល់ថ្ងៃសុក្រ ទី១០ ខែកក្កដា ឆ្នាំ២០២៦ នៅអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ–សម្តេចម៉ែ (បុរីអូរស្វាយ–សែនជ័យ)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ស្ថានទូតហ្វីលីពីន ប្រចាំទីក្រុងភ្នំពេញ សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង រៀបចំវគ្គសិក្សាថ្នាក់ភាសាអង់គ្លេស ទំនាក់ទំនងធុរកិច្ច និងទេសចរណ៍ សម្រាប់មន្ត្រីរដ្ឋបាលឃុំ/ស្រុក និងសហគមន៍អេកូទេសចរណ៍នៅស្រុកបុរីអូរស្វាយ សែនជ័យ។ វគ្គសិក្សាថ្នាក់ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងធុរកិច្ច និងទេសចរណ៍ ធ្វើឡើងក្នុងគោលបំណងពង្រឹងជំនាញទំនាក់ទំនងភាសាអង់គ្លេសកម្រិតមូលដ្ឋាន ដល់មន្ត្រីមូលដ្ឋាន និងសហគមន៍អេកូទេសចរណ៍អូរស្វាយ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍មូលដ្ឋានតាមរយៈកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ និងការលើកកម្ពស់វិស័យអេកូទេសចរណ៍ប្រកបដោយចីរភាព។

វគ្គសិក្សាថ្នាក់ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងធុរកិច្ច និងទេសចរណ៍នេះ ត្រូវបានរៀបចំឡើងជាពិសេសទៅតាមតម្រូវការរបស់មន្ត្រីឃុំ/ស្រុក និងសហគមន៍អេកូទេសចរណ៍អូរស្វាយ នៃស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង។ សិក្ខាកាមទាំងអស់ ត្រូវចូលរួមថ្នាក់សិក្សាភាសាអង់គ្លេសនីមួយៗរយៈពេល១៥ម៉ោងសិក្សា ដែលត្រូវបានរៀបចំឡើងដោយការបញ្ចូលគ្នានូវមេរៀនភាសាអង់គ្លេសកម្រិតមូលដ្ឋាន និងការអនុវត្តទំនាក់ទំនងជាក់ស្តែង ដើម្បីអាចឱ្យសិក្ខាកាមយកជំនាញភាសាអង់គ្លេសកម្រិតមូលដ្ឋាន ទៅអនុវត្តនៅក្នុងការបំពេញកិច្ចការងារប្រចាំថ្ងៃ សកម្មភាពសហគមន៍ និងការប្រាស្រ័យទាក់ទងជាមួយភ្ញៀវទេសចរណ៍ និងដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ។




ស្ថានទូតហ្វីលីពីន ប្រចាំទីក្រុងភ្នំពេញ សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង រៀបចំវគ្គសិក្សាថ្នាក់ភាសាអង់គ្លេសទំនាក់ទំនងធុរកិច្ច និងទេសចរណ៍ សម្រាប់មន្ត្រីរដ្ឋបាលឃុំ/ស្រុក និងសហគមន៍អេកូទេសចរណ៍នៅស្រុកបុរីអូរស្វាយ សែនជ័យ ពីថ្ងៃចន្ទទី៦ ដល់ថ្ងៃសុក្រ ទី១០ ខែកក្កដា ឆ្នាំ២០២៦ នៅអគារមរតកសន្តមរាស្ត្រនិយម សម្តេចឪ–សម្តេចម៉ែ (បុរីអូរស្វាយ–សែនជ័យ)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## វគ្គសិក្សាថ្នាក់ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងទេសចរណ៍

វគ្គសិក្សាថ្នាក់ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងទេសចរណ៍នេះ ត្រូវបានរៀបចំឡើងសម្រាប់បង្រៀនមគ្គុទ្ទេសក៍សហគមន៍អេកូទេសចរណ៍អូរស្វាយ អំពីជំនាញទំនាក់ទំនងភាសាអង់គ្លេសកម្រិតមូលដ្ឋាន និងការទទួលបដិសណ្ឋារកិច្ចក្នុងការប្រាស្រ័យទាក់ទងជាមួយភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។ វគ្គសិក្សានេះនឹងណែនាំពីពាក្យសម្តី និងវាក្យសព្ទភាសាអង់គ្លេសដែលអាចត្រូវប្រើប្រាស់ជាប្រចាំនៅក្នុងបរិបទទេសចរណ៍រួមមាន៖ ការនិយាយស្វាគមន៍, ការនាំផ្លូវ, ការណែនាំអំពីសុវត្ថិភាព, ការពន្យល់ពីសក្តានុពលធម្មជាតិក្នុងតំបន់ទេសចរណ៍។ វគ្គសិក្សានេះ មានសារសំខាន់ជាពិសេសសម្រាប់សហគមន៍អេកូទេសចរណ៍ ក្នុងស្រុកបុរីអូរស្វាយ សែនជ័យ ដែលជាទីកន្លែងមានសក្តានុពលខ្ពស់ក្នុងវិស័យអេកូទេសចរណ៍ និងជាការចូលរួមចំណែកដល់ការគាំទ្រជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនមូលដ្ឋាន និងការអភិវឌ្ឍន៍សហគមន៍។ តាមរយៈការទទួលបានការយល់ដឹងភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងទេសចរណ៍ជាមូលដ្ឋាន សហគមន៍អេកូទេសចរណ៍ នឹងអាចរៀបចំខ្លួនឱ្យបានកាន់តែល្អប្រសើរ ក្នុងការទទួលស្វាគមន៍ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ, ចែករំលែកព័ត៌មានអំពីសហគមន៍ និងធនធានដ៏សម្បូរបែបនៃបរិស្ថានអេកូទេសចរណ៍របស់ខ្លួន ព្រមទាំងគាំទ្រដល់ការបង្កើតបទពិសោធន៍ទេសចរណ៍ដ៏ល្អៗពីសហគមន៍របស់ខ្លួន។ ការពង្រឹងជំនាញទាំងនេះ មិនត្រឹមតែជួយបង្កើនការចូលរួមប្រាស្រ័យទាក់ទងជាមួយភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមចំណែកដល់ការថែរក្សាធនធានធម្មជាតិ និងសម្បត្តិវប្បធម៌ក្នុងសហគមន៍ ក៏ដូចជាការអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ស្រុកបុរីអូរស្វាយ សែនជ័យ។

## វគ្គសិក្សាថ្នាក់ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងធុរកិច្ច

វគ្គសិក្សាថ្នាក់ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងធុរកិច្ចនេះ ត្រូវបានរៀបចំឡើងដើម្បីផ្តល់ចំណេះដឹងភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងធុរកិច្ចកម្រិតមូលដ្ឋានដល់មន្ត្រីឃុំ និងស្រុកក្នុងការត្រៀមលក្ខណៈយកទៅប្រើប្រាស់ក្នុងកិច្ចការងារ និងទំនាក់ទំនងប្រចាំថ្ងៃជាមួយដៃគូជាតិ និងអន្តរជាតិ។ វគ្គសិក្សានេះ នឹងណែនាំអំពីគោលគំនិតសំខាន់ៗ និងភាសាអនុវត្តជាក់ស្តែងដែលអាចប្រើប្រាស់ក្នុងការទំនាក់ទំនងបែប





ស្ថានទូតហ្វីលីពីន ប្រចាំទីក្រុងភ្នំពេញ សហការជាមួយមជ្ឈ-មណ្ឌលឯកសារកម្ពុជា និងរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង រៀបចំវគ្គសិក្សាថ្នាក់ភាសាអង់គ្លេស ទំនាក់ទំនងធុរកិច្ច និងទេសចរណ៍ សម្រាប់មន្ត្រីរដ្ឋបាលឃុំ/ស្រុក និងសហគមន៍អេកូទេសចរណ៍នៅស្រុកបុរីអូរស្វាយ សែនជ័យ ពីថ្ងៃចន្ទ ទី៦ ដល់ថ្ងៃសុក្រ ទី១០ ខែកក្កដា ឆ្នាំ២០២៦ នៅអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ–សម្តេចម៉ែ (បុរីអូរស្វាយ–សែនជ័យ)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

---

វិជ្ជាជីវៈ។ តាមរយៈមេរៀនរៀបចំទុកជាមុន និងការអនុវត្តជាក់ស្តែង សិក្ខាកាមនឹងទទួលបានចំណេះដឹងភាសាអង់គ្លេសជាមូលដ្ឋាន ក្នុងបរិបទប្រើប្រាស់ និងសន្ទនា (និយាយ, ស្តាប់, អាននិងសរសេរ)។ វគ្គសិក្សានេះមានគោលបំណងបង្កើនទំនុកចិត្តរបស់មន្ត្រីរដ្ឋបាល ក្នុងការប្រាស្រ័យទាក់ទងជាមួយស្ថាប័នរដ្ឋនានា អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធអន្តរជាតិ។ តាមរយៈការអនុវត្ត និងពង្រឹងកម្រិតសមត្ថភាពភាសាអង់គ្លេសមូលដ្ឋាននេះ មន្ត្រីរដ្ឋបាលនឹងមានលទ្ធភាពកាន់តែប្រសើរឡើងក្នុងការបំពេញកិច្ចការងារគាំទ្រដល់កិច្ចសហប្រតិបត្តិការ ការផ្លាស់ប្តូរចំណេះដឹង និងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍មូលដ្ឋាននៅក្នុងស្រុកបុរីអូរស្វាយ សែនជ័យ។

## ការវាស់ស្ទង់ចំណេះដឹងមុនថ្នាក់រៀនភាសាអង់គ្លេស

មុននឹងចូលរួមក្នុងវគ្គសិក្សា សិក្ខាកាមទាំងអស់ត្រូវបំពេញការវាស់ស្ទង់ចំណេះដឹងភាសាអង់គ្លេសមុនថ្នាក់រៀនភាសាអង់គ្លេសចាប់ផ្តើម។ ការវាស់ស្ទង់ចំណេះដឹងភាសាអង់គ្លេសនេះ រៀបចំឡើងដើម្បីពិនិត្យមើលកម្រិតសមត្ថភាពភាសាអង់គ្លេសបច្ចុប្បន្នរបស់សិក្ខាកាមចូលរួមទាំងអស់ និងអាចជួយសម្រួលដល់គ្រូបង្រៀនភាសាអង់គ្លេសក្នុងការយល់ដឹងអំពីកម្រិតចំណេះដឹងភាសាអង់គ្លេស និងតម្រូវការរបស់សិក្ខាកាម ដើម្បីអាចឱ្យគ្រូបង្រៀនភាសាអង់គ្លេសអាចយកមេរៀនដ៏សមស្របបំផុតមកបង្រៀន។ លើសពីនេះទៅទៀត លទ្ធផលចេញពីការវាស់ស្ទង់ចំណេះដឹងភាសាអង់គ្លេសនឹងជួយដល់គ្រូបង្រៀនភាសាអង់គ្លេស ក្នុងការស្វែងរកវិធីសាស្ត្របង្រៀនឱ្យមានប្រសិទ្ធភាព និងបទពិសោធន៍សិក្សារៀនសូត្រភាសាអង់គ្លេសដ៏ល្អក្នុងជំនាញទំនាក់ទំនងធុរកិច្ច និងទេសចរណ៍ សម្រាប់សិក្ខាកាម។

វគ្គសិក្សានេះបង្រៀនដោយកញ្ញា CHRES P. PABAS ពីថ្ងៃចន្ទ ទី៦ ដល់ថ្ងៃសុក្រ ទី១០ ខែកក្កដា ឆ្នាំ២០២៦ នៅអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ–សម្តេចម៉ែ (បុរីអូរស្វាយ–សែនជ័យ)។




ស្ថានទូតហ្វីលីពីន ប្រចាំទីក្រុងភ្នំពេញ សហការជាមួយមជ្ឈ-មណ្ឌលឯកសារកម្ពុជា និងរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង រៀបចំវគ្គសិក្សាថ្នាក់ភាសាអង់គ្លេស ទំនាក់ទំនងធុរកិច្ច និងទេសចរណ៍ សម្រាប់មន្ត្រីរដ្ឋបាលឃុំ/ស្រុក និងសហគមន៍អេកូទេសចរណ៍នៅស្រុកបុរីអូរស្វាយ សែនជ័យ ពីថ្ងៃចន្ទ ទី៦ ដល់ថ្ងៃសុក្រ ទី១០ ខែកក្កដា ឆ្នាំ២០២៦ នៅអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ–សម្តេចម៉ែ (បុរីអូរស្វាយ–សែនជ័យ)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ

## សម្របសម្រួលដំណើរបេសកកម្មរបស់គណៈប្រតិភូរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ក្នុងការចុះសិក្សាប្រមូលទិន្នន័យដើម្បីបង្កើតគម្រោងអភិវឌ្ឍន៍សាកល្បងនៅលើ «កោះឈើទាលធំ»

ស្រេង លីជា



*រដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ សម្របសម្រួលដំណើរបេសកកម្មរបស់គណៈប្រតិភូរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ក្នុងការចុះសិក្សាប្រមូលទិន្នន័យដើម្បីបង្កើតគម្រោង អភិវឌ្ឍន៍សាកល្បងនៅលើ «កោះឈើទាលធំ» នាព្រឹកថ្ងៃពុធ ទី១៥ ខែកក្កដា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នាព្រឹកថ្ងៃពុធ ទី១៥ ខែកក្កដា ឆ្នាំ២០២៦ ឯកឧត្តម ស៊ុម សុខម្ភ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ ចុះសិក្សាប្រមូលព័ត៌មាន និងទិន្នន័យសំខាន់ៗ ដើម្បីធ្វើបុរេសមិទ្ធិផល ក្នុងគោលដៅឆ្ពោះទៅគិតគូរបង្កើតគម្រោងអភិវឌ្ឍន៍សាកល្បងតំបន់ព្រំដែនលើ «កោះឈើទាលធំ» ស្ថិតក្នុងភូមិសាស្ត្រស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។

នៅក្នុងដំណើរបេសកកម្មដ៏មានសារសំខាន់នេះ មានការអញ្ជើញចូលរួមដោយ លោក ភោគ សុវិសិដ្ឋ អភិបាលស្រុកស្តីទីនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ អមដំណើរដោយលោកស្រី យោ អ៊ី ឡាង នាយករដ្ឋបាលស្តីទី, លោក ព្រាប សារ៉េត នាយករងរដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ និង



រដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ សម្របសម្រួលដំណើរបេសកកម្មរបស់គណៈប្រតិភូរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ក្នុងការចុះសិក្សាប្រមូលទិន្នន័យដើម្បីបង្កើតគម្រោង អភិវឌ្ឍន៍សាកល្បងនៅលើ «កោះឈើទាលធំ» នាព្រឹកថ្ងៃពុធ ទី១៥ ខែកក្កដា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បុគ្គលិកប្រចាំការនៅទីតាំងអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) គឺជាអ្នកជួយសម្របសម្រួល ក្នុងកិច្ចសម្ភាសន៍ និងប្រមូលទិន្នន័យ។

ដំណើរបេសកកម្មនេះ ធ្វើឡើងក្នុងក្របខណ្ឌនៃការរៀបចំផែនទីតម្រង់ទិសដើម្បីអភិវឌ្ឍន៍តំបន់ព្រំដែន ស្របតាមលិខិតផ្លូវការលេខ ១៨២/២៦ រកព.លស របស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ក្នុងគោលបំណងសិក្សាស្វែងយល់ពីស្ថានភាពជាក់ស្តែង និងប្រមូលធាតុចូលពីអាជ្ញាធរមូលដ្ឋាន ដូចជាប្រជាពលរដ្ឋ ដើម្បីជំរុញការអភិវឌ្ឍន៍តំបន់ព្រំដែនឱ្យមានការរីកចម្រើនប្រកបដោយនិរន្តរភាព និងពង្រឹងសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន។

***ផ្អែកតាមផែនការសកម្មភាពដំណើរបេសកកម្មសិក្សាស្រាវជ្រាវនេះ នឹងត្រូវបែងចែកជាពីរលើក រួមមាន៖***

លើកទី១) ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៦ ដោយក្រុមការងារនឹងចុះជួបសម្ភាសន៍ប្រមូលព័ត៌មានផ្ទាល់ជាមួយអាជ្ញាធរពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

លើកទី២) ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៦ ដោយក្រុមការងារនឹងបន្តចុះជួបសម្ភាសន៍



ជាមួយមន្ត្រីដឹកនាំតាមមន្ទីរពាក់ព័ន្ធ គ្រូបង្រៀន អាជ្ញាធរ និងសហគមន៍បន្ថែមទៀត។

ចុងបញ្ចប់នៃដំណើរបេសកកម្ម លោក ភោគ សុវិសិដ្ឋ អភិបាលស្រុកស្តីទី និងក្នុងនាមជារដ្ឋបាលស្រុក ជូនសមុខឱ្យប្រជាពលរដ្ឋទូទាំងស្រុក ថ្លែងការគាំទ្រយ៉ាងពេញទំហឹង និងត្រៀមលក្ខណៈសហការសម្របសម្រួលគ្រប់បែបយ៉ាងជាមួយគណៈប្រតិភូទាំងផ្នែកសន្តិសុខ និងការផ្តល់ព័ត៌មាន ដើម្បីធានាឱ្យដំណើរបេសកកម្មសិក្សាប្រមូលទិន្នន័យនេះ ទទួលបានជោគជ័យខ្ពស់ ឆ្លើយតបទៅនឹងទស្សនវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយតំបន់ព្រំដែនទៅជាតំបន់អភិវឌ្ឍន៍ សន្តិភាព និងមិត្តភាពប្រកបដោយភាពចម្រើនរុងរឿង។

# អាជ្ញាធរមូលដ្ឋាន និងមន្ត្រី មកពីក្រសួងសុខាភិបាល រៀបចំកម្មវិធី

## «វគ្គបណ្តុះបណ្តាលគ្រូបង្គោល ដើម្បីលុបបំបាត់ ជំងឺឆ្លងព្រូនស៊ីស្តូ ឬជំងឺព្រូនធំពោះ និងជំងឺផ្សេងៗក្នុងសហគមន៍ នៅអគារមរតកសង្គមរាស្ត្រនិយមសម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)

ស្រេង លីដា



អាជ្ញាធរមូលដ្ឋាន និងមន្ត្រីមកពីក្រសួងសុខាភិបាល រៀបចំកម្មវិធី «វគ្គបណ្តុះបណ្តាលគ្រូបង្គោល ដើម្បីលុបបំបាត់ ជំងឺឆ្លងព្រូនស៊ីស្តូ ឬជំងឺព្រូនធំពោះ និងជំងឺផ្សេងៗក្នុងសហគមន៍ នៅអគារមរតកសង្គមរាស្ត្រនិយមសម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ពីថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២០-២១ ខែកក្កដា ឆ្នាំ២០២៦ អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យ ហ្វូងម៉ែ បានសហការជាមួយអាជ្ញាធរឃុំអូរស្វាយ ផ្តល់ទីតាំងសម្រាប់រៀបចំកម្មវិធី «វគ្គបណ្តុះបណ្តាលគ្រូបង្គោល ដើម្បីសហគមន៍ដឹកនាំអនុវត្តការប្រើប្រាស់ទឹកស្អាតបង្គន់និងអនាម័យ ដើម្បីឈានទៅលុបបំបាត់ជំងឺស៊ីស្តូ»។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីវាគ្មិនលោកបណ្ឌិត ខៀវ វីរៈ អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ នៃក្រសួងសុខាភិបាល និង កញ្ញា វ៉ាន់ ម៉ូលីដែន ប្រធានផ្នែកដង្កូវព្រូន ព្រមទាំងមានការចូលរួមពីតំណាងក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទមន្ទីរសុខា-

ភិបាលខេត្តស្ទឹងត្រែង មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង ការិយាល័យស្រុកប្រតិបត្តិស្ទឹងត្រែង អាជ្ញាធរឃុំអូរស្វាយ បុគ្គលិកមណ្ឌលសុខភាពកំភុន បុគ្គលិកមណ្ឌលសុខភាពព្រះនរោត្តម សីហនុរាជា និងសម្តេចព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ អូរស្វាយ និងតំណាងអង្គការសុខភាពពិភពលោក (WHO)។

**ស្ថានភាពជំងឺព្រូនស៊ីស្តូ (ជំងឺព្រូនធំពោះ) និងវដ្តនៃការចម្លង**

ក្នុងឱកាសនេះ លោកបណ្ឌិត ខៀវ វិរៈ បានគូសបញ្ជាក់ថា បច្ចុប្បន្នមានប្រជាជនប្រមាណ៨០,០០០នាក់ រស់នៅក្នុងភូមិនានាចំនួន១១៨ភូមិ តាមបណ្តោយដងទន្លេ និងដៃទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង និងខេត្តក្រចេះ កំពុងប្រឈមមុខនឹងហានិភ័យនៃជំងឺព្រូនស៊ីស្តូ ឬជំងឺព្រូនធំពោះ។ ជំងឺព្រូនស៊ីស្តូ ឬជំងឺព្រូនធំពោះ នេះ កើតមាននៅក្នុងស្រុកចំនួន៧ នៃខេត្តចំពីរសាក់របស់ប្រទេស ឡាវ គឺស្រុកស៊ីផាន់ដន និងស្រុកមឿងលះប្រម៉ូក។ លោកបានពន្យល់អំពីវដ្តនៃការចម្លងនៃជំងឺព្រូនធំពោះថា៖

**ទី១) ការបញ្ចេញមេរោគព្រូនស៊ីស្តូ៖** នៅពេលដែលមនុស្សម្នាក់ដែលមានផ្ទុកមេរោគព្រូនស៊ីស្តូ បត់ជើងធំពាសវាលពាសកាល ឬជុះចូលក្នុងទឹកទន្លេមេគង្គ លាមករបស់អ្នកជំងឺដែលមានពងព្រូនស៊ីស្តូ នឹងហូរចូលទៅក្នុងទឹក។

**ទី២) ការលូតលាស់របស់ពងព្រូនស៊ីស្តូនៅក្នុងខ្យង៖** នៅពេលពងព្រូនទាំងនោះបានជ្រៀតចូលទៅក្នុង «ខ្យងខ្វា» រួចវិវត្តខ្លួនទៅជាកូនដង្កូវទឹកព្រូនស៊ីស្តូ ហើយហែលចេញមកក្នុងទឹកទន្លេវិញ។

**ទី៣) ការជ្រាបនៃកូនដង្កូវព្រូនស៊ីស្តូចូលខ្លួនមនុស្ស៖** នៅពេលប្រជាជនណាម្នាក់ចុះហែលទឹក ឬមុជទឹក ឬបោកគក់ ឬនេសាទត្រី នៅក្នុងទន្លេមេគង្គ កូនដង្កូវព្រូនស៊ីស្តូទាំងនេះនឹងជ្រៀតចូលតាមស្បែកមនុស្ស។

**ទី៤) ការបំផ្លាញសុខភាព៖** ពេលចូលទៅដល់ក្នុងរាងកាយ វានឹងធ្វើដំណើរតាមចរន្តឈាមទៅកាន់ពោះវៀនរួចលូតលាស់ជាព្រូនពេញវ័យ និងបង្កើនកូនចៅនៅក្នុងពោះវៀនហើយបញ្ចេញសារជាតិពុលដល់ថ្លើម។

ប្រសិនបើមានបរិមាណព្រូនច្រើនក្នុងរាងកាយ អ្នកជំងឺនឹងចេញរោគសញ្ញាក្អួតចង្អោរ រាករូស ស្គមស្គាំង និងទាចទឹក (ធំពោះ) ដែលជាផលវិបាកបណ្តាលមកពីក្រិនថ្លើម។ លោកបណ្ឌិត ខៀវ វិរៈ បានបញ្ជាក់ថា ប្រសិនមានប្រជាជនមានរោគសញ្ញាដូចខាងលើ សូមប្រញាប់ទៅកាន់មូលដ្ឋានសុខាភិបាលសាធារណៈដែលនៅជិតបំផុត ដើម្បីប្រឹក្សាពិគ្រោះយោបល់ និងធ្វើរោគវិនិច្ឆ័យឱ្យបានត្រឹមត្រូវ ដើម្បីទទួលការព្យាបាលបានទាន់ពេលវេលា។

មណ្ឌលសុខភាពអូរស្វាយ គឺជាព្រះរាជទានដ៏ខ្ពង់ខ្ពស់ឧត្តម និងក្លាយជាគ្រឹះស្ថានសុខាភិបាលសាធារណៈផ្លាល់ក្នុងឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាថែទាំសុខភាពបឋម ពិនិត្យ សម្រាលកូន ពិគ្រោះ និងព្យាបាលជំងឺទូទៅជូនប្រជាជនក្នុងមូលដ្ឋាន ព្រមទាំងផ្តល់ការអប់រំសុខភាពដល់ប្រជាជន។

ជាមួយគ្នាដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា បានចូលរួមបំពេញតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់ជំនួយមនុស្សធម៌ និងការថែទាំយ៉ាងយកចិត្តទុកដាក់ដល់អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ប្រហែល៦០០នាក់ នៅក្នុងស្រុកបុរីអូរស្វាយសែនជ័យ។ អ្នករស់រានមានជីវិតទាំងនោះ ភាគច្រើនមានអាយុចន្លោះពី៦០ ដល់៨០ឆ្នាំ កំពុងប្រឈមមុខនឹងជំងឺប្រចាំកាយ និងវិបត្តិផ្លូវចិត្ត។ ការគាំទ្រឱ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានសេវាសុខភាព និងសេវាសង្គមបានទាន់ពេលវេលា គឺជាបេសកកម្មចម្បងដើម្បីឱ្យជនរងគ្រោះអាចរស់នៅបានយូរអង្វែង មានសុខភាពល្អ និងអាចចែករំលែកបទពិសោធន៍រឿងរ៉ាវប្រវត្តិសាស្ត្រដល់មនុស្សជំនាន់ក្រោយ។ ការកត់ត្រា និងចងក្រងរឿងរ៉ាវទាំងនេះ មានសារសំខាន់សម្រាប់ប្រវត្តិសាស្ត្រជាតិ។

ជាងនេះទៅទៀត អគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យហ្លួងម៉ែ ដែលត្រូវបានកសាងឡើងនៅក្នុងឆ្នាំ២០២៤ ក្រោមការឧបត្ថម្ភពីភ្នាក់ងារសហប្រតិបត្តិការ និងអភិវឌ្ឍន៍អន្តរជាតិតួកគី ស្ថានទូតតួកគីប្រចាំកម្ពុជា និងសម្របសម្រួលដោយរដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ មិនត្រឹមតែជាទីតាំងប្រវត្តិសាស្ត្រ និងការងារសង្គមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានចូលរួមចំណែកក្នុងការទប់ស្កាត់ និងកាត់បន្ថយការរីករាលដាលនៃជំងឺព្រូនស៊ីស្តូ (ជំងឺធំពោះ) តាមរយៈការរៀបចំឱ្យមានបន្ទន់អនាម័យសាធារណៈ សម្រាប់បម្រើដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងការថែរក្សាបរិស្ថានជុំវិញឱ្យមានអនាម័យស្អាតជាប្រចាំ និងមានទឹកស្អាតសម្រាប់បរិភោគ។ អគាររមរតកសង្គមរាស្ត្រនិយមបានដើរតួជា «គំរូអនាម័យនៅក្នុងសហគមន៍» ក្នុងការចូលរួមធ្វើការផ្លាស់ប្តូរឥរិយាបថរស់នៅរបស់ប្រជាជនដែលអាចឱ្យសហគមន៍បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល និងចូលរួមបង្កើតបរិស្ថានរស់នៅស្អាត ដើម្បីបង្ការជំងឺឆ្លងនានានៅក្នុងសហគមន៍។




អាជ្ញាធរមូលដ្ឋាន និងមន្ត្រីមកពីក្រសួងសុខាភិបាល រៀបចំកម្មវិធី «វគ្គបណ្តុះបណ្តាលគ្រូបង្គោល ដើម្បីលុបបំបាត់ជំងឺឆ្លងព្រូនស៊ីស្តូ ឬជំងឺព្រូនធំពោះ និងជំងឺផ្សេងៗក្នុងសហគមន៍ នៅអគាររមរតកសង្គមរាស្ត្រនិយមសម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ពីថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# សិស្សានុសិស្សមកពីសាលាបឋមសិក្សា ប៊ុន រ៉ានី ហ៊ុន សែន កោះថ្ម ទស្សនកិច្ចរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម

ឌន ឫទ្ធា



សិស្សមកពីសាលាបឋមសិក្សា ប៊ុន រ៉ានី ហ៊ុន សែន កោះថ្ម មកទស្សនកិច្ចសិក្សា និងរៀនសូត្រពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម នៅព្រឹកថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅព្រឹកថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៦ សិស្សានុសិស្សមកពីសាលាបឋមសិក្សា ប៊ុន រ៉ានី ហ៊ុន សែន កោះថ្ម ចំនួន២០នាក់ បានធ្វើដំណើរមកទស្សនកិច្ច និងរៀនសូត្រអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ គោលបំណងនៃទស្សនកិច្ច គឺសិស្សានុសិស្សចង់រៀនសូត្រ និងស្វែងយល់អំពីប្រវត្តិសាស្ត្រដ៏ជូរចត់កាលពីអតីតកាល ការកសាងសន្តិភាព ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងជាពិសេសការផ្តល់តម្លៃដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ជាកិច្ចចាប់ផ្តើម កញ្ញា រី ស៊ីថា បានណែនាំខ្លួន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មដល់សិស្សានុសិស្ស មុនធ្វើបទបង្ហាញអំពីផ្ទាំងពិព័រណ៍រូបភាពចំនួន៥ផ្នែក គឺទី១) រូបថតបង្ហាញពីសំណល់ សង្គ្រាមទសវត្សរ៍ ឆ្នាំ១៩៦០ដល់១៩៧០ នៅតំបន់កោះថ្ម។ ទី២) រូបថតបង្ហាញពីជីវិតរស់នៅក្នុងរបប ប៉ុល ពត។ ទី៣) ផ្ទាំងគំនូរបង្ហាញពីដំណើររបស់ សម្តេច ហ៊ុន សែន ឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។ ទី៤) រូបថតបង្ហាញពីការវិលត្រឡប់មកស្រុកភូមិវិញក្នុងឆ្នាំ ១៩៧៩ បន្ទាប់ពីការដួលរលំរបប ប៉ុល ពត និងទី៥)

រូបភាពបង្ហាញពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

បន្ទាប់មកលោក ឈុំ រ៉ា បានបែងចែកប្រធានបទចំនួន៤ គឺការចូលកាន់កាប់ទីក្រុងភ្នំពេញ, ការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជន, ការជម្លៀសដោយបង្ខំ និង ការបញ្ជូនទៅទីតាំងសម្លាប់ទួលពោធិ៍ជ្រៃ ដើម្បីយកមកពិភាក្សាជាក្រុមៗ។

ក្រុមទី១) ពិភាក្សាលើប្រធានបទ«ការចូលកាន់កាប់ទីក្រុងភ្នំពេញ» មានសមាជិកចំនួន៥នាក់រួមមានឈ្មោះ ភារ៉ុន ភារ៉ា, ផ្ទិល វ៉ែង, លាង មាស, វ៉ែត ដារ៉ាន់ និង មើង ម៉ាត់ណា បានយល់ឃើញថា ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានបញ្ចប់រាល់ការជ្រៀតជ្រែកពីបរទេស ការទម្លាក់គ្រាប់បែក និងការប្រឈមអាវុធដាក់គ្នានៃសង្គ្រាមស៊ីវិលរវាងខ្មែរនិងខ្មែរ ដែលអូសបន្លាយពេល៥ឆ្នាំនៅកម្ពុជា ប៉ុន្តែនៅថ្ងៃដដែលនេះ ទីក្រុងភ្នំពេញបានធ្លាក់ក្រោមការគ្រប់គ្រងរបស់កងកម្លាំងកុម្មុយនីស្តទាំងស្រុង។ កងកម្លាំងដែលពាក់ឯកសណ្ឋានពណ៌អាចម៍សេះ និងពណ៌ខ្មៅបានធ្វើដំណើរចូលទីក្រុងពីគ្រប់ទិសទី។ ប្រជាជនភាគច្រើនដែលរស់នៅក្នុងទីក្រុងភ្នំពេញបាននាំគ្នាឈរត្រៀបត្រាតាមដងផ្លូវ ហើយបានស្រែកអបអរសាទរនិងក្រវីទង់ក្រណាត់ស។ ទោះបីជាយ៉ាងនេះក្តី មានមនុស្សជាច្រើននាក់ទៀត បានសម្ងំលាក់ខ្លួននៅក្នុងផ្ទះ ដោយព្រួយបារម្ភថាខ្លួនអាចនឹងត្រូវចាប់ខ្លួនឬបាញ់សម្លាប់។

ក្រុមទី២) ពិភាក្សាលើប្រធានបទ«ការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន» ដែលមានសមាជិកចំនួន៥នាក់មានឈ្មោះ ធី ធារី, អ៊ាម សារុន, គ្រឹម រតនា, ថុល ដានី និង ហាន់ លីហ៊ួវ បានយល់ឃើញថា ប្រជាជននៅតាមទីក្រុងនិងទីប្រជុំជនភាគច្រើនជឿជាក់ថា ខ្លួននឹងរស់នៅប្រកបដោយ សុខសន្តិភាពក្រោមការគ្រប់គ្រងរបស់មេដឹកនាំថ្មី ហើយប្រជាជនគ្រប់រូបនឹងពួតដៃគ្នាធ្វើការ ដើម្បីបង្រួបបង្រួមជាតិ។ ផ្ទុយទៅវិញពីរឬបីម៉ោងបន្ទាប់ពីកាន់កាប់បានទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមបានចាប់ផ្តើមបាញ់រះទៅលើអាកាសជាសញ្ញាបង្ខំប្រជាជនឱ្យចាកចេញពីទីក្រុង។ ខ្មែរក្រហមបានបង្ខំអ្នករស់នៅទីក្រុងភ្នំពេញប្រហែលពីរលាននាក់ ដែលក្នុងនោះរួមបញ្ចូល ទាំងអ្នកភៀសខ្លួនចូលទីក្រុងក្នុងអំឡុងពេលសង្គ្រាម ចំនួនជាងមួយលាននាក់ ឱ្យចាកចេញទៅកាន់ទីជនបទ។ ត្រឹមតែរយៈពេលមួយសប្តាហ៍តែប៉ុណ្ណោះ ប្រជាជនក្នុងទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀតត្រូវបានបណ្តេញចេញឱ្យទៅធ្វើការងារកសិកម្មនៅតាមតំបន់ជនបទ។ មិនមានការលើកលែងណាមួយទេនៅក្នុងការជម្លៀស។ សូម្បីអ្នកជំងឺក៏ត្រូវបានបណ្តេញចេញពីមន្ទីរពេទ្យៗជនភៀសខ្លួនរាប់ពាន់នាក់ជាពិសេសកុមារ មនុស្សចាស់ជរា និងអ្នកជំងឺបានស្លាប់នៅតាមផ្លូវ។ ស្ត្រីមានផ្ទៃពោះជាច្រើនបានស្លាប់នៅពេលសម្រាលកូន ដោយសារតែគ្មានថ្នាំសង្កូវ ឬ សេវាសុខាភិបាល។ ក្មេងៗបានវង្វេងបាត់ពីឪពុកម្តាយ។ ប្រជាជនភាគច្រើនមិនដឹងថា តើមានអ្វីកំពុងតែកើតឡើងនោះទេ។ ប្រជាជនភាគច្រើនដែលបានចាកចេញពីទីក្រុង ត្រូវបានបញ្ជូនទៅកាន់ភូមិស្រុកនៅខាងក្រៅទីក្រុង ជាទីតាំងដែលអ្នកទាំងនោះត្រូវរស់នៅ និងធ្វើការអស់ជាច្រើនខែ។ ក្នុងករណីជាច្រើនប្រជាជនទាំងនោះបាន ផ្លាស់ទីទៅកាន់ទីតាំងផ្សេងដែលមានសាច់ញាតិឬអ្នកមានទំនាក់ទំនងជាមួយខ្លួន។ ប៉ុន្មានខែក្រោយមក ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំ ជាទូទៅតាមរយៈរថយន្តនិងរថភ្លើងទៅកាន់សហករណ៍ ដែលត្រូវបានបង្កើតឡើងនៅពាសពេញផ្ទៃប្រទេស។

ក្រុមទី៣) ពិភាក្សាលើប្រធានបទ«ការជម្លៀសដោយបង្ខំ» មានសមាជិកចំនួន៥នាក់មានឈ្មោះ វិច្ឆិកា អេនី, ភន ពេជ្រ, ពេជ្រ មានបញ្ញកា, លាប សុផា និងវី ស្រីវ៉ែនបានយល់ឃើញថា ជារួមរបបខ្មែរក្រហមបង្កើតឱ្យមានការផ្លាស់ទីប្រជាជនក្នុងដំណាក់កាលទូទៅបី រួមមានៈ ទី១) ការផ្លាស់ទីប្រជាជនចេញពីទីក្រុងនានា ដូចជាទីក្រុងភ្នំពេញ ក្រុងបាត់ដំបង ក្រុងសៀមរាប និងក្រុង ពីរ-បីផ្សេងទៀត ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (រួមបញ្ចូលទាំងការផ្លាស់ទីតាមរយៈរថភ្លើងដែលកើតមានឡើងនៅរយៈពេល៦ខែក្រោយមកទៀត)។ ទី២) ការផ្លាស់ទីប្រជាជននៅតាមទីជនបទ ក្នុងភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម ភូមិភាគបូព៌ា ចាប់តាំងពី





សិស្សមកពីសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម មកទស្សនកិច្ចសិក្សា និងរៀនសូត្រពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម នៅព្រឹកថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចុងឆ្នាំ១៩៧៥ ទៅកាន់ផ្នែកដទៃទៀតនៃប្រទេសកម្ពុជា។ ទី៣) ការផ្លាស់ទីប្រជាជនចេញពីភូមិភាគបូព៌ានៅក្នុងឆ្នាំ១៩៧៧។

ក្រុមទី៤) ពិភាក្សាលើប្រធានបទ «ទួលពោធិ៍ជ្រៃ» មានសមាជិកចំនួន៥នាក់មានឈ្មោះ ខុង សុភី, ជា ដេវិត, អ៊ាម ថាវីន, អឿន ស្រីឡៃ និង ធន់ សុភាត បានយល់ឃើញថា នៅឆ្នាំ១៩៧៥ ទីវាលនេះត្រូវបានគេស្គាល់ថាជាទីតាំងសម្លាប់យ៉ាងអសោចលើទាហានលន់នល់ និងប្រជាជនស៊ីវិលរាប់ពាន់នាក់។ ទីនេះជាទីតាំងនៃការសម្លាប់រង្គាលដ៏សោកសង្រេងមួយនៅអំឡុងពេលនៃការជម្លៀសប្រជាជនដោយបង្ខំទ្រង់ទ្រាយធំលើកដំបូងបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលខ្មែរក្រហមបានបណ្តេញប្រជាជនចេញពីទីក្រុងនិងបាន«ចាត់ថ្នាក់» អតីតមន្ត្រី និងអ្នកគាំទ្ររបបលន់នល់។

ចុងបញ្ចប់នៃដំណើរទស្សនកិច្ច និងរៀនសូត្រអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សិស្សានុសិស្សនៅតាមក្រុមនីមួយៗបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

ក្រុមទី១) យើងមានអារម្មណ៍សប្បាយចិត្ត នៅពេលបានសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ នៅពេលដែលយើងបានស្គាល់ពីប្រសគល់ដ៏រឹងមាំនៃវប្បធម៌ដ៏រុងរឿងរបស់ដូនតា ធ្វើឱ្យយើងមានស្មារតីស្រឡាញ់ជាតិនិងចង់ចូលរួមថែរក្សាការពារមរតកទាំងនោះ។

ក្រុមទី២) យើងចាប់អារម្មណ៍ទៅលើរូបប្រជាជនកំពុងធ្វើស្រែចម្ការ ក្នុងរបបខ្មែរក្រហម។ ពេលឃើញពិព័រណ៍រូបភាពដែលបានដាក់តាំងបង្ហាញ យើងអាណិតដល់លោកតា លោកយាយដែលធ្លាប់រស់នៅឆ្លងកាត់របបខ្មែរក្រហម។ មួយវិញទៀត យើងឃើញរូបភាពអដ្ឋិធាតុបានធ្វើឱ្យយើងមានអារម្មណ៍សោកសៅណាស់។

ក្រុមទី៣) យើងសប្បាយរីករាយនៅពេលបានចូលរួមទស្សនាពិព័រណ៍ និងបានសិក្សាអំពីប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)។ ជាពិសេស យើងបានធ្វើការពិភាក្សាលើប្រធានបទការជម្លៀសប្រជាជនដោយបង្ខំ។

ក្រុមទី៤) យើងរីករាយនៅពេលបានដឹងអំពីប្រវត្តិសាស្ត្រខ្មែរបានច្រើនជាងមុន។ លើសពីនេះទៅទៀត គឺយើងបានដឹងអំពីប្រវត្តិទួលពោធិ៍ជ្រៃ ដែលជាទីតាំងសម្លាប់យ៉ាងអសោចលើទាហានលន់នល់ និងប្រជាជនស៊ីវិលរាប់ពាន់នាក់។

# សិស្សវិទ្យាល័យអន្លង់វែងទស្សនាខ្សែភាពយន្តឯកសារ និងសិក្សាពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

**សួត វិចិត្រ**







*សិស្សវិទ្យាល័យអន្លង់វែងទស្សនាខ្សែភាពយន្តឯកសារ និងសិក្សាពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៦ ការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្តីពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងចាក់បញ្ចាំងខ្សែភាពយន្តឯកសារ ទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម ដល់សិស្សនៃវិទ្យាល័យអន្លង់វែងចំនួន៣នាក់ដើម្បីទស្សនា។ គោលបំណងនៃវេទិកាថ្នាក់រៀនថ្ងៃនេះ គឺចង់លើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ ការកសាងសន្តិភាព និងការផ្សះផ្សានៅតំបន់អន្លង់វែង និងតំបន់ផ្សេងទៀតនៅប្រទេសកម្ពុជា។

នៅក្នុងវេទិកាថ្នាក់រៀននេះ លោក សួត វិចិត្រ បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានធ្វើបទបង្ហាញដោយផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍ក្នុងខែកក្កដា និងបង្ហាញអំពីទំនាក់ទំនងគ្នាយ៉ាងជ្រាលជ្រៅ រវាងបក្សកុម្មុយនីស្តកម្ពុជា(ខ្មែរក្រហម) និងបក្សកុម្មុយនីស្តវៀតណាម គិតត្រឹមខែកក្កដា ឆ្នាំ១៩៧៥។ ខ្មែរក្រហមបានចាប់ផ្តើមធ្វើការបោសសម្អាតផ្ទៃក្នុងបក្សរបស់ខ្លួន ដោយផ្តោតទៅលើកម្មាភិបាលដែលមាននិន្នាការ ឬធ្លាប់មានទំនាក់ទំនងជាមួយវៀតណាម ដូចជា ខ្មែរវៀតមិញ ឬអ្នកធ្លាប់ទៅ

ទទួលការបំពាក់បំប៉ននៅទីក្រុងហាណូយ ប្រទេសវៀតណាម។ ក្រៅពីនេះ ប្រជាជនស៊ីវិលត្រូវបានធ្វើទុក្ខបុកម្នេញ និងរងការសម្លាប់រង្គាលដោយហេតុផលពូជសាសន៍ វណ្ណៈ និងនិន្នាការក្បត់ រហូតឈានទៅដល់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនប្រមាណជិត ២ លាននាក់ បានស្លាប់បាត់បង់ជីវិត ដោយសារការអត់ឃ្លាន ការធ្វើការងារហួសកម្លាំង ជំងឺគ្មានថ្នាំព្យាបាល និងការចាប់យកទៅសម្លាប់។

យោងតាមការរៀបរាប់របស់ឈ្មោះ អុន ទី គឺជាអ្នករស់រានមានជីវិតម្នាក់នៅក្នុងសម័យខ្មែរក្រហម បានប្រាប់រឿងរ៉ាវដ៏គួរឱ្យជូរចត់របស់ខ្លួនថា អ្វីដែលខ្លួនមិនអាចបំភ្លេចបានពីសម័យខ្មែរក្រហម គឺការបាត់បង់ឪពុក បងប្អូនជាទីស្រឡាញ់ ការហូបចុកមិនគ្រប់គ្រាន់ ការធ្វើការងារហួសកម្លាំង និងគ្មានពេលសម្រាក។ គាត់បានរស់នៅក្នុងភាពតក់ស្លុត និងភ័យខ្លាច ព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់។ ប្រសិនបើខ្មែរក្រហមប្រាប់ថា ត្រូវបញ្ជូនទៅ «សហករណ៍ថ្មី» ប្រាកដណាស់គឺខ្មែរក្រហមយកទៅសម្លាប់។ ចំណែកឯអ្នកទោស គឺត្រូវឆ្នាំគុកយកទៅដាក់នៅមន្ទីរឃុំឃាំង ដើម្បីសួរចម្លើយ។

តមកក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានបង្ហាញនូវពិព័រណ៍លលាដ៍ក្បាល និងគ្រោងឆ្អឹងជនរងគ្រោះ បន្ទាប់ពីសោកនាដកម្មនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហម និងចាក់បញ្ចាំងខ្សែភាពយន្តឯកសារមានចំណងជើង «គណៈប្រតិភូនៃបក្សពលករវៀតណាម អញ្ជើញធ្វើទស្សនកិច្ចជាមិត្តភាពនឹងបក្សកុម្មុយនីស្តកម្ពុជា» ឱ្យសិស្សទស្សនា ។

បន្ទាប់ពីទស្សនាចប់ សិស្សទាំងបីនាក់យល់ឃើញថា ការសិក្សាពីប្រវត្តិសាស្ត្រតាមរយៈទស្សនាភាពយន្តឯកសារ ដែលខ្លួនមិនធ្លាប់បានឃើញពីមុនមកជាការល្អ និងទទួលបានចំណេះដឹងថ្មីៗ។ រឿងរ៉ាវដែលយើងធ្លាប់ឮចាស់ៗនិយាយ និងរៀននៅសាលា គឺមានតែមួយផ្នែកតែប៉ុណ្ណោះ។ នៅពេលដែលយើងមកសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺធ្វើឱ្យយើងកាន់តែមានចំណេះដឹងបន្ថែមទៀត។



ផ្ទាំងពិព័រណ៍រូបថតអំពីអដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ

## មកសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ

**ឌីម សុខគា**







*សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ មកសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ នៅព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ មជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀន ស្ដីពីព្រឹត្តិការណ៍ជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម ដោយមានសិស្សានុសិស្សថ្នាក់ទី១១ នៃវិទ្យាល័យជាស៊ីមតាកែវ ចំនួន៦នាក់ មកចូលរួម។ គោលបំណងនៃវេទិកាថ្នាក់រៀន គឺចង់ផ្ដល់ឱ្យសិស្សានុសិស្សស្វែងយល់បន្ថែមពីមាតិកាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយផ្ដោតសំខាន់លើការពិភាក្សាអំពីព្រឹត្តិការណ៍ជម្លៀសដោយបង្ខំនៅក្នុងរបបខ្មែរក្រហម។ សិស្សានុសិស្សមានឱកាសក្នុងការពង្រឹងសមត្ថភាពតាមរយៈការបង្កើតវេទិកាពិភាក្សា និងដោះស្រាយចម្ងល់ផ្សេងៗដែលខ្លួនចង់ដឹងនាពេលកន្លងមក។

ជាកិច្ចចាប់ផ្ដើម បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តតាកែវ ឈ្មោះ ឌីម សុខគា បានធ្វើការណែនាំខ្លួន ទៅកាន់សិស្សានុសិស្ស និងសួរនាំទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីស្ទាបស្ទង់ចំណេះដឹងរបស់សិស្សជាមុនៗ សុខគា បានសួរសំណួរថា តើថ្ងៃនេះ ប្អូនៗចង់ស្វែងយល់ពីព្រឹត្តិការណ៍អ្វីខ្លះដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម? បន្ទាប់ពីទទួលបានចម្លើយពីសិស្សរួច សុខគា បានចំណាយពេល ២០នាទី ធ្វើបទបង្ហាញដល់សិស្សដោយលើកយកមេរៀននៅក្នុងជំពូកទី៣ «ការឡើងកាន់អំណាច

របស់ខ្មែរក្រហម៖ ការជម្លៀសប្រជាជនចេញពីទីក្រុង, ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ»។ តមក សិស្សចំណាយពេល២៥នាទីដើម្បីអានមេរៀនក្នុងជំពូកទី៣ និង១៥នាទីសម្រាប់លើកជាសំណួរដែលខ្លួនចង់ដឹង។

ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញឱ្យទៅរស់នៅទីជនបទឬតំបន់ដាច់ស្រយាល ពីខេត្តមួយទៅខេត្តមួយផ្សេងទៀត។ មុនពេលជម្លៀស ខ្មែរក្រហមពុំបានផ្តល់ដំណឹងដល់ប្រជាជនជាមុនឡើយ។ អំឡុងពេលជម្លៀសប្រជាជនដែលស្លាប់ច្រើនជាងគេ គឺអ្នកជំងឺដែលសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ, កុមារ, ស្ត្រីមានផ្ទៃពោះ, ស្ត្រីដែលទើបតែសម្រាលកូនរួច, ចាស់ជរា និងក្រុមទាហានលន់ នល់ និងបញ្ញវន្តុ។ ក្នុងរបបខ្មែរក្រហមអង្គការបានជម្លៀសប្រជាជនជា៣ដំណាក់កាល គឺដំណាក់កាលទី១) ចាប់តាំងពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនឱ្យចាកចេញពីក្រុងភ្នំពេញ និងទីប្រជុំជនឱ្យទៅរស់នៅតាមបណ្តាខេត្តនានា ឬទីជនបទ។ ដំណាក់កាលទី២) ចាប់តាំងពីចុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានម្លៀសប្រជាជនក្នុងភូមិភាគកណ្តាល ភូមិភាគនិរតី ដោយជម្លៀសតាមរថភ្លើង និងដំណាក់កាលទី៣) ពីចុងឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៨ ដោយខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីភូមិភាគបូព៌ា។

ជាលទ្ធផល ការពិភាក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ធ្វើឱ្យសិស្សានុសិស្សបានដឹងពីព្រឹត្តិ-ការណ៍នៃការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម។ មិនត្រឹមតែប៉ុណ្ណោះ សិស្សានុសិស្សថែមទាំងយល់ដឹងពីសោកនាដកម្មរួម ទាំងការសម្លាប់រង្គាលក្នុងរបបខ្មែរក្រហម។ សិស្សានុសិស្សទាំងអស់បានប្តេជ្ញារួបរួមសាមគ្គីគ្នា ទប់ស្កាត់អំពើហិង្សា ដែលអាចឈានដល់ការកកើតមានអំពើប្រល័យពូជសាសន៍។ ជាចុងបញ្ចប់នៃវេទិកាថ្នាក់រៀន សិស្សានុសិស្សបានបង្ហាញពី ចំណាប់អារម្មណ៍ដូចខាងក្រោម៖




សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ មកសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ នៅព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ឆន្ទ ណាំអនុឧត្តរា៖** ព្រឹកនេះ ខ្ញុំយល់ដឹងពីព្រឹត្តិការណ៍ការជម្លៀសប្រជាជនក្នុងរបបខ្មែរក្រហម។ អំឡុងពេលជម្លៀសប្រជាជនបានជួបទុក្ខវេទនា ដូចជា ព្រាត់ប្រាសក្រុមគ្រួសារ សាច់ញាតិ ប្ដីប្រពន្ធរួមទាំងកូនៗ និងធ្វើឱ្យប្រជាជនស្លាប់អស់ជាច្រើន។ នៅក្នុងរបបខ្មែរក្រហម អង្គការបានប្រើប្រជាជនឱ្យធ្វើការងារហួសកម្លាំង និងមិនឱ្យហូបចុកគ្រប់គ្រាន់។ ខ្ញុំមិនចង់ឱ្យកើតមានសង្គ្រាមទៀតទេ ជាក់ស្ដែងនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ កន្លងមកកើតមានការផ្ទុះអាវុធរវាងកម្ពុជា-ថៃ ធ្វើឱ្យមានចលាចលយ៉ាងខ្លាំង។ ខ្ញុំបានឃើញវិរកងទ័ពពលីជីវិត ចំណែកប្រជាជនដែលរស់នៅតាមតំបន់ព្រំដែន ត្រូវភៀសខ្លួនមករស់នៅតាមខេត្តផ្សេងៗឆ្ងាយពីផ្ទះសម្បែង។

**ផាត ច័ន្ទថារ័ត្ន៖** ខ្ញុំបានយល់ដឹងកាន់តែច្បាស់អំពីរបបខ្មែរក្រហម បន្ថែមពីការរៀននៅសាលា។ ខ្ញុំបានដឹងពីព្រឹត្តិការណ៍ជម្លៀសប្រជាជនដោយបង្ខំ និងបានដឹងពីទុក្ខលំបាករបស់ប្រជាជនដែលធ្លាប់រស់ឆ្លងកាត់របបខ្មែរក្រហម។ ការជម្លៀសប្រជាជនដោយបង្ខំពីកងទ័ពខ្មែរក្រហម បានធ្វើឱ្យប្រជាជនស្លាប់អស់ជាច្រើន។ រឿងមួយដែលធ្វើឱ្យខ្ញុំឈឺចាប់បំផុត គឺខ្មែរសម្លាប់ខ្មែរគ្នាឯង។ ការជម្លៀសពុំមានប្រជាជនណាម្នាក់បានដឹងជាមុនទេ គឺជាល្បិចបោកបញ្ឆោតរបស់ខ្មែរក្រហមដើម្បីឱ្យប្រជាជនជម្លៀសចេញពីផ្ទះសម្បែងទៅកាន់ទីជនបទ។ របបខ្មែរក្រហម គឺជារបបផ្ដាច់ការ។ ជាក់ស្ដែង ខ្ញុំបានឮយាយរបស់ខ្ញុំប្រាប់ថា ក្នុងរបបខ្មែរក្រហម គាត់ត្រូវបែកបាក់បងប្អូន ចំណែកឪពុករបស់គាត់ត្រូវស្លាប់។ យាយរបស់ខ្ញុំត្រូវខ្មែរក្រហមរៀបការជាមួយតារបស់ខ្ញុំ ដោយមិនមានការសុំអនុញ្ញាតពីក្រុមគ្រួសារឡើយ។ ខ្ញុំមិនចង់ឱ្យកើតមានសង្គ្រាមទេ គឺខ្ញុំត្រូវការតែសន្តិភាពតែប៉ុណ្ណោះ។ ជាក់ស្ដែង សង្គ្រាមដែលកើតឡើងនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ធ្វើឱ្យខ្ញុំភ័យខ្លាច និងធ្វើឱ្យលំបាកដល់ក្មេងៗដែលកំពុងរៀនសូត្រ។ រីឯប្រជាជនត្រូវភៀសខ្លួនចាកចោលផ្ទះសម្បែងដើម្បីស្វែងរកតំបន់សុវត្ថិភាព។


សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ មកសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវ នៅព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ធូច សុខចាន់ដារ៉ា៖** ខ្ញុំដឹងពីព្រឹត្តិការណ៍នៃការជម្លៀសប្រជាជនដោយបង្ខំឱ្យទៅរស់នៅតាមបណ្ដាខេត្តនានា ឬតំបន់ដាច់ស្រយាល ក្នុងគោលបំណងឱ្យប្រជាជនទៅធ្វើស្រែចម្ការ។ ការជម្លៀសដោយបង្ខំធ្វើឱ្យប្រជាជនស្លាប់អស់ជាច្រើន។ ខ្ញុំធ្លាប់បានឮយាយរបស់ខ្ញុំប្រាប់ថា របបខ្មែរក្រហម គឺជារបបផ្ដាច់ការ និងបំបិទសិទ្ធិសេរីភាព។ យាយរបស់ខ្ញុំតែងតែផ្ដែផ្ដាំកូនចៅថា ប្រសិនបើយើងរស់នៅក្នុងប្រទេសមានសន្តិភាពហើយ យើងគួរតែកុំនាំគ្នាបង្កឱ្យកើតមានសង្គ្រាម ព្រោះនៅពេលដែលកើតមានសង្គ្រាមនឹងនាំមកនូវផលលំបាកយ៉ាងខ្លាំងដល់ប្រជាជន។ ជាក់ស្ដែង ខ្ញុំបានដឹងអំពីសង្គ្រាមដែលបានកើតឡើងកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ កន្លងមក ធ្វើឱ្យខ្ញុំមានការព្រួយបារម្ភខ្លះដែរ ព្រោះខ្ញុំបានឃើញប្រជាជនចាកចោលផ្ទះសម្បែងដើម្បីស្វែងរកទីទួលសុវត្ថិភាព។ បន្ទាប់ពីខ្ញុំបានឃើញទិដ្ឋភាពទាំងអស់នេះ ខ្ញុំមានអារម្មណ៍អាណិតអាសូរដល់ប្រជាជនដែលរស់នៅតាមតំបន់ព្រំដែនខ្លាំងណាស់ ហើយអ្វីដែលធ្វើឱ្យខ្ញុំសោកស្ដាយទៀតគឺ វីរកងទ័ពយើងបានពលីជីវិតដើម្បីការពារទឹកដី ដូច្នេះហើយ ខ្ញុំមិនចង់ឱ្យកើតមានសង្គ្រាមទៀតទេ។



















# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!

















# កូវ ផល្លា ៖ អតីតយោធា កងពលលេខ៣១០ ដែលបាត់ខ្លួន

អេង សុខម៉េង

កូវ ផល្លា ភេទប្រុស អាយុ ២០ឆ្នាំ (បាត់ខ្លួន១៩៧៦)។ តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបសម្ភាសន៍ជាមួយឈ្មោះ កូវ ស៊្រុន អាយុ៧៣ឆ្នាំ ត្រូវជាឪពុករបស់ផល្លា បានរៀបរាប់ពីប្រវត្តិរូបសង្ខេបដូចខាងក្រោម៖

ផល្លា គឺជាកូនច្បងក្នុងគ្រួសារដែលមានបងប្អូនចំនួន៩នាក់ក្នុងនោះស្រី២នាក់, ទី១) ឈ្មោះកូវ ផល្លា, ទី២) ឈ្មោះកូវផល្លាក, ទី៣) ឈ្មោះ កូវ ផាន, ទី៤) ឈ្មោះ កូវ ផេន, ទី៥) ឈ្មោះ កូវ ភាព, ទី៦) ឈ្មោះ កូវ ស្រេន, ទី៧) ឈ្មោះ កូវ ស្រន, ទី៨) ឈ្មោះ កូវ សោភា និង ទី៩) ឈ្មោះ កូវ សោភ័ណ។ ផល្លា មានស្រុកកំណើតនៅភូមិកំពង់គរ ឃុំតាម៉ៅ (បច្ចុប្បន្នឃុំកំពង់គរ) ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ កាលពីវ័យកុមារភាព ផល្លា រៀននៅសាលាបឋមសិក្សាកំពង់គរ រហូតដល់ថ្នាក់ទី៦ (សង្គមចាស់) ហើយពេលឆ្លងភូមិសិក្សាចូលដល់ថ្នាក់អនុវិទ្យាល័យ ឪពុក-ម្តាយរបស់ផល្លា បានបញ្ជូនគាត់ឱ្យទៅរៀននៅភ្នំពេញ ដោយត្រូវរស់នៅជាមួយម្តាយមីង ដែលជាសាស្ត្រាចារ្យ។



ប្រវត្តិរូបរបស់ កូវ ផល្លា។ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លោក លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែង ជាហេតុនាំឱ្យប្រទេសជាតិធ្លាក់ចូលក្នុងសង្គ្រាម និងមានបាតុកម្មស្ទើរពេញផ្ទៃប្រទេស។ ផល្លា ត្រូវត្រឡប់មករស់នៅស្រុកកំណើតនៅឯខេត្តក្រចេះវិញ។ នៅឆ្នាំ១៩៧២ ផល្លា បានបួសជាព្រះសង្ឃដោយគង់នៅវត្តស្ថិតក្នុងឃុំតាម៉ៅ។ បន្ទាប់ពីបួសបានបីវស្សា ពោលគឺនៅឆ្នាំ១៩៧៤ ផល្លា ត្រូវបានខ្មែរក្រហមបង្ខំឱ្យលាចាកសិក្ខាបទ។ ឪពុករបស់ផល្លា បានរៀបរាប់បន្តថា ចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៣ នៅស្រុកព្រែកប្រសព្វ តែងមានយន្តហោះសហរដ្ឋអាមេរិកមកទម្លាក់គ្រាប់បែកបេ-៥២ នៅក្នុងភូមិ-ឃុំ ស្ទើររាល់ថ្ងៃ ថែមទាំងមានការប្រយុទ្ធរវាងទាហាន លន់ នល់ ជាមួយនឹងកងទ័ពបដិវត្តន៍ខ្មែរក្រហម ព្រោះតំបន់ខេត្តក្រចេះបានធ្លាក់ចូលក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម តាំងពីឆ្នាំ១៩៧០។ នៅពេលមានការទម្លាក់គ្រាប់បែកម្តងៗ គ្រួសាររបស់ផល្លា បានគេចខ្លួនដើម្បីស្វែងរកកន្លែងមានសុវត្ថិភាពប៉ុលេណដ្ឋាន ព្រោះផ្ទះ

របស់ប្រជាជនទាំងអស់ក្នុងភូមិតែងមានដឹកលេណដ្ឋាន។

ភូមិកំពង់គរ បានធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមតាំងពីឆ្នាំ១៩៧០ ប៉ុន្តែអង្គការមិនទាន់ឱ្យប្រជាជនធ្វើការរួម, ហូបរួម, ស្នាក់នៅរួម និងផ្សឹកព្រះសង្ឃនៅឡើយទេ។ រហូតដល់ចុងឆ្នាំ១៩៧៤ ទើបខ្មែរក្រហមបានចាប់ផ្ដើមបង្កើតជាសហករណ៍ និងបង្ខំប្រជាជនឱ្យហូបរួម, រស់នៅរួម និងធ្វើការរួមគ្នា ដើម្បីអនុវត្តតាមផែនការអង្គការ។

នៅឆ្នាំ១៩៧៤ អង្គការបានឃោសនាអូសទាញយុវជន-យុវនារីឱ្យចូលរួមជាមួយកម្លាំងតស៊ូខ្មែរក្រហម។ ពេលនោះ ផល្លា និងយុវជនយុវនារីក្នុងឃុំ ត្រូវបានគណៈឃុំឈ្មោះ ង្គួន បង្ខំឱ្យចូលជាមួយកម្លាំងបដិវត្តន៍ខ្មែរក្រហម។ ឪពុក ផល្លា បានបន្តថា «កូនខ្ញុំមិនចង់ចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហមទេ ព្រោះត្រូវរស់នៅឆ្ងាយពីគ្រួសារ ប៉ុន្តែគ្មានជម្រើសអ្វីក្រៅពីធ្វើតាមអង្គការ ប្រសិនបើបដិសេធមិនចូលរួមនោះខ្មែរក្រហមនឹងចោទប្រកាន់ថាជាខ្មាំង»។

ក្រោយចូលបដិវត្តន៍ ផល្លា ត្រូវបានអង្គការចាត់តាំងឱ្យធ្វើស្រែនៅការដ្ឋានឆ្ងាយពីផ្ទះ។ ផល្លា ធ្វើស្រែបានប្រហែលជាកន្លះខែ អង្គការបានបញ្ជូនឱ្យទៅហ្វឹកហាត់ទ័ពនៅតំបន់ស្ទឹងទ្រ និងជ្រៃដំរី ស្ថិតក្នុងស្រុកព្រែកប្រសព្វ មុនបញ្ជូនទៅចូលរួមប្រយុទ្ធក្នុងសមរភូមិ។ ឪពុក ផល្លា បានត្រឹមទទួលដំណឹងថាកូនបានទៅប្រយុទ្ធជាមួយទាហាន លន់ នល់ នៅទីរួមខេត្តក្រចេះ និងនៅខេត្តកំពង់ចាម ហើយផល្លា មិនដែលបានមកលេងឪពុកម្ដាយបងប្អូនទេ។

នៅឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមឡើងកាន់អំណាចទាំងស្រុងនៅទូទាំងប្រទេស ឪពុក ផល្លា បានបាត់ដំណឹងកូនស្ងូន្យឈឹង ហើយនៅពេលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ នៅតែមិនឃើញកូនត្រឡប់មកផ្ទះវិញ។ ឪពុក ផល្លា និងក្រុមគ្រួសារបានស៊ើបសួរស្វែងរកដំណឹងកូនតាមរយៈយុវជន-យុវនារីដែលបានចូលរួមធ្វើបដិវត្តន៍ជាមួយគ្នា ប៉ុន្តែគ្មាននរណាដឹងពីដំណឹងកូនឡើយ។ ឪពុកផល្លា បាននិយាយថា យុវជន-យុវនារី ដែលទៅចូលរួមបដិវត្តន៍ភាគច្រើនបាត់ដំណឹង មានតិចតួចណាស់បានត្រឡប់មកជួបជុំសាច់ញាតិគ្រួសារវិញក្រោយរបបខ្មែរក្រហម។

យោងតាមប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ឈ្មោះ កូវ ផល្លា ជាយោធាក្នុងកងពលលេខ៣១០ ត្រូវបានអង្គការឃាត់ខ្លួននៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៦ នៅភូមិគ្គុលដងទង់ ជាយក្រុងភ្នំពេញ និងឃុំខ្លួននៅផ្ទះឆ, បន្ទប់ធំ៣, បន្ទប់តូច១៣។



កងទ័ពបដិវត្តន៍ខ្មែរក្រហមនៅសមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជាតិនេះ ខ្ញុំបិះតែនឹងស្លាប់ចំនួន១៨លើក (ត)

សៀវ សុផុន



សៀវ សុផុន បួសជាព្រះសង្ឃនៅវត្តល្វាអំ ឡុងឆ្នាំ១៩៧០ និងឆ្នាំ១៩៧១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចេញពីខ្លួនអស់រលីង ដូច្នេះទម្រាំតែរថក្រោះទាំង៥គ្រឿងនោះចេញផុតទៅ គឺយើងម្នាក់ៗត្រូវសន្ទប់ឈរចំនួន៥ដង។ ខ្ញុំមកដល់ផ្ទះវិញនៅវេលាម៉ោងប្រមាណ១រសៀល។ ឪពុករបស់ខ្ញុំជាមួយបងៗទាំងពីរនាក់ទៀត បានស្តាប់ការរៀបរាប់របស់ បងកាំង រីឯខ្ញុំមិនបាននិយាយទេព្រោះ ហត់ហេវខ្លាំងពេក។ ក្រោយពីយើងហូបបាយរួច យើងទាំងពីរនាក់ប្រះខ្លួនដេកនៅលើគ្រែរៀងៗខ្លួន។ អស់រយៈពេលមួយព្រឹកធំនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំគិតថានឹងត្រូវស្លាប់ច្រើនជាងរស់ព្រោះទី១) ប្រសិនបើកុំតែខ្ញុំរត់គេចចេញពីក្បួនជម្លៀសរបស់យោធាអាវខ្មៅខ្មែរក្រហមរួចប្បាស់ជាពុំដឹងខ្ញុំទៅដល់ទីណាឡើយ គឺក្នុងរយៈពេល៣ឆ្នាំ៨ខែនិងម្ភៃថ្ងៃ ច្បាស់ជាអត់បាយស្លាប់ពុំខាន ព្រោះខ្ញុំមានតែខោអាវតែមួយចង្កេះតែប៉ុណ្ណោះ ពុំមានអ្វីដោះដូរយកអាហារហូបចុកឡើយ។ ទី២) ដោយសារបងកាំងមាត់ពុំមានគម្របដូច្នេះអាចនឹងត្រូវស្លាប់ដោយសារខ្មែរក្រហមដឹងថាយើងគឺជាសិស្សសាលា ឬត្រូវខ្មែរក្រហមវាយចោលដោយរោហាព្រោកប្រាជ្ញរបស់បងកាំងពុំខានឡើយ។ ៣) ប្រសិនជាខ្ញុំត្រូវស្លាប់ពិតមែននោះគឺស្លាប់ដោយបិទភ្នែកពុំជិតឡើយ ព្រោះពុំបានជួបមុខឪពុកដែលខំស្អាត់ពីសៀមរាបមករកកូននៅភ្នំពេញ។

## លើកទី៦ បែកចេញរហូតពីនិស្សិតពេទ្យ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥

តាំងពីដើមមក ខ្ញុំពុំដែលមានទម្លាប់ដេកពេលថ្ងៃទេ។ បន្តិចក្រោយមក ស្រាប់តែខ្ញុំឮស្នូរគោះទ្វារផ្ទះ។ យើងបានទៅបើកទ្វារ ស្រាប់តែឃើញយោធាអាវខ្មៅខ្មែរក្រហមពីរនាក់ប្រដាប់ដោយអាវុធគ្រប់ដៃ ឈរនៅមាត់ទ្វារ និងនិយាយបែបកំបុតកំបុយថា «ទាំងអស់គ្នាត្រូវចេញពីផ្ទះឥឡូវនេះ ដោយខានពុំបានឡើយ។ អង្គការឱ្យចេញទៅតែបីថ្ងៃប៉ុណ្ណោះ ព្រោះបន្តិចទៀតយន្តហោះអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកស្លាប់ទាំងអស់គ្នាជាពុំខាន»។ យោធានោះនិយាយសឹងតែមិនទាន់អស់សេចក្តីក៏ដើរចេញទៅវិញតាមទ្វាររបង ព្រោះទ្វាររបងនិងទ្វារផ្ទះរបស់យើងពីរថ្ងៃកន្លងមកនេះបានបិទជិត ពុំមានចំហឡើយ។ បងកាំងប៊ួយដែលចូលចិត្តស្តាប់សម្តីអ្នកសៀមរាបនិយាយរដឹន បានឃាត់ខ្ញុំមិនឱ្យចាកចេញទេ ដោយនិយាយថា បន្តិចទៀត សាលានឹងបើកឱ្យសិស្សចូលរៀនវិញ។ ឆ្លៀតពេលកំបាំងមុខពីបងប្រុសទាំងបីនាក់ ឪពុកខ្ញុំបានមានប្រសាសន៍តិចៗប្រាប់ខ្ញុំថា គាត់ចង់នាំខ្ញុំទៅជួបមុខម្តាយខ្ញុំវិញ ព្រោះបែកពីគ្នា៥ឆ្នាំមកហើយ។ ប្រសិនបើថ្ងៃក្រោយសាលាបើកទ្វារ ខ្ញុំអាចធ្វើដំណើរចូលមករៀនវិញព្រោះមិនទាន់ហួសពេលឡើយ។ បន្ទាប់ពីឪពុករបស់ខ្ញុំនិយាយប្រាប់ខ្ញុំបានមួយស្របក់ ស្រាប់តែមានយោធាខ្មែរក្រហមម្នាក់ទៀតមកដេញយើងជាលើកទី២ ឱ្យចេញពីផ្ទះ ដោយប្រើពាក្យដូចមុនដដែល។ យើងទាំងពីរនាក់បានរៀបចំអីវ៉ាន់បន្តិចបន្តួចដាក់ចូលទៅក្នុងកាបូបស្បែកធំម្នាក់មួយ ដែលមានខ្សែស្ពាយដូចគ្នា និងបានលាកម្លោះស្រុកសំរោងខេត្តតាកែវទាំងបីនាក់។ យើងស្ពាយកាបូបម្នាក់មួយៗដើរចេញមក ហើយយើងបានបែកគ្នារហូតមកដល់ថ្ងៃនេះតែម្តង។ ក្រៅពីខោអាវ គឺខ្ញុំសង្វាតយកវិញ្ញាបនប័ត្រសិក្សា កាតកូនសិស្សប័ណ្ណសរសើរក្នុងសៀវភៅរៀនសូត្រ តារាងកិត្តិយស រូបថតពេញមួយអាល់ប៊ុមស្ទើ ឡូម៉ាកពី ឡុតមួយដើម និងឧបករណ៍ផ្សំភ្លេង ដែលជាចំណងដៃរបស់មិត្តសម្លាញ់ ប៊ុនធឿន មកជាមួយ។

ក្រៅពីនេះ ខ្ញុំបានស្ពាយរបស់ធ្ងន់ពីមុខគឺម៉ាញេជាប់វិទ្យុប្រើថ្មពិល៥ដុំម៉ាក NIVICO (Japan) មួយគ្រឿង និងវិទ្យុប្រើថ្មពិល៣ដុំម៉ាក SANYO មួយគ្រឿង។ រីឯឪពុកខ្ញុំបានរៀបចំខោអាវដាក់ក្នុងកាបូប និងដែកអង្រួសសម្រាប់រួសឈើថ្មីសន្ទាងមួយដើមដែលទើបនឹងទិញថ្មី ដែលមានទម្រង់ដូចកន្ទុយសត្វកេ ស្ពាយមកជាមួយ។ ឪពុកខ្ញុំបានប្រគល់នាឡិកាដៃម៉ាក RADO

(តនៅលេខក្រោយ)

រូបក្របមុខ៖
សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
ព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 319, July 2026

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.